# សតិបដ្ឋានសូត្រ

ព្រះពុទ្ធវង្ស កិម-តួរ

រៀបរៀង

ធម្មទាននៃគហបតី បេ-យាន

ក្នុងអនុសំវច្ឆរមហាសន្និបាតទី ១៦ នៃមន្ត្រីសង្ឃ

ព.ស. ២៥០៤ គ.ស. ១៩៦០

# សតិបដ្ឋានសូត្រ

ព្រះពុទ្ធវង្ស កិម-តូរ

រៀបរៀង

ធម្មទាននៃគហបតី បេ-យាន

ក្នុងអនុសំវច្ឆរមហាសន្និបាតទី ១៦ នៃមន្ត្រីសង្ឃ

ព.ស. ២៥០២ គ.ស. ១៩៦០

សតិសំចរោ. អ៊ុង - ប៊ុនស៊ីន

# អារម្ភកថា

សៀវភៅសតិបដ្ឋានសូត្រនេះ សំដែងអំពីសតិបដ្ឋាន ៤ យ៉ាង មានកាយានុបស្សនាសតិបដ្ឋានជាដើម ខ្ញុំបានប្រែ - រៀបរៀងសេចក្តីក្នុងផ្ទៃសៀវភៅនេះបំពោះតែសតិបដ្ឋានសូត្រ ជាសូត្រទី ១០ ក្នុងមូលបរិយាយ..វគ្គនៃគម្ពីរមជ្ឈិមនិកាយ មូលបណ្ណាសកៈ មានសេចក្តីទាំងស្រុងត្រូវគ្នានឹងមហាសតិបដ្ឋានសូត្រទី ៩ ក្នុងគម្ពីរទីឃនិកាយ មហាវគ្គដែរ ប៉ុន្តែបាលី មានប្លែកគ្នាបន្តិចបន្តួច ដោយសារលោកអ្នករៀបរៀងក្នុងសម័យជាន់ក្រោយបំប្រួញមិនឲ្យសាំជួនដដែល ៗ ។ ក្នុងវេលាដែលកំពុងរៀបរៀង ខ្ញុំបានយកគម្ពីរឈ្មោះសុមង្គលវិលាសិនី អដ្ឋកថានៃគម្ពីរទីឃ-និកាយមកមើល ហើយអធិប្បាយពង្រីកសេចក្តីដោយអន្លើ ៗ បំពោះតែត្រង់សេចក្តីណាដែលចង្អៀតពិបាកស្តាប់ប៉ុណ្ណោះ ដើម្បីឲ្យទូលាយគំនិតនៃអ្នកសិក្សាបានដោយងាយ ។

អ្នកសិក្សា កាលបើបានមើលចាំស្ទាត់តែខាងសតិបដ្ឋានសូត្រនេះហើយ ក៏ឈ្មោះថា បានមើលចាំស្ទាត់ទាំងមហាសតិបដ្ឋានសូត្រឯណោះផងដែរ ព្រោះសូត្រទាំងពីរនេះ មានទំហំសេចក្តីប៉ុនគ្នា ឥតមានលើសខ្វះអំពីគ្នាឡើយ ឯអត្ថរសសោតទៀត ក៏មានខ្លឹមសារយ៉ាងសំខាន់ដូចគ្នាឲ្យអ្នករៀន នឹងអ្នកស្តាប់កើតប្រាជ្ញា នឹងសេចក្តីស្ងប់ស្ងាត់ចិត្ត ព្រមទាំងមានអានិសង្សជាអស្ចារ្យដល់អ្នកដែលបានចំរើន ដូចមានសំដែងទុកនៅទីបំផុតខាងចុង ព្រោះសូត្រទាំងពីរនេះ និយាយតែអំពីធម៌គឺសតិបដ្ឋាន ៤

ដោយពិស្តារ ៗ ក្នុងអដ្ឋកថានៃធម្មបទបុព្វភាគ មានសេចក្តីសរសើរ ថា សតិបដ្ឋានសូត្រនេះ សូម្បីព្រះពុទ្ធគ្រប់ព្រះអង្គ ក៏ពុំដែលលះបង់ ចោលឡើយ ។

កាលដែលរៀបរៀងចប់ហើយ ខ្ញុំបានយកធម៌នេះ ទៅប្រគេនព្រះ ឧបាលិវង្ស ស្ងួរ-ហាយ ឲ្យជួយពិនិត្យ លុះលោកពិនិត្យរួចហើយ ខ្ញុំក៏ បានយកទៅប្រគេនសម្តេចព្រះមហាសុមេធាធិបតី (ជ. ណា. ជោតញ្ញា- ណោ) សង្ឃនាយក ពិនិត្យសម្រេចថែមទៀត សម្តេចក៏បានពិនិត្យកែ សម្រួល ហើយយល់ឃើញថា ធម៌នេះ គួរបោះពុម្ពផ្សាយ ដើម្បីជា ប្រយោជន៍ដល់បព្វជិត និងគ្រហស្ថអ្នកសិក្សាស្វែងរកសេចក្តីស្ងប់ប្រតិបត្តិ តាម ។

គហបតី មេ-យាង ជាឧបាសកមានសទ្ធា ធ្លាប់បានបោះពុម្ព សៀវភៅធម៌អាថ៌ផ្សេង ៗ ផ្សាយជាធម្មទានប្រគេនព្រះសង្ឃ ដែលនិមន្ត មកក្នុងអនុសំវច្ឆរមហាសន្និបាតនៃមន្ត្រីសង្ឃរៀងរាល់ឆ្នាំពុំដែលខាន ។ លុះដល់មកឆ្នាំនេះទៀត គហបតីនេះ ព្រមទាំងបុត្រី និងបុត្រប្រសា បាន បរិច្ចាគទ្រព្យបោះពុម្ពសៀវភៅនេះចំនួន ៥.០០០ ច្បាប់ ប្រគេនព្រះសង្ឃ គ្រប់វត្តក្នុងកម្ពុជរដ្ឋ ក្នុងឱកាសអនុសំវច្ឆរមហាសន្និបាតទី ១៦ នៃមន្ត្រី ព ស. ២៥០២ ដូចពីក្នុងឆ្នាំមុន ១ រាង ៨ ឆ្នាំកន្លងទៅហើយនោះដែរ ទាំងបានប្តេជ្ញាទុកថា ដរាបណា បើអាយុសង្ខារ និងអាជីវភាព មាន

ដំណើរប្រព្រឹត្តទៅដោយស្រួល ពុំមានឧបសគ្គអ្វីទេ ដកបនោះ នឹងនៅតែចាត់ចែងបោះពុម្ពសៀវភៅធម៌ ឬវិន័យតាមសមគួរចែកផ្សាយជាធម្មទានដូចក្នុងឱកាសឆ្នាំនេះ ឲ្យបានជាប់រៀងរាល់ឆ្នាំតទៅ ។

ខ្ញុំអ្នករៀបរៀងសៀវភៅនេះ សូមអនុមោទនាជាមួយផង ទាំងសូមជូនពរទាំងនេះ គឺ អាយុ វណ្ណៈ សុខៈ ពលៈ សុវត្ថិភាព នឹងវឌ្ឍនភាពគ្រប់ប្រការ ចូរឲ្យកើតមានដល់គហបតី យេ - យាឈ ព្រមទាំងបុត្រ នឹងបុត្រប្រសាជានិច្ចនិរន្តរ៍ កុំបីឃ្លៀងឃ្លាតឡើយ !

ថ្ងៃទី ២៥ វិច្ឆិកា ២៥០២ / ១៩៥៨

ព្រះពុទ្ធវង្ស កិម - តូរ (បន្ទុមង្គលោ)

វត្តឧណ្ណាលោម



លោកឃាយ ថាង់ ផាមាត



ឧបាសិកា ចង



គហបតី បេ - យាង



នាង បេ - ស៊ីវ៉ាន



តាន់ - អៀម - តង់



នាង បេ - ស៊ីវ៉ាត



លី - ជិន - លិម

# សតិបដ្ឋានសូត្រ

នមត្ថុ រតនត្តយស្ស

សូមនមស្ការ ចំពោះព្រះរត្នត្រ័យ (ដោយគោរព) ។

## សេចក្ដីបរិយាយក្នុងខាងដើមនៃសតិបដ្ឋាន

មុននឹងអធិប្បាយសេចក្ដីក្នុងផ្ទៃនៃសតិបដ្ឋាននេះ គួរពុទ្ធសាសនិកជ្រាបថា ព្រះសម្ពុទ្ធជាបរមគ្រូរបស់យើង ចាប់តាំងពីព្រះអង្គបានត្រាស់ដឹងឡើងក្នុងលោក ទ្រង់មានព្រះហឫទ័យប្រកបដោយមហាករុណា ប្រោសប្រទានព្រះសទ្ធម្មទេសនាចំពោះសត្វសត្វក្នុងលោក អស់រយៈកាលចំនួន ៤៥ ឆ្នាំ ដោយមានព្រះពុទ្ធបំណងចង់ឲ្យសត្វបានសម្រេចមគ្គ-ផលក្នុងពេលដែលស្ដាប់ ឬស្ដាប់ហើយនឹងបាន់ប្រតិបត្តិតាម ដើម្បីឆ្ពោះមុខត្រង់ទៅកាន់ព្រះនិព្វានតែម្យ៉ាង មិនមែនមានព្រះបំណងត្រឹមតែដឹកនាំសត្វឲ្យបានសុគតិគឺ មនុស្ស ទេវតា ឬព្រហ្មប៉ុណ្ណោះទេ ពីព្រោះព្រះអង្គទ្រង់ស្គាល់ច្បាស់នូវភពទាំងពួង ដែលទ្រង់ធ្លាប់បានកើតស្លាប់ ស្លាប់កើតដោយផ្ទាល់ព្រះអង្គមក អស់កាលជាអនេកជាតិ ទាំងទ្រង់ឈ្វេងយល់ច្បាស់ដោយញាណផងទៀតថា ភពទាំង ៣ សឹងពេញពោរដោយគំនរភ្លើងទុក្ខនិងភ្លើងកិលេស កំពុងឆេះរោលកំដៅពួកសត្វឲ្យក្ដៅក្រហាយអន្ទះអន្ទែងជានិច្ច ប៉ុន្តែពួកសត្វដែលត្រូវអំណាចអវិជ្ជាដឹកមុខឬបិទបាំង ក៏បែរជាសំគាល់ថា ការកើតនៅក្នុងភពជាការសុខស្រួលទៅវិញ ប្រៀប

ដូចសត្វល្អិតតូច ៗ មានមមាចជាដើម ក្រឡេកឃើញពន្លឺភ្លើងក្នុងរាត្រី ស្មានថាជារបស់ត្រជាក់សុខសប្បាយ ឬស្មានថាជាចំណី ក៏នាំគ្នាហើរទៅហោមពេមលេងប្រឡែងព័ទ្ធក្រឡឹងនាយអាយដោយសេចក្តីវង្វេង មិនយូរប៉ុន្មាន ក៏ដល់នូវសេចក្តីវិនាសស្លាប់ដោយសារភ្លើងនោះឯង យ៉ាងណាមិញ; បុគ្គលដែលត្រូវអវិជ្ជាបិទបាំង សំគាល់ឃើញសម្បត្តិមនុស្សនិងសម្បត្តិទេវតា ក៏ស្មានថាសម្បត្តិទាំងនោះជារបស់វិសេសត្រជាក់ត្រជុំប្រកបដោយសេចក្តីសុខស្រួលទៀងទាត់មិនប្រែប្រួល ម៉្លោះហើយក៏ប្រើនតែនាំគ្នាបំពេញការកុសលផ្សេង ៗ បំពោះតែខាងវដ្តគាមិកុសល គឺកុសលដែលធ្វើដំណើរឲ្យវិលវល់ក្នុងភព ព្រោះតែប្រាថ្នាសម្បត្តិទាំងនោះ ៗ សម្បត្តិទាំងនោះឯង រមែងចងក្រៀកនូវបុគ្គលជាម្ចាស់នោះឲ្យជាប់នៅក្នុងភពហើយដេះពេលដោយគំនរភ្លើងទុក្ខនិងភ្លើងកិលេស ធ្វើឲ្យវិលវល់ស្លាប់កើត ទទួលរងទុក្ខវេទនានៅក្នុងវដ្តៈរឿយ ៗ រកទីបំផុតគ្មាន ក៏យ៉ាងនោះដែរ ។

ម្យ៉ាងទៀត, មនុស្សខ្វាក់ បើមិនមានគេដឹកនាំទេ តែងដើរត្រង់ផ្លូវខ្លះ ខុសផ្លូវខ្លះ យ៉ាងណាមិញ; បុគ្គលដែលប្រកបដោយអវិជ្ជាបិទបាំង មិនដឹងច្បាស់នូវកងទុក្ខ ព្រោះការអន្ទោលទៅមកក្នុងវដ្តៈ បើមិនមានអ្នកប្រាជ្ញដឹកនាំទេ រមែងប្រារព្ធធ្វើនូវបុញ្ញាភិសង្ខារ (ចំណែកខាងបុណ្យ)

ខ្លះ នូវអបុញ្ញាភិសង្ខារ (ចំណែកខាងបាប) ខ្លះ នូវអានេញ្ជាភិសង្ខារ (ចំណែកខាងឈានដែលមានចិត្តវិបល្លាសដោយទិដ្ឋិ មានសស្សតទិដ្ឋិជាដើម) ខ្លះ ក៏យ៉ាងនោះដែរ ។ បុគ្គលនោះ បើទុកជាធ្វើនូវបុញ្ញាភិសង្ខារ គឺការតាក់តែងបុណ្យណាមួយ ដោយកាយ វាចា ចិត្ត បុណ្យនោះឯង រមែងលាយច្រឡំដោយទោសច្រើនប្រការ មានជាតិជរាជាដើម, ព្រោះហេតុអ្វី ? ព្រោះប្រាថ្នានូវសម្បត្តិក្នុងបរលោក គឺសម្បត្តិមនុស្សឬសម្បត្តិទេវតាណាមួយ ដោយសំគាល់ថា សម្បត្តិទាំងនោះឯងប្រសើរប្រកបដោយសេចក្តីសុខទៀងទាត់ ប៉ុន្តែព្រះសព្វញ្ញុពុទ្ធ ពុំដែលសំដែងសរសើរចំពោះកំណើតនៃសត្វដែលទៅកើតជាមនុស្សក្តី ជាទេវតាក្តី ជាព្រហ្មក្តី ថាជាកំណើតប្រកបដោយសុខផុតចាកទុក្ខទាំងពួងឡើយ ព្រោះព្រះអង្គទ្រង់ជ្រាបច្បាស់ថា បើជាតិ (កំណើត) របស់សត្វទាំងឡាយមាននៅដរាបណា ទុក្ខទាំងឡាយមានជាតិទុក្ខជាដើម ក៏មាននៅដរាបនោះដែរ ដោយហេតុនោះបានជា ព្រះអង្គទ្រង់ត្រាស់សរសើរចំពោះតែព្រះនិព្វានមួយ ថាជាធម្មជាតអាចធ្វើសត្វទាំងឡាយឲ្យរលត់ផុតចាកទុក្ខគ្រប់ប្រការបាន ។

ចំណែកខាងបុគ្គលដែលប្រកបដោយវិជ្ជា រមែងមានការយល់ឃើញថា ការកើតជាមនុស្សក្តី កើតជាទេវតាក្តី កើតជាព្រហ្មក្តី ដោយអំណាចនៃកាមាវចរកុសលឬរូបាវចរកុសលណាមួយ ក៏គង់មិនរួចផុតចាកទុក្ខទាំងពួង

បានឡើយ តាំងមានការយល់ឃើញទៀតថា បើជាតិមិនទាន់អស់ទេ ទុក្ខក៏មិនទាន់អស់ដែរ ព្រោះកំណើតរបស់សត្វទាំងឡាយ ដែលកើតក្នុងភពថោកទាបទឹងភពឧត្តមនោះ ៗ ដោយអំណាចនៃកុសលាកុសលកម្ម សុទ្ធតែជាកំណើតនៅមានការប្រែប្រួលមិនទៀងទាត់ កាលបើអស់អំណាចនៃកុសលាកុសលកម្មនោះហើយ សត្វទាំងឡាយនោះឯង ត្រូវតែវិលត្រឡប់រកភពថ្មីទៀតជាធម្មតា ការធ្វើដំណើរវិលវល់ត្រឡប់ចុះឡើងនៅក្នុងវដ្ដៈដោយអំណាចនៃផលបុណ្យទឹងផលបាបដឹកនាំដូច្នេះ តើទីបំផុតនៃទុក្ខរបស់សត្វនៅត្រឹមណា ? បុគ្គលដែលប្រកបដោយវិជ្ជា កាលបើយល់ឃើញយ៉ាងនេះហើយ រមែងមានសេចក្ដីនឿយណាយធុញទ្រាន់ទឹងកំណើតដែលកើតរឿយ ៗ ក្នុងវដ្ដៈនេះ តែងត្រិះរិះរកឧបាយដើម្បីដោះខ្លួនគេចចេញឲ្យរួចផុតស្រឡះចាកភពទាំង ៣ ដោយការខំប្រឹងបំពេញកុសលផ្សេង ៗ បំពោះតែខាងវិវដ្ដគាមិកុសល គឺកុសលដែលធ្វើដំណើរឆ្ពោះទៅកាន់ព្រះនិព្វានជាទីប្រាសចាកវដ្ដៈ ។ បុគ្គលនោះ កាលបើធ្វើកុសលណាមួយ ដោយកាយ វាចា ចិត្ត មានការឲ្យទានជាដើម រមែងតាំងចិត្តដើម្បីពន្រឹងបង្អស់នូវពួកកិលេសមានលោភៈជាដើម ឲ្យរីងស្ងួតអស់ពីខន្ធសន្ដានឈមមុខទៅរកព្រះនិព្វានតែម្យ៉ាងប៉ុណ្ណោះ កុសលរបស់បុគ្គលនេះហៅថាវិវដ្ដគាមិកុសល (កុសលរបស់បុគ្គលអ្នកដល់នូវព្រះនិព្វានដែលរួចស្រឡះចាកការវិលកើតវិលស្លាប់) ។

ធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់លើកឡើងសម្តែង សម្រាប់ឲ្យសត្វប្រតិបត្តិតាម ដើម្បីឆ្ពោះទៅកាន់ព្រះនិព្វាននោះ មានច្រើនជាអនេក ប៉ុន្តែក្នុងទីខ្លះ ទ្រង់សម្តែងសំដៅយកវិបស្សនាតែម្យ៉ាង, ទីខ្លះសំដៅយកទាំងសមថៈទាំងវិបស្សនា, ទីខ្លះសំដៅយកអដ្ឋង្គិកមគ្គ គឺមគ្គប្រកបដោយអង្គ ៨, ទីខ្លះសំដៅយកត្រៃសិក្ខា គឺសីល សមាធិ បញ្ញា, ទីខ្លះសំដៅយកពោធិបក្ខិយធម៌ទាំង ៣៧ មានសតិបដ្ឋាន ៤ និងសម្មប្បធាន ៤ ជាដើម ឯក្នុងទីនេះ សំដៅយកសតិបដ្ឋានទាំង ៤ តែម្យ៉ាងប៉ុណ្ណោះ ។

## សតិបដ្ឋាន

ពាក្យថា សតិបដ្ឋាន ប្រែថា ការដំកល់នូវសតិគឺស្មារតី, សតិប្រែថា ធម្មជាតិជាគ្រឿងរលឹកនឹកឃើញ ។ សតិនេះ ជាគុណជាតិមានប្រយោជន៍សំខាន់បំផុត បំពោះកាតព្វកិច្ច (កិច្ចដែលត្រូវធ្វើ) ទាំងក្នុងគតិលោក ទាំងក្នុងគតិធម៌ ។ បុគ្គល ទោះធ្វើការអ្វីដោយកាយក្តី ទោះនិយាយអ្វីដោយវាចាក្តី ទោះគិតអ្វីដោយចិត្តក្តី ត្រូវមានសតិតាំងនៅជាប្រមុខជាដរាប ទើបការនោះៗ មិនភ្លាត់ខុស អាចញ៉ាំងប្រយោជន៍ឲ្យសម្រេចបាន បុគ្គលខ្លះដែលធ្វើការអ្វីនីមួយដោយកាយ វាចា ចិត្ត ច្រើនតែជ្រលួសភ្លាត់ខុស នាំឲ្យមានអន្តរាយ មិនសម្រេចប្រយោជន៍ ព្រោះតែមិនដំកល់សតិឲ្យរឹងប៉ឹង គឺបណ្តែតបណ្តោយសតិឲ្យរាយមាយទាសទៅ

ក្នុងអារម្មណ៍ផ្សេង ៗ, ចំណែកខាងឥតិធម៌វិញ ក៏ត្រូវអាស្រ័យសតិប្រ-ចាំនៅជាប្រមុខដូចគ្នាដែរ ព្រោះហេតុនោះបានជាព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងធម៌ គឺសតិបដ្ឋាននេះ ទ្រង់ឲ្យលើកសតិមកប្រើជាប្រមុខគ្រប់អន្លើក្នុងការពិចារណាចំរើននូវធម៌នីមួយ ៗ ។

## មគ្គ

ពាក្យថា មគ្គ ប្រែថា ផ្លូវ ។ ធម្មតាផ្លូវ សុទ្ធតែសម្រាប់ឲ្យអ្នកដំណើរទាំងពួង ដើរទៅកាន់ប្រទេសដែលខ្លួនត្រូវការទៅ ៗ ឯមគ្គក្នុងទីនេះ សំដៅយកផ្លូវ គឺសតិបដ្ឋានទាំង ៤ ជាផ្លូវដ៏បរិសុទ្ធស្អាតក្រៃលែង សម្រាប់ឲ្យសត្វលោកប្រតិបត្តិធ្វើដំណើរឆ្ពោះទៅកាន់ព្រះនិព្វាន ។ ព្រោះហេតុនោះ ពុទ្ធសាសនិក គួរបង្អោនចិត្តសិក្សា ស្តាប់ គោរពប្រតិបត្តិតាមសតិបដ្ឋាន ដូចមានសេចក្តីផ្តើមសម្តែងតទៅនេះ ៖

សម័យមួយ ព្រះភគវ័តអរហន្តសម្មាសម្ពុទ្ធ ទ្រង់គង់នៅក្នុងដែនកុរុ អាស្រ័យនូវកម្មាសធម្មនិគមនៃអ្នកដែនកុរុ ដោយហេតុជនទាំងនោះជាអ្នកបរិសុទ្ធមានចិត្តនឹងសតិតាំងនូវមាំជានិច្ច អាចទទួលស្តាប់សតិបដ្ឋាន-សូត្រដែលជាធម៌ល្អិតជ្រាលជ្រៅបាន ។ ព្រោះហេតុនោះបានជាក្នុងគម្ពីរសុមង្គលវិលាសិនីអដ្ឋកថាទីឃនិកាយ មានសេចក្តីសម្តែងសរសើរថាបរិស័ទទាំង ៤ គឺភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ក្នុងដែនកុរុ ច្រើនតែជាអ្នកព្យាយាមចំរើនសតិបដ្ឋានរឿយ ៗ ដោយហោចទៅ សូម្បីពួកជន

ជាទាសៈ នឹងកម្មករ ក៏តែងនាំគ្នានិយាយពាក្យប្រកបដោយសតិបដ្ឋានដែរ ទោះបីក្នុងពេលដែលកំពុងធ្វើការផ្សេង ៗ មានការដងទឹក ពុះឧស បុក រវៃអំបោះជាដើម ក៏មិនសូវនិយាយពាក្យឥតប្រយោជន៍ឡើយ ។ បើស្ត្រីណាមួយ មានគេសួរថា នាងឯង បានធ្វើទុកក្នុងចិត្តនូវសតិបដ្ឋានណាខ្លះ? បើនាងនោះឆ្លើយថា មិនបានធ្វើទុកក្នុងចិត្តនូវអ្វីបន្តិចបន្តួចទេ ។ គេតែងតិះដៀលស្ត្រីនោះថា ថ្វីយ! ជីវិតរបស់នាងឯង ជាជីវិតឥតប្រយោជន៍ដូច្នេះទេឬ នាងឯងបើទុកជាមានជីវិតរស់នៅ ក៏ប្រហែលគ្មានទឹងបុគ្គលស្លាប់ដែរ ។ ហើយគេបានឲ្យឱវាទថា ឥឡូវ នាងឯងកុំធ្វើយ៉ាងនេះតទៅទៀត ។ គេបង្រៀនស្ត្រីនោះ ឲ្យចេះសតិបដ្ឋានណាមួយតាមការគួរ ។ ម្យ៉ាងទៀតបើស្ត្រីណានិយាយថា ខ្ញុំបានធ្វើទុកក្នុងចិត្តនូវសតិបដ្ឋានឈ្មោះនេះ ៗ ។ គេក៏ឲ្យពរសាធុការ ចំពោះស្ត្រីនោះថា ជីវិតរបស់នាង ជាជីវិតប្រសើរណាស់ នាងឯងពេញហៅថាជាមនុស្សមានភ័ព្វ ព្រះសម្មាសម្ពុទ្ធបានត្រាស់ឡើងក្នុងលោក ដើម្បីជាប្រយោជន៍ដល់នាងឯងហើយ ។

ក្នុងដែនកុរុនោះ មិនមែនត្រឹមតែជាតិជាមនុស្សប៉ុណ្ណោះទេ ដែលបានធ្វើទុកក្នុងចិត្តនូវសតិបដ្ឋាន សូម្បីសត្វតិរច្ឆានទាំងឡាយដែលនៅអាស្រ័យនឹងមនុស្សទាំងនោះ គេក៏បង្រៀនឲ្យចេះបរិកម្មនូវសតិបដ្ឋានដែរ ដូចមាននិទានជាឧទាហរណ៍ថា មានអ្នករបាំម្នាក់ ចាប់យកកូនសេកមក

ចិញ្ចឹមបង្រៀនឲ្យនិយាយភាសាមនុស្ស ។ ថ្ងៃមួយ អ្នកបុំនោះ នាំកូនសេកទៅកាន់សំណាក់ភិក្ខុនី វេលាត្រឡប់មកវិញ ក៏ភ្លេចកូនសេកចោលនៅទីនោះ ។ ពួកសាមណេរី ចាប់កូនសេកនោះមកថែទាំទុក កំណត់ឲ្យឈ្មោះសេកនោះថា ពុទ្ធរក្ខិត ។ ថ្ងៃមួយព្រះមហាថេរី ឃើញកូនសេកនោះទំនៅពីខាងមុខ ក៏ហៅសួរថា នែពុទ្ធរក្ខិត! ឯងមានធ្វើទុកក្នុងចិត្តនូវការនាអ្វីខ្លះទេ? សេកឆ្លើយថា ខ្ញុំគ្មានធ្វើទុកក្នុងចិត្តនូវអ្វីទេ ។ ព្រះមហាថេរី និយាយថា នែអាវុសោ! ឯងមកនៅក្នុងសំណាក់នៃបព្វជិត ពុំគួរនៅដោយអត្តភាពឥតប្រយោជន៍ដូច្នេះទេ គួរតែបរិកម្មនូវធម៌ណាមួយកុំខាន ប៉ុន្តែឯងមិនអាចនឹងបរិកម្មនូវធម៌ដទៃបានទេ ចូរឯងស្វាធ្យាយថា អដ្ឋិ អដ្ឋិ (ឆ្អឹង ៗ) ដូច្នេះចុះ ។ សេកនោះឋិតនៅក្នុងឱវាទនៃព្រះមហាថេរី ហើយប្រព្រឹត្តស្វាធ្យាយថា អដ្ឋិ អដ្ឋិ ពុំដែលដាច់ ។ ថ្ងៃមួយមានសត្វខ្លែងមួយ ក្រឡេកឃើញក៏ធាបចុះចាប់កូនសេកនោះដោយក្រញាំក្រចក ដែលកំពុងទំហាលថ្ងៃនៅលើក្លោងទ្វារក្នុងវេលាព្រឹក ។ សេកនោះ បានស្រែកថា កិរិ ៗ ប្តូរក្រិច ៗ ។ ពួកសាមណេរីឮសូរហើយក៏នាំគ្នាចាប់យកដុំដីចោល ដេញតាមស្រែកបន្លឺល សេកនោះឯង ក៏របូតរួចមកវិញ ។ ពួកសាមណេរី នាំសេកនោះមកដាក់នៅខាងមុខព្រះមហាថេរី ៗ ក៏សួរថា នែពុទ្ធរក្ខិត! កាលដែលសត្វស្ទាបធាបនាំឯងទៅនោះ ឯងមានគិតអ្វីខ្លះទេ? សេកឆ្លើយថា ទានខ្ញុំគ្មានគិតអ្វីដទៃទេគឺខ្ញុំ

គិតយ៉ាងនេះថា គំនរថ្មីងមកទាំគំនរថ្មីង ទៅពេយកយទុកក្នុងទីណាអេះ? ខំគិតតែប៉ុណ្ណោះឯង ។ ព្រះមហាថេរនិយាយថា សាធុសាធុ ពុទ្ធក្កិត គំនិតនេះហើយនឹងជាបច្ច័យនាំឲ្យឯងអស់កពទៅក្នុងអនាគតពុំខាន ។

ក្នុងដែនកុរុនោះ សូម្បីសត្វតិរច្ឆាន ក៏ចេះចំរើនសតិបដ្ឋានខ្លះដែរ ដូចរឿងដែលបានសម្ដែងមកនេះឯង ។ ព្រោះហេតុនោះ ព្រះសម្ពុទ្ធ ជាបរមគ្រូ ទ្រង់ជ្រាបថា ពួកជនអ្នកដែនកុរុ មានសេចក្ដីចំរើនល្អតលាស់ ដោយប្រាជ្ញាស្មារតីដ៏សុខុមណាស់ ទើបទ្រង់សម្ដែងនូវសតិបដ្ឋានសូត្រ នេះ ។ ក្នុងវេលាដែលព្រះអង្គប្រារព្ធនឹងសម្ដែងនូវសតិបដ្ឋាន ទ្រង់ត្រាស់ ហៅភិក្ខុទាំងឡាយដោយព្រះពុទ្ធដីកាថា ភិក្ខុទាំងឡាយអើយ! ភិក្ខុទាំង នោះ ក៏ទទួលព្រះពុទ្ធដីកាថា ព្រះករុណាព្រះអង្គ ទើបព្រះមានព្រះភាគ ទ្រង់បាប់សម្ដែងសូត្រនេះថា :

ផ្លូវគឺសតិបដ្ឋានទាំង ៤ នេះ ជាផ្លូវមូលតែមួយ ប្រព្រឹត្ត ទៅដើម្បីសេចក្ដីបរិសុទ្ធិស្អាតរបស់សត្វទាំងឡាយ ដែល មានចិត្តសៅហ្មងដោយមន្ទិលទាំងឡាយមានរាគៈជាដើម នឹងឧបក្កិលេសទាំងឡាយ មានអភិជ្ឈាវិសមលោភៈជា ដើម ដើម្បីកន្លងបង់នូវសេចក្ដីសោកនឹងសេចក្ដីខ្សឹកខ្សួល រំជួលចិត្តទាំងឡាយ ដើម្បីផុតរលត់នៃទុក្ខនឹងទោមនស្ស ទាំងឡាយ ដើម្បីដល់នូវអរិយមគ្គជាធម៌ស្រោចស្រង់សត្វ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវនិព្វាន ។

*សតិបដ្ឋាន ៤ នោះគឺអ្វីខ្លះ ?*

# ១- កាយានុបស្សនាសតិបដ្ឋាន

## ការដំកល់ស្មារតីពិចារណានូវកាយ

ភិក្ខុ មានសេចក្ដីព្យាយាមដុតបំផ្លាញនូវពួកកិលេសក្នុងភពទាំង ៣ ប្រកបដោយញាណគឺសម្បជញ្ញៈ (សេចក្ដីដឹងច្បាស់) ទាំងប្រកបដោយស្មារតីជាគ្រឿងកំណត់ ពិចារណាឃើញនូវកាយក្នុងកាយ (១) បន្ទោបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។

ក្នុងទីនេះ ពាក្យថា អភិជ្ឈានោះបានដល់ កាមច្ឆន្ទៈ គឺចំណង់ក្នុងកាម ឬសេចក្ដីត្រេកត្រអាល, ពាក្យថា ទោមនស្សនោះបានដល់ព្យាបាទៈ ឬបដិឃៈ គឺការចងគំនុំឬសេចក្ដីថ្នាំងថ្នាក់អាក់អន់ក្នុងចិត្ត, ពាក្យថា លោក នោះបានដល់កាយ ដែលជាទីប្រជុំនៃអាការៈទាំង ៣២ មានសក់ រោម ក្រចកជាដើម ឬបានដល់ឧបាទានក្ខន្ធទាំង ៥ មានរូបូបាទានក្ខន្ធជាដើម ។ ភិក្ខុ កាលបើពិចារណាឃើញកាយរបស់ខ្លួនដែលមិនមានវិកលវិការៈ ជាកាយបរិបូណ៌ដោយសុខភាពគ្រប់យ៉ាង ក៏រមែងមានសេចក្ដីត្រេកអរជាប់ចិត្តចំពោះកាយរបស់ខ្លួន ឬប្រាថ្នាចង់ឲ្យកាយរបស់ខ្លួនបានសុខស្រួល

---

១ ពាក្យថាពិចារណាឃើញនូវកាយក្នុងកាយ គឺប្រាកដជាពិចារណាឃើញនូវកាយតែម្យ៉ាង មិនមែនឲ្យទៅពិចារណាឃើញអ្វីដទៃក្រៅពីកាយទេ ។ តទៅពាក្យថាវេទនាក្ដី ចិត្តក្ដី ធម៌ក្ដី គប្បីជ្រាបតាមន័យនេះដែរ ។

ប្រសើរក្រៃលែងជាងនោះទៅទៀតជាធម្មតា បើពុំដូច្នោះទេ គឺកាលបើកាយដល់នូវវិបត្តិ ឬប្រកបដោយទុក្ខណាមួយកើតឡើង ក៏រមែងមានទុក្ខទោមនស្សអាក់អន់ចង្អៀតចង្អល់ចិត្តមិនចង់ឲ្យកើតមានឡើង ឬមិនចង់ឲ្យជួបប្រទះទៀតជាធម្មតា ព្រោះហេតុនោះ ភិក្ខុកាលបើពិចារណាឃើញកាយនេះ ថាជាអត្តភាពឥតខ្លឹមសារតែងធ្លាក់ទៅក្នុងអំណាចនៃលក្ខណៈមានអនិច្ចលក្ខណៈជាដើម ទាំងជាលំនៅនៃសុខនិងទុក្ខ ដែលជាហេតុនាំឲ្យកើតអកុសលធម៌ គឺអភិជ្ឈានិងទោមនស្សដូច្នេះហើយ គួរតែបន្ទោបង់ដោយការសង្កត់សង្កិន ឬដោយការកំចាត់ចេញនូវអភិជ្ឈានិងទោមនស្សកុំឲ្យកើតមានក្នុងកាយនេះតទៅទៀតឡើយ ។

## ២– វេទនានុបស្សនាសតិប្បដ្ឋាន

### ការដំកល់សតិពិចារណានូវវេទនា

ភិក្ខុ មានសេចក្ដីព្យាយាម ដុតបំផ្លាញនូវពួកកិលេសក្នុងភពទាំង៣ ប្រកបដោយញាណ គឺសម្បជញ្ញៈ ទាំងប្រកបដោយសតិជាគ្រឿងកំណត់ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ ហើយបន្ទោបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។

ពាក្យថា វេទនា ប្រែថា ការដឹងនូវអារម្មណ៍មាន ៣ យ៉ាងគឺ ការដឹងនូវអារម្មណ៍ជាសុខដែលប្រព្រឹត្តទៅក្នុងកាយនិងចិត្ត ហៅថា សុខវេទនា ១ ការដឹងនូវអារម្មណ៍ជាទុក្ខដែលប្រព្រឹត្តទៅក្នុងកាយនិងចិត្ត ហៅថា ទុក្ខ-

វេទនា ១ ការដឹងនូវអារម្មណ៍មិនមែនជាទុក្ខ មិនមែនជាសុខ ដែលប្រព្រឹត្ត ទៅក្នុងកាយនិងចិត្ត ហៅថា ឧបេក្ខាវេទនា ១ ។ ភិក្ខុ កាលណាបើបាន ទទួលអារម្មណ៍ជាសុខ ដែលកើតអំពីសម្ផ័ស្ស ទាំងឡាយមានចក្ខុសម្ផ័ស្ស ជាដើម ក៏តែងមានសេចក្តីត្រេកអររីករាយក្នុងកាលនោះ តែងតែចង់ឲ្យសុខ នោះឋិតនៅយឺនយូរ ឬចង់ឲ្យសុខនោះចំរើនកើនឡើងជាងនោះទៅទៀត ។ កាលណាបើបានទទួលអារម្មណ៍ជាទុក្ខ ដែលកើតអំពីសម្ផ័ស្ស ទាំងឡាយ មានចក្ខុសម្ផ័ស្សជាដើមហើយ តែងមានសេចក្តីទុក្ខអាក់អន់ចង្អៀតចង្អល់ ចិត្តក្នុងកាលនោះ ហើយមិនចង់ឲ្យជួបប្រទះនឹងអារម្មណ៍ជាទុក្ខនោះតទៅ ទៀត ព្រោះហេតុនោះ ភិក្ខុ កាលបើបានពិចារណាឃើញនូវវេទនានេះថា ជាធម្មជាតិឥតខ្លឹមសារ តែងធ្លាក់នៅក្នុងអំណាចនៃលក្ខណៈ មានអនិច្ច-លក្ខណៈជាដើម ដែលជាហេតុនាំឲ្យកើតអភិជ្ឈានិងទោមនស្សជួបប្រទះ ហើយ គួរតែបន្ទោបង់ដោយការសង្កត់សង្កិន ឬដោយការកំចាត់ចេញ កុំ ឲ្យកើតមានក្នុងកាយនេះតទៅទៀតឡើយ ។

## ៣ – ចិត្តានុបស្សនាសតិបដ្ឋាន

### ការដំកល់សតិពិចារណានូវចិត្ត

ភិក្ខុ មានសេចក្តីព្យាយាមដុតបំផ្លាញនូវពួកកិលេសក្នុងភពទាំង ៣ ប្រកបដោយញាណ គឺសម្បជញ្ញៈ ទាំងប្រកបដោយសតិជាគ្រឿងកំណត់ ពិចារណាឃើញនូវចិត្តក្នុងចិត្ត ហើយបន្ទោបង់នូវអភិជ្ឈានិងទោមនស្ស

ក្នុងលោក(១) ។

ធម្មជាតដែលតែងត្រិះរិះគិតករកនូវអារម្មណ៍ផ្សេង ៗ ទាំងចំណែកខាងល្អ ទាំងចំណែកខាងអាក្រក់ ហៅថា ចិត្ត ។ ចិត្តនេះដោយសង្ខេបមាន ៨៩ ដួង ដោយពិស្ដារមាន ១២១ ដួង ក៏ពិតមែន ប៉ុន្តែបើបំប្រួញឲ្យខ្លីចុះមក ចិត្តនេះមានត្រឹមតែ ២ គឺ ចិត្តជាកុសល ១ ចិត្តជាអកុសល ១ ។ អភិជ្ឈានិងទោមនស្ស ជាតួចេតសិក អាចជួយជំរុញចិត្តឲ្យកើតសេចក្ដីស្រឡាញ់និងសេចក្ដីស្អប់ក្នុងឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍ជាធម្មតា ព្រោះហេតុនោះ ភិក្ខុ គួរតែបន្ទោបង់ដោយការសង្កត់សង្កិន ឬដោយការកំចាត់នូវអភិជ្ឈានិងទោមនស្សនោះចេញ កុំឲ្យកើតមានតទៅទៀតឡើយ ។

## ៤ – ធម្មានុបស្សនាសតិប្បដ្ឋាន

ការដំកល់សតិពិចារណានូវធម៌

ភិក្ខុ មានសេចក្ដីព្យាយាមដុតបំផ្លាញនូវពួកកិលេសក្នុងភពទាំង ៣ ប្រកបដោយញាណ គឺសម្បជញ្ញៈ ទាំងប្រកបដោយសតិជាគ្រឿងកំណត់ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ហើយបន្ទោបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក (២) ។

ពាក្យថា ធម៌ក្នុងទីនេះ បានដល់នីវរណធម៌ទាំង ៥ យ៉ាងមានកាម-ច្ឆន្ទៈជាដើម ធម៌ដែលជាគ្រឿងពាំងស្កាក់ដំណើរមិនឲ្យកុសលចិត្តកើត

១-២ ពាក្យថាលោក ក្នុងទីនេះ បានអធិប្បាយក្នុងកាយានុបស្សនាសតិបដ្ឋានរួចហើយ ។

ទៀតបាន ហៅថា នីវរណធម៌ ឯអភិជ្ឈានឹងទោមនស្សក្នុងទីនេះ ក៏កប់បញ្ចូលក្នុងពួកនីវរណធម៌ ៥ យ៉ាងនោះដែរ ព្រោះអភិជ្ឈា បានដល់កាមច្ឆន្ទៈ, ទោមនស្ស បានដល់ព្យាបាទៈ ឬបដិឃៈ ធម៌ទាំងពីរយ៉ាងនេះឯង ដែលនាំចិត្តរបស់បុគ្គលឲ្យកើតសេចក្តីស្រឡាញ់នឹងសេចក្តីស្អប់ ចំពោះសត្វនឹងសង្ខារទាំងឡាយ ព្រោះហេតុនោះ ភិក្ខុ កាលបើឃើញទោសនៃអកុសលធម៌គឺអភិជ្ឈានឹងទោមនស្សដូច្នេះហើយ គួរតែបន្ទោបង់ដោយការសង្កត់សង្កិន ឬដោយការកំចាត់នូវអភិជ្ឈានឹងទោមនស្សនោះចេញ កុំឲ្យកើតមានតទៅទៀតឡើយ ។

## កាយានុបស្សនាសតិប្បដ្ឋាន

## អានាបានបព្វៈ

### សង្កាត់នៃការពិចារណាខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល

ភិក្ខុ ពិចារណាឃើញនូវកាយក្នុងកាយ តើដូចម្តេច? ភិក្ខុនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី អង្គុយពត់ខ្លួនតម្រង់កាយ ប្រុងស្មារតី ឈមមុខឆ្ពោះទៅកាន់កម្មដ្ឋាន ។ ភិក្ខុនោះ មានស្មារតីដកដង្ហើមចេញ ទាំងមានស្មារតីដកដង្ហើមចូល, ទោះដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង, ទោះដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង, ទោះដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់

ថា អាត្មាអញដកដង្ហើមចេញខ្លី, ពោះដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី ៗ មិនត្រឹមតែប៉ុណ្ណោះ ភិក្ខុនោះ ហាត់ឲ្យស្ទាត់ថែមទៀតថា អាត្មាអញដឹងច្បាស់នូវពួកខ្យល់ដកដង្ហើមចេញ សឹមដកដង្ហើមចេញ, ហាត់ឲ្យស្ទាត់ថា អាត្មាអញដឹងច្បាស់នូវពួកខ្យល់ដកដង្ហើមចូល សឹមដកដង្ហើមចូល, ហាត់ឲ្យស្ទាត់ថា អាត្មាអញរម្ងាប់នូវកាយសង្ខារទាំងអស់ សឹមដកដង្ហើមចេញ, ហាត់ឲ្យស្ទាត់ថា អាត្មាអញរម្ងាប់នូវកាយសង្ខារទាំងអស់ សឹមដកដង្ហើមចូល ៗ ប្រៀបដូចជាងក្រឡឹង និងកូនសិស្សនៃជាងក្រឡឹងដែលប៉ិនប្រសប់ ពោះទាញខ្សែក្រឡឹងវែង ក៏ដឹងច្បាស់ថា អាត្មាអញទាញខ្សែក្រឡឹងវែង, ពោះទាញខ្សែក្រឡឹងខ្លី ក៏ដឹងច្បាស់ថា អាត្មាអញទាញខ្សែក្រឡឹងខ្លី យ៉ាងណាមិញ; ភិក្ខុពោះដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង, ពោះដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង, ពោះដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី, ពោះដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី ក៏យ៉ាងនោះដែរ ៗ

មិនត្រឹមតែប៉ុណ្ណោះ ភិក្ខុត្រូវហាត់ប្រិតប្រៀបថា អាត្មាអញកំណត់ដឹងឲ្យច្បាស់នូវពួកខ្យល់ដកដង្ហើមចេញ សឹមដកដង្ហើមចេញ ទាំងកំណត់ដឹងច្បាស់នូវពួកខ្យល់ដកដង្ហើមចូល សឹមដកដង្ហើមចូល, ត្រូវហាត់ឲ្យស្ទាត់ថា អាត្មាអញរម្ងាប់នូវកាយសង្ខារទាំងអស់ សឹមដកដង្ហើម

ចេញ ទាំងរម្ងាប់នូវកាយសង្ខារទាំងអស់ សឹមដកដង្ហើមចូល ។

ពាក្យថា អស្សាសៈបស្សាសៈ គឺខ្យល់ដកដង្ហើមចេញនឹងខ្យល់ដកដង្ហើមចូលដ៏គ្រោតគ្រាត ដែលប្រព្រឹត្តទៅមកក្នុងកាយ ដូចខ្យល់ដែលធ្វើឲ្យញ័រកាយ, រញ្ជួយកាយ ឬកម្រើកកាយជាដើម ហៅថា កាយសង្ខារ ។ យោគាវចរ អ្នកចំរើនអានាបានស្សតិកម្មដ្ឋាន ហាត់ធ្វើខ្យល់អស្សាសៈបស្សាសៈ ឲ្យថ្នឹកស្ងាត់ឲ្យកាន់តែខ្លីតិចទៅ ។ ដរាបដល់ខ្យល់នោះឯងអស់រលត់ស្ងួនស្ងប់លែងមានប្រព្រឹត្តទៅក្នុងកាយ ហៅថា រម្ងាប់កាយសង្ខារប្រហែលគ្នានឹងបុគ្គលស្លាប់ នឹងបុគ្គលអ្នកចូលនិរោធសមាបត្តិដែរ ។ ឯបុគ្គលស្លាប់នឹងបុគ្គលចូលនិរោធសមាបត្តិនោះ មានការប្លែកគ្នាខ្លះ គឺបុគ្គលស្លាប់មានកាយសង្ខារ វចីសង្ខារ ចិត្តសង្ខាររលត់ អាយុក៏អស់ ភ្លើងធាតុក៏រលត់ ឥន្ទ្រិយក៏បែកធ្លាយ ចំណែកខាងបុគ្គលចូលនិរោធសមាបត្តិមានកាយសង្ខារ វចីសង្ខារ ចិត្តសង្ខាររលត់ស្ងប់ដែរ ប៉ុន្តែអាយុមិនអស់ភ្លើងធាតុមិនរលត់ស្ងប់ ឥន្ទ្រិយក៏នៅពុំទាន់បែកធ្លាយ ។

តមក ភិក្ខុនោះ ពិចារណាឃើញនូវកាយក្នុងកាយជាខាងក្នុង គឺកាយរបស់ខ្លួនផង ពិចារណាឃើញនូវកាយក្នុងកាយជាខាងក្រៅ គឺកាយរបស់អ្នកដទៃផង ពិចារណាឃើញនូវកាយក្នុងកាយទាំងខាងក្នុងទាំងខាងក្រៅផង ។ ភិក្ខុនោះ ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងកាយផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងកាយផង ពិចារណាឃើញ

នូវធម៌ដែលប្រជុំកើតឡើងទាំងធម៌ដែលសូន្យទៅក្នុងកាយផង ។ ម្យ៉ាងទៀត ស្មារតីរបស់ភិក្ខុនោះ ក៏តាំងឡើងប្រាកដថា កាយនេះ គ្រាន់តែជាកាយប៉ុណ្ណោះឯង មិនមែនសត្វ មិនមែនបុគ្គល មិនមែនស្ត្រី មិនមែនបុរសទេ កំណត់ដើម្បីឲ្យចំរើនប្រាជ្ញា ឲ្យមានស្មារតីរឹងប៉ឹងប៉ុណ្ណោះ ដោយអំណាចនៃការពិចារណាឃើញច្បាស់ដូច្នេះហើយ ចិត្តរបស់ភិក្ខុនោះ មិនជាប់ជំពាក់ មិនអាស្រ័យនៅដោយតណ្ហានិងទិដ្ឋិផង ទាំងមិនមានសេចក្តីប្រកៀកប្រកាន់នូវអ្វីនីមួយតិចតួចក្នុងលោកផង ។

ពាក្យថា ធម៌ដែលប្រជុំកើតឡើងក្នុងកាយនិងធម៌ដែលសូន្យទៅក្នុងកាយនោះ បានដល់ខ្យល់អស្សាសៈនិងបស្សាសៈ ដែលអាស្រ័យនៅក្នុងករជកាយផង អាស្រ័យនៅក្នុងក្តោងច្រមុះផង អាស្រ័យនៅនឹងចិត្តផង ដែលសញ្ចរទៅមកបាន ហៅថាធម៌ប្រជុំកើតឡើង កាលបើធម៌ទាំងនោះឯងរលត់បាត់ទៅវិញ ហៅថាធម៌សូន្យទៅ ។

សេចក្តីដែលពោលមកនេះ ហៅថា ភិក្ខុ ពិចារណាឃើញនូវកាយក្នុងកាយ ។

អានាបានបព្វៈ ចប់ ។

# ឥរិយាបថបព្វៈ

## សង្ខាត់នៃការពិចារណានូវឥរិយាបថ

ភិក្ខុ ដោះដើរ ក៏ដឹងច្បាស់ថា អាត្មាអញដើរ, ដោះឈរ ក៏ដឹង

ច្បាស់ថា អាត្មាអញឈរ, ទោះអង្គុយ ក៏ដឹងច្បាស់ថា អាត្មាអញអង្គុយ, ទោះដេក ក៏ដឹងច្បាស់ថា អាត្មាអញដេក;ម្យ៉ាងទៀត ភិក្ខុនោះ ទោះមានកាយដំកល់នៅដោយអាការយ៉ាងណា ៗ ក៏ដឹងច្បាស់នូវកាយនោះដោយអាការយ៉ាងនោះ ៗ ។

តមក ភិក្ខុនោះ ឈ្មោះថាពិចារណាឃើញនូវកាយក្នុងកាយជាខាងក្នុង គឺកាយរបស់ខ្លួនផង ទាំងឈ្មោះថាពិចារណាឃើញនូវកាយក្នុងកាយជាខាងក្រៅ គឺកាយរបស់អ្នកដទៃផង ។ ប ។[1] ដោយអំណាចនៃការពិចារណាឃើញដូច្នេះ ចិត្តរបស់ភិក្ខុនោះក៏មិនជាប់ជំពាក់ មិនអាស្រ័យនៅដោយតណ្ហានិងទិដ្ឋិផង ទាំងមិនមានសេចក្ដីប្រកៀកប្រកាន់នូវអ្វីនីមួយតិចតួចក្នុងលោកផង ។

សេចក្ដីដែលពោលមកនេះ ហៅថា ភិក្ខុ ពិចារណាឃើញនូវកាយក្នុងកាយ ។

ឥរិយាបថបព្វៈ ចប់ ។

## សម្បជញ្ញបព្វៈ

### សង្កាត់នៃការកំណត់ដឹងច្បាស់នូវកិច្ចដែលធ្វើ

ភិក្ខុ កាលឈានដើរទៅមុខ ឬឈានថយក្រោយ ក៏ដឹងខ្លួនច្បាស់, កាលក្រឡេកមើលទៅមុខ ឬក្រឡេកមើលទៅទិសផ្សេង ៗ ក៏

---

[1] ត្រូវជ្រាបថា សេចក្ដីនេះបានអធិប្បាយក្នុងខាងដើម ត្រង់អានាបានបព្វៈរួចហើយ ។

ដឹងខ្លួនច្បាស់, កាលបត់អង្គុញ ឬលាតសណ្ដូកដៃជើង ក៏ដឹងខ្លួនច្បាស់, កាលទ្រទ្រង់នូវសង្ឃាដី បាត្រ, ចីវរ ក៏ដឹងខ្លួនច្បាស់, កាលស៊ី ផឹក ទំពា ហុត ស្រូប នូវភោជនផ្សេងៗ មានចង្ហាន់បិណ្ឌបាតជាដើម ក៏ដឹងខ្លួនច្បាស់, កាលបន្ទោឧច្ចារៈ ឬបស្សាវៈ ក៏ដឹងខ្លួនច្បាស់, កាលដើរ ឈរ អង្គុយ ដេក ភ្ញាក់ និយាយស្ដី នៅស្ងៀម ក៏ដឹងខ្លួនច្បាស់ ។

តមក ភិក្ខុនោះ ឈ្មោះថាពិចារណាឃើញនូវកាយក្នុងកាយជាខាងក្នុង គឺកាយរបស់ខ្លួនផង ទាំងឈ្មោះថាពិចារណាឃើញនូវកាយក្នុងកាយជាខាងក្រៅ គឺកាយរបស់អ្នកដទៃផង ។ប។ ដោយអំណាចនៃការពិចារណាឃើញដូច្នេះ ចិត្តរបស់ភិក្ខុនោះ ក៏មិនជាប់ជំពាក់ មិនអាស្រ័យនៅដោយតណ្ហានិងទិដ្ឋិផង ទាំងមិនមានសេចក្ដីប្រកៀកប្រកាន់នូវអ្វីៗនីមួយតិចតួចក្នុងលោកផង ។

សេចក្ដីដែលពោលមកនេះ ហៅថា ភិក្ខុ ពិចារណាឃើញនូវកាយក្នុងកាយ ។

សម្បជញ្ញបព្វៈ ចប់ ។

# បដិក្កូលបព្វៈ

## សង្ខាត់នៃការពិចារណានូវអាការៈ ៣២ ថាជាបដិក្កូល

ភិក្ខុ ពិចារណាឃើញច្បាស់នូវកាយនេះ គឺខាងលើតាំងអំពីបាតជើង

ឡើងទៅ ខាងក្រោមតាំងអំពីចុងសក់ចុះមក ទីបំផុតជុំវិញត្រឹមស្បែក ដែលពេញដោយវត្ថុមិនស្អាតមានប្រការៈផ្សេង ៗ មាននៅក្នុងកាយនេះគឺ សក់ទាំងឡាយ រោមទាំងឡាយ ក្រចកទាំងឡាយ ធ្មេញទាំងឡាយ ស្បែក សាច់ សរសៃទាំងឡាយ ឆ្អឹងទាំងឡាយ ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសម្បោរ ទឹករំអិល ទឹកមូត្រ ។ ប្រៀបដូចថៃ មានមុខទាំងពីរខាង ដែលពេញដោយធញ្ញជាតិផ្សេង ៗ គឺស្រូវសាលី ស្រូវ ខ្សាយ សណ្តែកបាយ សណ្តែកកជមាស ល្ង អង្ករ, បុរសដែលមាន ចក្ខុបសាទស្រាយមុខថៃនោះចេញហើយ រមែងឃើញច្បាស់ថា នេះស្រូវ សាលី នេះស្រូវខ្សាយ នេះសណ្តែកបាយ នេះសណ្តែកកជមាស នេះ ល្ង នេះអង្ករ យ៉ាងណាមិញ;

ភិក្ខុ ពិចារណាឃើញច្បាស់នូវកាយនេះគឺ ខាងលើតាំងអំពីបាតជើង ឡើងទៅ ខាងក្រោមតាំងអំពីចុងសក់ចុះមក ទីបំផុតជុំវិញត្រឹមស្បែក ដែលពេញដោយវត្ថុមិនស្អាតមានប្រការៈផ្សេង ៗ មាននៅក្នុងកាយនេះថា នេះសក់ នេះរោម ។ ល ។ នេះទឹករំអិល នេះទឹកមូត្រ ក៏យ៉ាងនោះដែរ ។

តមក ភិក្ខុនោះឈ្មោះថាពិចារណាឃើញនូវកាយក្នុងកាយជាខាងក្នុង គឺកាយរបស់ខ្លួនផង ទាំងឈ្មោះថាពិចារណាឃើញនូវកាយក្នុងកាយជា

ខាងក្រៅ គឺកាយរបស់អ្នកដទៃផង ។ល។ ដោយអំណាចនៃការពិចារណាឃើញដូច្នេះ ចិត្តរបស់ភិក្ខុនោះក៏មិនជាប់ជំពាក់ មិនអាស្រ័យនៅដោយតណ្ហានិងទិដ្ឋិផង ទាំងមិនមានសេចក្តីប្រកៀកប្រកាន់នូវអ្វីនីមួយតិចតួចក្នុងលោកផង ។

សេចក្តីដែលពោលមកនេះ ហៅថា ភិក្ខុ ពិចារណាឃើញនូវកាយក្នុងកាយ ។

បដិកូលបព្វៈ ចប់ ។

# ធាតុបព្វៈ

សង្កាត់នៃការពិចារណានូវកាយថាជាធាតុ

ភិក្ខុ ពិចារណានូវកាយនេះ ឃើញច្បាស់ថា កាយនេះគ្រាន់តែជាធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ ប៉ុណ្ណោះឯង គ្មានអ្វីក្រៅអំពីធាតុទាំងនេះឡើយ ប្រៀបដូចគោឃាតកបុរស (បុរសអ្នកសម្លាប់មេគោ) ដែលជាអ្នកប៉ិនប្រសប់ នាំមេគោ(១) ទៅកាន់កន្លែងសម្លាប់ លុះសម្លាប់ហើយក៏អារពន្លះសាច់មេគោនោះ ទុកដាក់ដោយឡែក ៗ ពីគ្នា ហើយនាំយកសាច់មេគោនោះ ទៅដាក់អង្គុយលក់ក្នុងទីប្រជុំផ្លូវធំមានមុំ ៤ ។ គោឃាតកបុរសនោះគ្មានសេចក្តីសំគាល់ថា អញលក់មេគោទេ គ្រាន់តែសំគាល់ថា

---

១ ប្រែពីបាលីថា គាវី, ពាក្យថា គាវី នេះប្រែថា គោញី ឬ មេគោ ប៉ុន្តែដោយសេចក្តីអធិប្បាយ មិនចំពោះតែគោញី ឬមេគោទេ តាមតែគោប្រភេទណាក៏ដោយ គោឃាតកបុរសអាចពិឃាតបានដូចគ្នា ។

ញលក់សាច់គោតែម្យ៉ាង យ៉ាងណាមិញ; ភិក្ខុ ពិចារណាវែកញែកច្បាស់នូវកាយនេះឯង ដែលឋិតនៅដោយឥរិយាបថយ៉ាងណា មានអវយវៈតូចធំដំកល់នៅយ៉ាងណា ឃើញច្បាស់ថាជាធាតុពិត ៗ ដែលមាននៅក្នុងកាយថា នេះធាតុដី នេះធាតុទឹក នេះធាតុភ្លើង នេះធាតុខ្យល់ ក៏យ៉ាងនោះដែរ ។

លំដាប់តមក ភិក្ខុនោះ ឈ្មោះថា ពិចារណាឃើញនូវកាយក្នុងកាយជាខាងក្នុង គឺកាយរបស់ខ្លួនផង ទាំងឈ្មោះថា ពិចារណាឃើញនូវកាយក្នុងកាយជាខាងក្រៅ គឺកាយរបស់អ្នកដទៃផង ។ប។ ដោយអំណាចនៃការពិចារណាឃើញដូច្នេះ ចិត្តរបស់ភិក្ខុនោះ ក៏មិនជាប់ជំពាក់ មិនអាស្រ័យនៅដោយតណ្ហានិងទិដ្ឋិផង ទាំងមិនមានសេចក្ដីប្រកៀកប្រកាន់នូវអ្វីនីមួយតិចតួចក្នុងលោកផង ។

សេចក្ដីដែលពោលមកនេះ ហៅថា ភិក្ខុ ពិចារណាឃើញនូវកាយក្នុងកាយ ។

ធាតុបព្វៈ ចប់ ។

# នវសីវថិកាបព្វៈ

សង្ខាត់នៃការពិចារណានូវសរីរៈស្លាប់ដែលគេចោលក្នុងព្រៃស្មសាន

ភិក្ខុ ឃើញសរីរៈស្លាប់ដែលគេចោលក្នុងព្រៃស្មសាន(១) ទោះស្លាប់

---

១ ពាក្យសំស្ក្រឹតថា ស្មសាន (ស្មៈសាន) ពាក្យបាលីថា សុសាន គឺព្រៃសម្រាប់ចោលសពស្រស់ តាមទម្លាប់អ្នកជម្ពូទ្វីបក្នុងសម័យបុរាណ ។

អស់មួយថ្ងៃ ឬស្លាប់អស់ពីរថ្ងៃ ឬក៏ស្លាប់អស់បីថ្ងៃ ដែលកំពុងហើម មានសម្បុរខៀវដោយច្រើន មានខ្ទុះហូរចេញតាមទ្វារផ្សេង ៗ ក្តី ៗ ឃើញសរីរ ស្លាប់ ដែលគេចោលក្នុងព្រៃស្មសាន ដែលពួកសត្វស្លាបគឺ ក្អែក ត្មាត ត្រដក់ និងពួកសត្វជើង៤ គឺ ឆ្កែ ចចកជាដើម កំពុងដណ្តែងចឹកកកេរស៊ី ឬពួកបាណកជាតិ (សត្វល្អិតតូច ៗ មានដង្កូវជាដើម) កំពុងរូងជញ្ជក់ស៊ីក្តី ឃើញសរីរៈស្លាប់ដែលគេចោលក្នុងព្រៃស្មសាន នៅសល់ទាំងកង្ឆ្អឹងទាំងសាច់និងឈាម ទាំងនៅមានសរសៃជាគ្រឿងចងនៅឡើយក្តី ឃើញសរីរៈស្លាប់ដែលគេចោលក្នុងព្រៃស្មសាន នៅសល់តែកង្ឆ្អឹង គតសាច់ គ្រាន់តែប្រឡាក់ដោយឈាម ទាំងនៅមានសរសៃជាគ្រឿងចងនៅឡើយក្តី ឃើញសរីរៈស្លាប់ដែលគេចោលក្នុងព្រៃស្មសាន នៅសល់តែកង្ឆ្អឹងមិនមានសាច់និងឈាម តែនៅមានសរសៃជាគ្រឿងចងនៅឡើយក្តី ឃើញសរីរៈស្លាប់ដែលគេចោលក្នុងព្រៃស្មសាន សល់នៅតែកង្ឆ្អឹងទទេ ប្រាសចាកសរសៃជាគ្រឿងចង ខ្ចាត់ខ្ចាយរាត់រាយទៅក្នុងទិសតូចនិងទិសធំផ្សេង ៗ គឺឆ្អឹងដៃទៅដោយឡែក ឆ្អឹងជើងទៅដោយឡែក និងឆ្អឹងឯទៀត ៗ ទៅដោយឡែក ៗ ពីគ្នាក្តី ឃើញសរីរៈស្លាប់ដែលគេចោលក្នុងព្រៃស្មសាន សល់នៅតែកង្ឆ្អឹងទទេ មានសម្បុរស ដូចជាសម្បុរនៃស័ង្ខក្តី ឃើញសរីរៈស្លាប់ដែលគេចោលក្នុងព្រៃស្មសាន សល់នៅតែកង្ឆ្អឹងទទេ រោយរាយជាពំនូក ៗ កន្លងមួយឆ្នាំទៅ

ហើយក្តី ឃើញសរីរៈស្លាប់ដែលគេចោលក្នុងព្រៃស្មសាន សល់នៅតែរាងឆ្អឹងទទេ ពុកផុយ ខ្ទេចខ្ទីជាលំអិតតូច លំអិតធំផ្សេង ៗ ក្តី ភិក្ខុនោះនាំចូលមកប្រៀបនឹងកាយរបស់ខ្លួនថា សូម្បីកាយរបស់អាត្មាអញនេះសោត ក៏គង់នឹងមានសភាពដូច្នោះ គង់នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវភាពដូច្នោះទៅពុំបានឡើយ ។

លំដាប់តមក ភិក្ខុនោះ ពិចារណាឃើញនូវកាយក្នុងកាយជាខាងក្នុងគឺកាយរបស់ខ្លួន ពិចារណាឃើញនូវកាយក្នុងកាយជាខាងក្រៅ គឺកាយរបស់អ្នកដទៃ ឈ្មោះថា ពិចារណាឃើញនូវកាយក្នុងកាយ ទាំងខាងក្នុងទាំងខាងក្រៅ ។ ភិក្ខុនោះ ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងកាយ ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងកាយ ឈ្មោះថាពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងកាយ ។ ម្យ៉ាងទៀត ស្មារតីរបស់ភិក្ខុនោះ ក៏តាំងឡើងប្រាកដថា កាយនេះ គ្រាន់តែជាកាយប៉ុណ្ណោះឯង មិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រ្តី មិនមែនបុរសទេ កំណត់ដើម្បីឲ្យចំរើនប្រាជ្ញា ឲ្យមានស្មារតីរឹងប៉ឹងប៉ុណ្ណោះដោយអំណាចនៃការពិចារណាឃើញច្បាស់ដូច្នេះហើយ ចិត្តរបស់ភិក្ខុនោះ ក៏មិនជាប់ជំពាក់ មិនអាស្រ័យនៅដោយតណ្ហានឹងទិដ្ឋិផង ទាំងមិនមានសេចក្តីប្រកៀកប្រកាន់នូវអ្វីនីមួយតិចតួចក្នុងលោកផង ។

សេចក្ដីដែលពោលមកនេះ ហៅថា ភិក្ខុ ពិចារណាឃើញនូវកាយក្នុងកាយ ។

នវសីវថិកាបព្វៈ ចប់ ។

កាយានុបស្សនាសតិបដ្ឋាន ចប់ ។

# វេទនានុបស្សនាសតិបដ្ឋាន

ភិក្ខុ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ តើដូចម្ដេច? ភិក្ខុ កាលទទួលនូវវេទនាជាសុខ ក៏ដឹងច្បាស់ថា អាត្មាអញទទួលនូវវេទនាជាសុខ កាលទទួលនូវវេទនាជាទុក្ខ ក៏ដឹងច្បាស់ថា អាត្មាអញទទួលនូវវេទនាជាទុក្ខ កាលទទួលនូវវេទនាមិនមែនជាទុក្ខ មិនមែនជាសុខ ក៏ដឹងច្បាស់ថា អាត្មាអញទទួលនូវវេទនាមិនមែនជាទុក្ខ មិនមែនជាសុខ។

ការទទួលដឹងនូវអារម្មណ៍ជាសុខក្ដី ជាទុក្ខក្ដី មិនមែនជាទុក្ខ មិនមែនជាសុខក្ដី ហៅថា វេទនា, វេទនានេះមាន ៣ យ៉ាងគឺ ការទទួលដឹងនូវអារម្មណ៍ជាសុខ ដែលប្រព្រឹត្តទៅក្នុងកាយនឹងចិត្តហៅថា សុខ-វេទនា ១ ការទទួលដឹងនូវអារម្មណ៍ជាទុក្ខ ដែលប្រព្រឹត្តទៅក្នុងកាយនឹងចិត្ត ហៅថា ទុក្ខវេទនា ១ ការទទួលដឹងនូវអារម្មណ៍មិនមែនជាទុក្ខ មិនមែនជាសុខ ដែលប្រព្រឹត្តទៅក្នុងកាយនឹងចិត្ត ហៅថា ឧបេក្ខាវេទនា ១។

ភិក្ខុ កាលទទួលនូវវេទនាជាសុខ ដែលប្រកបដោយអាមិសៈ (១)

---

១. អាមិសៈ ក្នុងទីនេះប្រែថា នុយ, ចំណី, អាហារ គឺកាមគុណទាំង ៥ ហ្នឹងឯង ។

ក៏ដឹងច្បាស់ថា អាត្មាអញទទួលនូវវេទនាជាសុខ ដែលប្រកបដោយអាមិសៈ, ពោះទទួលនូវវេទនាជាសុខដែលមិនមានអាមិសៈ ក៏ដឹងច្បាស់ថា អាត្មាអញទទួលនូវវេទនាជាសុខ ដែលមិនមានអាមិសៈ ។

ពាក្យថា វេទនាជាសុខប្រកបដោយអាមិសៈនោះ បានដល់គេហសិតសោមនស្សវេទនា ៦ ដែលអាស្រ័យនូវផ្ទះគឺកាមគុណ ៥ ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ។ បុគ្គលណាបានឃើញរូបារម្មណ៍ដែលជាទីប្រាថ្នាជាទីត្រេកអរពេញចិត្តប្រកបដោយលោកាមិសៈ ឬរលឹកឃើញរូបារម្មណ៍ដែលខ្លួនធ្លាប់បានកប់ប្រសព្វពីក្នុងកាលមុននោះកន្លងទៅហើយ ។ សោមនស្សវេទនារបស់បុគ្គលនោះ ក៏កើតឡើងរីករាយបំពោះអារម្មណ៍នោះ ។ សោមនស្សវេទនាបែបនេះ ហៅថា គេហសិតសោមនស្សវេទនា អាស្រ័យនូវកាមគុណ ប្រព្រឹត្តទៅក្នុងចក្ខុទ្វារ (ចំណែកខាងគេហសិតសោមនស្សវេទនា អាស្រ័យនូវកាមគុណ ប្រព្រឹត្តទៅក្នុងទ្វារឯទៀត ៗ មានសោតទ្វារជាដើម គប្បីជ្រាបតាមន័យដែលបានពោលហើយក្នុងចក្ខុទ្វារនោះផងចុះ) ។

ពាក្យថា វេទនាជាសុខមិនមានអាមិសៈនោះ បានដល់នេក្ខម្មសិតសោមនស្សវេទនា ៦ ដែលមិនអាស្រ័យនូវកាមគុណ ៥ ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ។ បុគ្គលណា កាលដឹងថា រូបទាំងឡាយមិនទៀង មានការប្រែប្រួលជាធម្មតា ទាំងបានឃើញច្បាស់ដោយប្រាជ្ញា តាមសេចក្តី

ពិតយ៉ាងនេះថា រូបទាំងឡាយក្នុងកាលពីមុនក្តី ក្នុងកាលឥឡូវនេះក្តី រូបទាំងអស់នោះ សុទ្ធតែមិនទៀង ជាទុក្ខ មានការប្រែប្រួលទៅជាដូច្នេះ ឬជាដូច្នោះជាធម្មតា កាលបើឃើញយ៉ាងនេះហើយ សោមនស្សវេទនារបស់បុគ្គលនោះ ក៏កើតឡើងដោយសេចក្តីត្រេកអរក្នុងការចេញចាកកាមមិនពេញចិត្តក្នុងអារម្មណ៍ទាំងនោះ ហើយខ្វល់ខ្វាយរកឧបាយទីងគេចចេញចាកកាមគុណ ដើម្បីបំពេញនូវវិបស្សនា សោមនស្សវេទនាបែបនេះហៅថា នេក្ខម្មសិតសោមនស្សវេទនា មិនអាស្រ័យនូវកាមគុណ ប្រព្រឹត្តទៅក្នុងចក្ខុទ្វារ (បំណែកខាងនេក្ខម្មសិតសោមនស្សវេទនា មិនអាស្រ័យនូវកាមគុណ ប្រព្រឹត្តទៅក្នុងទ្វារឯទៀត ៗ មានសោតទ្វារជាដើម គប្បីជ្រាបតាមន័យដែលបានពោលហើយក្នុងចក្ខុទ្វារនោះផងចុះ) ។

កិក្ខុ ទោះទទួលនូវវេទនាជាទុក្ខប្រកបដោយអាមិសៈ ក៏ដឹងច្បាស់ថា អាត្មាអញទទួលនូវវេទនាជាទុក្ខប្រកបដោយអាមិសៈ ទោះទទួលនូវវេទនាជាទុក្ខមិនមានអាមិសៈ ក៏ដឹងច្បាស់ថា អាត្មាអញទទួលនូវវេទនាជាទុក្ខមិនមានអាមិសៈ ។

ពាក្យថា វេទនាជាទុក្ខប្រកបដោយអាមិសៈនោះ បានដល់គេហសិតទោមនស្សវេទនា ៦ ដែលអាស្រ័យនូវកាមគុណ ៥ ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ។ បុគ្គលណា បានឃើញអារម្មណ៍ទាំងឡាយ មានរូបជាដើមដោយចក្ខុទ្វារ ជាអារម្មណ៍ ជាទីស្រឡាញ់ពេញចិត្ត ប្រាថ្នាចង់បាននូវ

អារម្មណ៍ទាំងនោះ ហើយមិនបានសម្រេចដូចប្រាថ្នាក្តី បានសម្រេចហើយ ប៉ុន្តែដល់នូវសេចក្តីវិនាសព្រាត់ប្រាសទៅវិញ ដោយហេតុណាមួយក្តី ទោមនស្ស គឺសេចក្តីអាក់អន់តូចចិត្តក៏កើតឡើង ព្រោះហេតុតែមិនបានដូចបំណងនោះជាបច្ច័យ ទោមនស្សបែបនេះ ហៅថា គេហសិតទោមនស្សវេទនាអាស្រ័យនូវកាមគុណ ប្រព្រឹត្តទៅក្នុងចក្ខុទ្វារ (ចំណែកខាងគេហសិតទោមនស្សវេទនា ដែលអាស្រ័យនូវកាមគុណ ប្រព្រឹត្តទៅក្នុងទ្វារឯទៀត ១ មានសោតទ្វារជាដើម គប្បីជ្រាបតាមន័យដែលបានពោលហើយក្នុងចក្ខុទ្វារនោះផងចុះ) ។

ពាក្យថា វេទនាជាទុក្ខមិនមានអាមិសៈនោះ បានដល់នេក្ខម្មសិតទោមនស្សវេទនា ដែលមិនអាស្រ័យនូវកាមគុណ ៥ ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ។ បុគ្គលណា បានដឹងថា រូបទាំងឡាយ ជារបស់មិនទៀង មានការប្រែប្រួលជាធម្មតា ទាំងបានឃើញច្បាស់ដោយប្រាជ្ញាតាមសេចក្តីពិតផង យ៉ាងនេះថា រូបទាំងឡាយក្នុងកាលពីមុនក្តី ក្នុងកាលឥឡូវនេះក្តី រូបទាំងអស់នោះ សុទ្ធតែមិនទៀងជាទុក្ខ មានការប្រែប្រួលទៅជាដូច្នេះ ឬជាដូច្នោះជាធម្មតា លុះឃើញទោសក្នុងរូបារម្មណ៍ជាដើមដូច្នេះហើយ ក៏នឿយណាយក្នុងកាម ឃើញទោសក្នុងកាមមានប្រការផ្សេង ១ អាស្រ័យនូវនេក្ខម្មៈ ប្រាថ្នានឹងចៀសចេញចាកកាម មានសេចក្តីស្រឡាញ់ពេញចិត្តក្នុងវិមោក្ខធម៌ គឺនិព្វាន ទោមនស្សរបស់បុគ្គលនោះ កើតឡើងដោយ

គិតឃើញថា អាត្មាអញមិនទាន់បានខ្វល់ខ្វាយប្រារព្ធធ្វើនូវវិបស្សនាណាមួយ ដោយអំណាចនៃលក្ខណៈមានអនិច្ចលក្ខណៈជាដើមសោះទេ ឬបានខ្វល់ខ្វាយធ្វើវិបស្សនាអស់កន្លះខែ ឬអស់មួយខែ ឬក៏អស់មួយឆ្នាំដែរ ប៉ុន្តែមិនអាចបានដល់នូវអរិយភូមិ ទោមនស្សបែបនេះ ហៅថា នេក្ខម្មសិត-ទោមនស្សវេទនា មិនអាស្រ័យនូវកាមគុណ ប្រព្រឹត្តទៅក្នុងចក្ខុទ្វារ (ចំណែកខាងនេក្ខម្មសិតទោមនស្សវេទនា ដែលមិនអាស្រ័យនូវកាមគុណ ប្រព្រឹត្តទៅក្នុងទ្វារឯទៀត ៗ មានសោតទ្វារជាដើម គប្បីជ្រាបតាមន័យដែលបានពោលហើយក្នុងចក្ខុទ្វារនោះផងចុះ) ។

ភិក្ខុ កាលទទួលនូវវេទនាមិនមែនជាទុក្ខ មិនមែនជាសុខ ប្រកបដោយអាមិសៈ ក៏ដឹងច្បាស់ថា អាត្មាអញ ទទួលនូវវេទនាមិនមែនជាទុក្ខ មិនមែនជាសុខ ប្រកបដោយអាមិសៈ. កាលទទួលនូវវេទនាមិនមែនជាទុក្ខ មិនមែនជាសុខដែលមិនមានអាមិសៈ ក៏ដឹងច្បាស់ថា អាត្មាអញ ទទួលនូវវេទនាមិនមែនជាទុក្ខ មិនមែនជាសុខ ដែលមិនមានអាមិសៈ ។

ពាក្យថា វេទនាមិនមែនជាទុក្ខ មិនមែនជាសុខ ប្រកបដោយអាមិសៈនោះ បានដល់គេហសិតឧបេក្ខា ដែលអាស្រ័យនូវកាមគុណ ៥ ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ។ ឧបេក្ខាដែលកើតឡើងដល់ពាលបុថុជ្ជនជាអ្នកល្ងង់ខ្លៅ ស្ទើរតែឃើញរូបដោយចក្ខុហើយ ក៏ជាអ្នកមិនស្ទូវនេះនោត ឬលោភក្នុងរូបនោះប៉ុន្មានឡើយ សម្តែងអាការបែបដើយព្រងើយ ។

ប៉ុន្តែមិនមែនជាអ្នកឃើញទោសក្នុងរូបនោះជាប្រក្រតីទេ ឧបេក្ខាបែបនេះ មិនកន្លងនូវរូបបានឡើយ ព្រោះហេតុនោះ ឧបេក្ខានោះឯង លោក ហៅថា ឧបេក្ខាអាស្រ័យនូវកាមគុណមិនកន្លងនូវអារម្មណ៍ទាំងឡាយ មាន រូបជាដើមបានទេ ជាឧបេក្ខាកើតឡើងជាប់ស្អិតត្រាំនៅក្នុងរូបារម្មណ៍ជា ដើម ប្រហែលទឹករុយដែលទំសម្ងំនៅក្នុងដុំនៃស្ករដូច្នោះឯង (ឯគេហសិត- ឧបេក្ខា អាស្រ័យនូវកាមគុណ ប្រព្រឹត្តទៅក្នុងទ្វារឯទៀត ៗ មានសោតទ្វារ ជាដើម គប្បីជ្រាបតាមន័យដែលបានពោលហើយក្នុងចក្ខុទ្វារនោះផងចុះ)ៗ

ពាក្យថា វេទនាមិនមែនជាទុក្ខ មិនមែនជាសុខ ដែលមិនមានអាមិសៈ នោះ បានដល់នេក្ខម្មសិតឧបេក្ខា, ដែលហៅថានេក្ខម្មសិតឧបេក្ខា ប្រែថា ឧបេក្ខាអាស្រ័យនូវនេក្ខម្មៈ (ការចេញចាកកាម) ឬថាមិនអាស្រ័យនូវ កាមគុណ ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ។ ឧបេក្ខារបស់បុគ្គលណាដែល បានដឹងថា រូបទាំងឡាយមិនទៀង មានការប្រែប្រួលជាធម្មតា ទាំងបាន ឃើញច្បាស់ដោយប្រាជ្ញាតាមសេចក្ដីពិតផង យ៉ាងនេះថា រូបទាំងឡាយ ក្នុងកាលពីមុនក្ដី ក្នុងកាលឥឡូវនេះក្ដី រូបទាំងអស់នោះ សុទ្ធតែមិនទៀង ជាទុក្ខ មានការប្រែប្រួលទៅជាដូច្នេះ ឬជាដូច្នោះជាធម្មតា សូម្បីអារម្មណ៍ ទាំងឡាយមានឥដ្ឋារម្មណ៍ជាដើម មកប្រាកដក្នុងចក្ខុទ្វារ ក៏សម្ដែងអាការ ហាក់ដូចជាដើយព្រងើយ ។ ប៉ុន្តែឧបេក្ខានេះមិនទាន់កន្លងនូវរូបបានទេ ព្រោះហេតុនោះ ឧបេក្ខានោះឯង លោកហៅថា នេក្ខម្មសិតឧបេក្ខា ជា

ឧបេក្ខាសម្បយុត្តដោយវិបស្សនាញាណ ដែលកើតឡើងមិនរីករាយក្នុងឥដ្ឋារម្មណ៍ មិនប្រទូស្តក្នុងអនិដ្ឋារម្មណ៍ មិនវង្វេងភ្លេចស្មារតី ព្រោះតែមិនបានពិចារណាឡើយ (ឯនេក្ខម្មសិតឧបេក្ខា ដែលមិនអាស្រ័យនូវកាមគុណប្រព្រឹត្តទៅក្នុងទ្វារឯទៀត ៗ មានសោតទ្វារជាដើម គប្បីជ្រាបតាមន័យដែលបានពោលហើយក្នុងចក្ខុទ្វារនោះផងចុះ) ។

លំដាប់តមក ភិក្ខុនោះពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយជាខាងក្នុង គឺវេទនារបស់ខ្លួន ទាំងពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ ជាខាងក្រៅ គឺវេទនារបស់អ្នកដទៃ; ឈ្មោះថាពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ ទាំងខាងក្នុង ទាំងខាងក្រៅ ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើង[១]ក្នុងវេទនាទាំងឡាយ ទាំងពិចារណាឃើញនូវធម៌ដែលសូន្យទៅ[២]ក្នុងវេទនាទាំងឡាយ ឈ្មោះថាពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងវេទនាទាំងឡាយ ។ ម្យ៉ាងទៀត ស្មារតីរបស់ភិក្ខុនោះ ក៏តាំងឡើងប្រាកដថា វេទនាទាំងឡាយនេះ គ្រាន់តែជាវេទនាប៉ុណ្ណោះឯង មិនមែនសត្វ មិនមែនបុគ្គល មិនមែនស្ត្រី មិនមែនបុរសទេ ការពិចារណាឃើញដូច្នេះ កំណត់ដើម្បីឲ្យចំរើនប្រាជ្ញា ឲ្យចំរើនស្មារតីប៉ុណ្ណោះ ដោយអំណាចនៃការពិចា-

---

១-២ សេចក្តីនេះ បានអធិប្បាយក្នុងអានាបានបព្វៈ ខាងកាយានុបស្សនាសតិបដ្ឋានរួចហើយ គ្រាន់តែផ្លាស់ពាក្យថាកាយ មកជាវេទនាប៉ុណ្ណោះ ។

ណា ឃើញដូច្នេះ ចិត្តរបស់ភិក្ខុនោះសោត ក៏មិនជាប់ជំពាក់ មិនអាស្រ័យនៅដោយតណ្ហានិងទិដ្ឋិផង ទាំងមិនមានសេចក្ដីប្រកៀកប្រកាន់នូវអ្វីនីមួយ ក្នុងលោកផង ។

សេចក្ដីដែលសម្ដែងមកនេះ ហៅថា ភិក្ខុ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ ។

វេទនានុបស្សនាសតិបដ្ឋាន ចប់ ។

# ចិត្តានុបស្សនាសតិបដ្ឋាន

ភិក្ខុ ពិចារណាឃើញនូវចិត្តក្នុងចិត្ត តើដូចម្ដេច ? ភិក្ខុ ពិចារណាឃើញ ទោះចិត្តប្រកបដោយរាគៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ, ទោះចិត្តប្រាសចាករាគៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ ។

រាគៈ ប្រែថា តម្រេកត្រេកត្រអាល, សេចក្ដីរីករាយក្នុងអារម្មណ៍, ចិត្តប្រកបដោយរាគៈ បានដល់ចិត្តដែលប្រកបដោយលោភមូល ៨ ។ ចិត្តប្រាសចាករាគៈ បានដល់លោកិយកុសលចិត្ត ៨ និងអព្យាកតចិត្ត ៣៤ ។

ភិក្ខុ ពិចារណាឃើញ ទោះចិត្តប្រកបដោយទោសៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ, ទោះចិត្តប្រាសចាកទោសៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈ ។

ទោសៈ ប្រែថា សេចក្ដីអាក់អន់ចិត្ត, សេចក្ដីទ្រុស្តក្នុងអារម្មណ៍, ចិត្តប្រកបដោយទោសៈ បានដល់ចិត្តដែលប្រកបដោយទោសមូល ២ ។

ចិត្តប្រាសចាកទោសៈ បានដល់លោកិយកុសលចិត្ត ៨ នឹងអព្យាកតចិត្ត ៣៤ ។

ភិក្ខុ ពិចារណាឃើញ នោះចិត្តប្រកបដោយមោហៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ, នោះចិត្តប្រាសចាកមោហៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈ ។

មោហៈ ប្រែថា សេចក្តីល្ងង់, សេចក្តីវង្វេងក្នុងអារម្មណ៍, ចិត្តប្រកបដោយមោហៈ បានដល់ចិត្តដែលប្រកបដោយមោហមូល ២ ។ ចិត្តប្រាសចាកមោហៈ បានដល់លោកិយកុសលចិត្ត ៨ នឹងអព្យាកតចិត្ត ៣៤ ។

ភិក្ខុ ពិចារណាឃើញ នោះចិត្តរួញរា ក៏ដឹងច្បាស់ថា ចិត្តរួញរា, នោះចិត្តរាយមាយ ក៏ដឹងច្បាស់ថា ចិត្តរាយមាយ ។

ចិត្តរួញរា បានដល់ចិត្តដែលធ្លាក់ចុះរឿយ ៗ ក្នុងថីនមិទ្ធៈ គឺចិត្តដែលរួញរាធុញថប់ ឬសេចក្តីច្រអូសកាយច្រអូសចិត្ត ក្នុងកិច្ចការជាកុសលផ្សេង ៗ ។ ចិត្តរាយមាយ បានដល់ចិត្តដែលប្រកបដោយឧទ្ធច្ចៈ គឺចិត្តដែលរាយមាយទាសទៅអណ្តែតអណ្តូងទៅក្នុងអារម្មណ៍ផ្សេង ៗ ដែលឥតប្រយោជន៍ ។

ភិក្ខុ ពិចារណាឃើញ នោះចិត្តដល់នូវភាពជាធំ ក៏ដឹងច្បាស់ថា ចិត្តដល់នូវភាពជាធំ, នោះចិត្តមិនទាន់ដល់នូវភាពជាធំ ក៏ដឹងច្បាស់ថា ចិត្តមិនទាន់ដល់នូវភាពជាធំ ។

ចិត្តដល់នូវភាពជាធំ បានដល់រូបាវចរចិត្តនឹងអរូបាវចរចិត្ត ព្រោះចិត្តនេះប្រាសចាកនីវរណធម៌ ៥ ឬថាព្រោះចិត្តនេះជាដំណើរនៃយោគាវចរអ្នកចំរើនឈានតែងប្រព្រឹត្ត ។ ចិត្តដែលមិនទាន់ដល់នូវភាពជា បានដល់កាមាវចរចិត្ត ។

ភិក្ខុ ពិចារណាឃើញ ទោះចិត្តនៅមានចិត្តដទៃប្រសើរជាង ក៏ដឹងច្បាស់ថា ចិត្តនៅមានចិត្តដទៃប្រសើរជាង, ទោះចិត្តមិនមានចិត្តដទៃប្រសើរជាង ក៏ដឹងច្បាស់ថា ចិត្តមិនមានចិត្តដទៃប្រសើរជាង ។

ចិត្តនៅមានចិត្តដទៃប្រសើរជាង បានដល់កាមាវចរចិត្ត, ចិត្តមិនមានចិត្តដទៃប្រសើរជាង បានដល់រូបាវចរចិត្តនឹងអរូបាវចរចិត្ត ។ ម្យ៉ាងទៀត សឧត្តរៈ បានដល់រូបាវចរចិត្ត, អនុត្តរៈ បានដល់អរូបាវចរចិត្តតែម្យ៉ាង ប៉ុន្តែក្នុងទីដទៃពីនេះ អនុត្តរៈ សំដៅយកលោកុត្តរចិត្ត ។

ភិក្ខុ ពិចារណាឃើញ ទោះចិត្តដំកល់នៅមាំ ក៏ដឹងច្បាស់ថា ចិត្តដំកល់នៅមាំ, ទោះចិត្តមិនទាន់ដំកល់នៅមាំ ក៏ដឹងច្បាស់ថា ចិត្តមិនទាន់ដំកល់នៅមាំ ។

ចិត្តដំកល់នៅមាំ បានដល់ចិត្តដែលប្រព្រឹត្តទៅក្នុងឧបចារសមាធិនឹងអប្បនាសមាធិ ។ ចិត្តមិនទាន់ដំកល់នៅមាំ បានដល់ចិត្តដែលប្រាសចាកឧបចារសមាធិ នឹងអប្បនាសមាធិ ។

ភិក្ខុ ពិចារណាឃើញ ទោះចិត្តផុតស្រឡះ ក៏ដឹងច្បាស់ថា ចិត្តផុត

ស្រឡះ, ទោះចិត្តមិនទាន់ផុតស្រឡះ ក៏ដឹងច្បាស់ថា ចិត្តមិនទាន់ផុតស្រឡះ ។

ចិត្តផុតស្រឡះ បានដល់ចិត្តដែលផុតស្រឡះចាកសញ្ញា មាននិច្ចសញ្ញាជាដើម ដោយតទង្គវិមុត្តិ គឺអនុបស្សនាទាំង ៧ មានអនិច្ចានុបស្សនាជាដើម នឹងចិត្តដែលផុតស្រឡះចាកនីវរណធម៌ ៥ ដោយវិក្ខម្ភនវិមុត្តិ គឺសមាបត្តិ ៨ ។ ចិត្តមិនទាន់ផុតស្រឡះ បានដល់ចិត្តដែលប្រាសចាកតទង្គវិមុត្តិ នឹងវិក្ខម្ភនវិមុត្តិ ។

តមក ភិក្ខុនោះ ពិចារណាឃើញនូវចិត្តក្នុងចិត្តជាខាងក្នុង គឺចិត្តរបស់ខ្លួនផង ពិចារណាឃើញនូវចិត្តក្នុងចិត្តជាខាងក្រៅ គឺចិត្តរបស់អ្នកដទៃផង ឈ្មោះថាពិចារណាឃើញនូវចិត្តក្នុងចិត្តទាំងខាងក្នុងទាំងខាងក្រៅ ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើង(១)ក្នុងចិត្តផង ពិចារណាឃើញនូវធម៌ដែលសូន្យ(២)ទៅក្នុងចិត្តផង ឈ្មោះថាពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងចិត្ត ។ ម្យ៉ាងទៀត ស្មារតីរបស់ភិក្ខុនោះ ក៏តាំងឡើងប្រាកដថា ចិត្តនេះ គ្រាន់តែជាចិត្តប៉ុណ្ណោះឯង មិនមែនសត្វ មិនមែនបុគ្គល មិនមែនស្ត្រី មិនមែនបុរសទេ កំណត់ដើម្បីឲ្យចំរើនប្រាជ្ញា ឲ្យមានស្មារតីរឹងប៉ឹងប៉ុណ្ណោះ ដោយអំណាចនៃការពិចារណាឃើញដូច្នេះ ចិត្តរបស់ភិក្ខុនោះ ក៏មិនជាប់ជំពាក់ មិនអាស្រ័យនៅ

---

១ - ២ សេចក្តីនេះ បានអធិប្បាយក្នុងអានាបានបព្វៈខាងកាយានុបស្សនាសតិបដ្ឋានរួចហើយ គ្រាន់តែផ្លាស់ពាក្យថា កាយ មកជាចិត្ត ប៉ុណ្ណោះ ។

ដោយតណ្ហានឹងទិដ្ឋិផង ទាំងមិនមានសេចក្ដីប្រកៀកប្រកាន់នូវអ្វីទីមួយ គិចតួចក្នុងលោកផង ។

សេចក្ដីដែលពោលមកនេះឯង ហៅថា ភិក្ខុពិចារណាឃើញនូវចិត្ត ក្នុងចិត្ត ។

ចិត្តានុបស្សនាសតិបដ្ឋាន ចប់ ។

# ធម្មានុបស្សនាសតិបដ្ឋាន

## នីវរណបព្វៈ

សង្កាត់នៃការពិចារណានូវធម៌ គឺនីវរណៈ

ភិក្ខុ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ តើដូចម្ដេច ? ភិក្ខុ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺនីវរណៈ៥ ។ ភិក្ខុ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺនីវរណៈ៥ នោះ តើដូចម្ដេចខ្លះ ភិក្ខុ ពិចារណាឃើញ ទោះកាមច្ឆន្ទៈមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា កាមច្ឆន្ទៈមាននៅក្នុងខ្លួនរបស់អាត្មាអញ, ទោះកាមច្ឆន្ទៈមិនមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា កាមច្ឆន្ទៈមិនមាននៅក្នុងខ្លួនរបស់អាត្មាអញ ម្យ៉ាងទៀត កាមច្ឆន្ទៈដែលមិនទាន់កើត ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កាមច្ឆន្ទៈដែលកើតឡើងហើយ អាចលះបង់បានដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កាមច្ឆន្ទៈ

ដែលលះបង់បានហើយ មិនអាចកើតតទៅទៀតដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

អធិប្បាយ ចំណង់ក្នុងកាម ឬចំណង់ដែលកើតឡើងដោយអំណាចនៃកាម ហៅថា កាមច្ឆន្ទៈ. ហេតុដែលនាំឲ្យកាមច្ឆន្ទៈកើតឡើងគឺ ដោយបណ្ដាយឲ្យមានអយោនិសោមនសិការៈក្នុងសុភនិមិត្ត ។ ការតាំងចិត្តកំណត់នូវអារម្មណ៍ថាល្អ ថាស្អាត ហៅថា សុភនិមិត្ត, ការមិនធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញាក្នុងរបស់ដែលមិនទៀងថាទៀង, របស់ដែលជាទុក្ខ ថាសុខ, របស់ដែលមិនមែនខ្លួន ថាខ្លួន, របស់ដែលមិនស្អាតថាស្អាត ហៅថា អយោនិសោមនសិការៈ ព្រោះហេតុនោះ បានជាព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការមិនធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញាក្នុងសុភនិមិត្តនេះ ជាអាហារនាំកាមច្ឆន្ទៈដែលមិនទាន់កើតឲ្យកើតឡើង កាមច្ឆន្ទៈដែលកើតឡើងហើយ ក៏រឹងរឹតតែបំរើនជាកិយ្យោភាពឡើងទៀត ។

ចំណែកខាងការលះនូវកាមច្ឆន្ទៈនោះ ត្រូវឲ្យមានយោនិសោមនសិ-ការៈក្នុងអសុភនិមិត្ត, ការតាំងចិត្តកំណត់នូវអារម្មណ៍ថាមិនល្អ មិនស្អាត ហៅថា អសុភនិមិត្ត, ការធ្វើទុកក្នុងចិត្តដោយមានឧបាយប្រាជ្ញាក្នុងរបស់ដែលមិនទៀង ថាមិនទៀងជាដើម ហៅថា យោនិសោមនសិការៈ ហេតុនោះបានជាព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការធ្វើ

ទុកក្នុងចិត្តដោយមានឧបាយប្រាជ្ញាក្នុងអសុភនិមិត្តនេះ ជាអាហារនាំកាមច្ឆន្ទៈដែលមិនទាន់កើតមិនឲ្យកើតឡើងបាន បើទុកជាកើតឡើងហើយ ក៏អាចលះបង់បាន ។

ម្យ៉ាងទៀត ធម៌ដែលប្រព្រឹត្តទៅដើម្បីលះនូវកាមច្ឆន្ទៈបានដែរ មាន ៦ យ៉ាងគឺ ១- អសុភនិមិត្តឧគ្គហៈ ការរៀននូវអសុភនិមិត្ត ២- អសុភភាវនានុយោគៈ ការប្រកបព្យាយាមរឿយ ៗ ក្នុងអសុភភាវនា ៣- ឥន្ទ្រិយេសុ គុត្តទ្វារតា ភាពជាអ្នកមានទ្វារគ្រប់គ្រងល្អក្នុងឥន្ទ្រិយទាំងឡាយ ៤- ភោជនេ មត្តញ្ញុតា ភាពជាអ្នកដឹងប្រមាណក្នុងភោជន ៥- កល្យាណមិត្តតា ភាពជាអ្នកមានមិត្តល្អ ៦- សប្បាយកថា និយាយ ឬស្តាប់នូវពាក្យដែលនាំឲ្យសប្បាយ ។ កាមច្ឆន្ទៈដែលលះបង់ដោយធម៌ទាំង ៦ យ៉ាងនេះបានហើយ ៗ មិនឲ្យកើតតទៅទៀតបាន ដោយអរហត្តមគ្គ ។

ភិក្ខុ ពិចារណាឃើញ នោះព្យាបាទមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថាព្យាបាទមាននៅក្នុងខ្លួនរបស់អាត្មាអញ, នោះព្យាបាទមិនមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា ព្យាបាទមិនមាននៅក្នុងខ្លួនរបស់អាត្មាអញ ។ ម្យ៉ាងទៀត ព្យាបាទដែលមិនទាន់កើតឡើង ហើយកើតឡើងបានដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ព្យាបាទដែលកើតឡើងហើយ អាចលះបង់បានដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ព្យាបាទដែល

លះបង់បានហើយ មិនអាចឲ្យកើតតទៅទៀតបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

អធិប្បាយ ធម៌ដែលញុំាងប្រយោជន៍ នឹងសេចក្ដីសុខរបស់អ្នកដទៃឲ្យវិនាស ហៅថា ព្យាបាទ, ហេតុដែលនាំឲ្យព្យាបាទកើតឡើងគឺ ធ្វើទុកក្នុងចិត្តដោយគ្មានឧបាយប្រាជ្ញប្រព្រឹត្តទៅក្នុងបដិឃនិមិត្ត ។ សេចក្ដីថាំងថាក់ចិត្តក្ដី អារម្មណ៍ណាមួយដែលនាំចិត្តឲ្យកើតសេចក្ដីថាំងថាក់ក្ដី ហៅថា បដិឃនិមិត្ត ព្រោះហេតុនោះ បានជាព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការធ្វើទុកក្នុងចិត្តដោយគ្មានឧបាយប្រាជ្ញក្នុងបដិឃនិមិត្តនេះឯង ជាអាហារនាំព្យាបាទដែលមិនទាន់កើតឲ្យកើតឡើង ព្យាបាទដែលកើតឡើងហើយ ក៏រឹងរឹតតែកើតចំរើនជាភិយ្យោភាពឡើងទៀត ។ ចំណែកខាងការលះបង់នូវព្យាបាទនោះ ដោយធ្វើទុកក្នុងចិត្តដោយមានឧបាយប្រាជ្ញប្រព្រឹត្តទៅក្នុងមេត្តាចេតោវិមុត្តិ ។

ម្យ៉ាងទៀត ធម៌ ៦ យ៉ាង ប្រព្រឹត្តទៅក្នុងការលះបង់នូវព្យាបាទបានដែរគឺ ១– មេត្តានិមិត្តឧគ្គហៈ ការរៀននូវមេត្តានិមិត្ត ២– មេត្តាភាវនានុយោគៈ ការប្រកបព្យាយាមរឿយ ៗ ក្នុងមេត្តាភាវនា ៣– កម្មស្សកតាបច្ចវេក្ខណា ការពិចារណានូវភាពដែលសត្វមានកម្មជារបស់ខ្លួន ៤– បដិសង្ខានពហុលីកតា ភាពជាអ្នកច្រើនដោយការពិចារណា ៥– កល្យាណមិត្តតា ភាព

ជាអ្នកមានមិត្តល្អ ៦- សប្បាយកថា និយាយឬស្តាប់នូវពាក្យដែលនាំឲ្យមានសេចក្តីសប្បាយ ។ បំណែកខាងព្យាបាទដែលលះបង់ដោយធម៌តាំង ៦ យ៉ាងនេះបានហើយ ។ មិនឲ្យកើតតទៅទៀតបានដោយអនាគាមិមគ្គ ។

ភិក្ខុ ពិចារណាឃើញ ទោះថីនមិទ្ធៈមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា ថីនមិទ្ធៈមាននៅក្នុងខ្លួនរបស់អាត្មាអញ, ទោះថីនមិទ្ធៈមិនមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា ថីនមិទ្ធៈមិនមាននៅក្នុងខ្លួនរបស់អាត្មាអញ ។ ម្យ៉ាងទៀត ថីនមិទ្ធៈដែលមិនទាន់កើតឡើង ហើយកើតឡើងបានដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ថីនមិទ្ធៈដែលកើតឡើងហើយ អាចលះបង់បានដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ថីនមិទ្ធៈដែលលះបង់បានហើយ មិនអាចឲ្យកើតតទៅទៀតបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

អធិប្បាយ ចិត្តដែលខ្ជិលច្រអូសនាំឲ្យធុញ នឹងចិត្តដែលច្រអូសក្ងុស ។ មិនប្រាកដជាគិតអ្វីមួយ ហៅថា ថីនមិទ្ធៈ ។ ហេតុដែលនាំឲ្យថីនមិទ្ធៈកើតឡើងគឺ ដោយធ្វើទុកក្នុងចិត្តដោយគ្មានឧបាយប្រាជ្ញប្រព្រឹត្តទៅក្នុងធម៌ ៥ គឺ អរតិ សេចក្តីមិនពេញចិត្ត ១ តន្ទិ សេចក្តីបំអៀកទម្រន់ ១ វិជម្ភិតា ការមិតពត់ ១ ភត្តសម្មទៈ សេចក្តីស្រវឹងក្នុងភត្ត ១ ចេតសោលីនត្តៈ ភាពនៃចិត្តដែលប្រអូសរួញរា ១ ។ ការធ្វើទុក

ក្នុងចិត្តដោយគ្មានឧបាយប្រាជ្ញាប្រព្រឹត្តទៅក្នុងធម៌ទាំង ៤ យ៉ាងនេះឯង ជាអាហារនាំថីនមិទ្ធៈដែលមិនទាន់កើតឲ្យកើតឡើង ថីនមិទ្ធៈដែលកើតឡើងហើយ ក៏រឹងរឹតតែកើតចំរើនជាភិយ្យោភាពឡើងទៀត ៗ បំណែកខាងការលះបង់នូវថីនមិទ្ធៈនោះ ដោយធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញាប្រកបដោយព្យាយាម ៣ យ៉ាងគឺ អារកធាតុ ព្យាយាមប្រារព្ធឡើងជាដំបូង១ និក្កមធាតុ ព្យាយាមយ៉ាងកណ្តាលដើម្បីចេញចាកកោសជ្ជៈ (សេចក្តីខ្ជិលច្រអូស)១ បរក្កមធាតុ ព្យាយាមយ៉ាងក្រៃលែងដើម្បីឈានកន្លងឲ្យរួចផុតចាកកោសជ្ជៈ ១ ៗ ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញាក្នុងព្យាយាម ៣ យ៉ាងនេះឯង ជាអាហារនាំថីនមិទ្ធៈដែលមិនទាន់កើតមិនឲ្យកើតឡើងបាន បើទុកជាកើតឡើងហើយ ក៏អាចលះបង់បាន ៗ

ម្យ៉ាងទៀត ធម៌ ៦ យ៉ាងប្រព្រឹត្តទៅក្នុងការលះបង់នូវថីនមិទ្ធៈបានដែរគឺ ១– អតិភោជនេ និមិត្តគ្គាហោ: កាន់យកនូវនិមិត្តក្នុងការបរិភោគនូវភោជនកន្លងប្រមាណ ២– ឥរិយាបថបរិវត្តនតា ភាពនៃការផ្លាស់ប្តូរនូវឥរិយាបថ ៣– អាលោកសញ្ញាមនសិការៈ ធ្វើទុកក្នុងចិត្តនូវអាលោកសញ្ញា ៤– អព្ភោកាសវាសៈ នៅក្នុងឱកាសដែលស្រឡះ ៥– កល្យាណមិត្តតា ភាពជាអ្នកមានមិត្តល្អ ៦– សប្បាយកថា និយាយ ឬស្តាប់នូវពាក្យដែលនាំឲ្យមានសេចក្តីសប្បាយ ៗ ថីនមិទ្ធៈដែលលះបង់ដោយធម៌ទាំង ៦ យ៉ាងនេះបាន

ហើយ ៗ មិនអាចកើតតទៅទៀតបាន ដោយអរហត្តមគ្គ ។

ភិក្ខុ ពិចារណាឃើញ ទោះឧទ្ធច្ចកុក្កុច្ចៈមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈមាននៅក្នុងខ្លួនរបស់អាត្មាអញ, ទោះឧទ្ធច្ចកុក្កុច្ចៈមិនមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈមិនមាននៅក្នុងខ្លួនរបស់អាត្មាអញ ។ មួយវិញទៀត ឧទ្ធច្ចកុក្កុច្ចៈដែលមិនទាន់កើតឡើង ហើយកើតឡើងបានដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើងហើយ អាចលះបង់បានដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ឧទ្ធច្ចកុក្កុច្ចៈដែលលះបង់បានហើយ មិនអាចកើតតទៅទៀតបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

អធិប្បាយ ភាពនៃចិត្តដែលរាយមាយអណ្តែតអណ្តូងទៅក្នុងអារម្មណ៍ផ្សេង ៗ នឹងភាពនៃចិត្តដែលក្តៅក្រហាយ ឬសង្ស័យក្នុងអំពើអាក្រក់ណាមួយដែលធ្លាប់ធ្វើមកហើយ ហៅថា ឧទ្ធច្ចកុក្កុច្ចៈ ។ ហេតុដែលនាំឲ្យឧទ្ធច្ចកុក្កុច្ចៈកើតឡើងគឺ ដោយធ្វើទុកក្នុងចិត្តដោយគ្មានឧបាយប្រាជ្ញាប្រព្រឹត្តទៅក្នុងចេតសោអវូបសមៈ (ការមិនធ្វើចិត្តឲ្យស្ងប់) ការមិនធ្វើចិត្តឲ្យស្ងប់ដោយគ្មានឧបាយប្រាជ្ញានេះឯង ជាអាហារនាំឧទ្ធច្ចកុក្កុច្ចៈដែលមិនទាន់កើតឲ្យកើតឡើង ដែលកើតឡើងហើយ ក៏រឹងរឹតតែកើតចំរើនជាភិយ្យោភាពឡើងទៀត ។ ចំណែកខាងការលះបង់នូវឧទ្ធច្ចកុក្កុច្ចៈនោះដោយធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញាប្រព្រឹត្តទៅក្នុងចេតសោវូបសម

(ការធ្វើចិត្តឲ្យស្ងប់) ពោលគឺសមាធិ ។ ព្រោះហេតុនោះបានជា ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ក្នុងធម៌ជាគ្រឿងធ្វើចិត្តឲ្យស្ងប់ដោយអំណាចសមាធិនេះឯង ជាហេតុនាំឲ្យឧទ្ធច្ចកុក្កុច្ចៈដែលមិនទាន់កើត មិនឲ្យកើតឡើងបាន ដែលកើតឡើងហើយ ក៏អាចលះបង់បាន ។

ម្យ៉ាងទៀត ធម៌ ៦ យ៉ាងប្រព្រឹត្តទៅក្នុងការលះបង់នូវឧទ្ធច្ចកុក្កុច្ចៈបាន ដែរគឺ ១– ពហុស្សុតតា ភាពជាអ្នករៀនសូត្រចេះដឹងច្រើន- ២– បរិបុច្ឆកតា ភាពជាអ្នកខ្សឹបខ្សាក់សាកសួរនូវហេតុដែលគួរនឹងមិនគួរ ៣– វិនយេ បកតញ្ញុតា ភាពជាអ្នកស្គាល់ខុសត្រូវក្នុងវិនយបញ្ញត្តិ ៤– វុឌ្ឍសេវិតា ភាពជាអ្នកសេពគប់នូវព្រះថេរៈដែលចាស់ទុំ ៥– កល្យាណមិត្តតា ភាពជាអ្នកសេពគប់នូវមិត្តល្អ ៦– សប្បាយកថា និយាយឬស្តាប់នូវពាក្យដែលនាំឲ្យមានសេចក្ដីសប្បាយ ។ ឧទ្ធច្ចកុក្កុច្ចៈដែលលះបង់ដោយធម៌ទាំង ៦ យ៉ាងនេះបានហើយ ។ មិនអាចកើតតទៅទៀតបាននោះគឺ ឧទ្ធច្ចៈកើតតទៅទៀតមិនបានដោយអរហត្តមគ្គ ឯកុក្កុច្ចៈកើតតទៅទៀតមិនបានដោយអនាគាមិមគ្គ ។

ភិក្ខុ ពិចារណាឃើញ ពោះវិចិកិច្ឆាមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា វិចិកិច្ឆាមាននៅក្នុងខ្លួនរបស់អាត្មាអញ, ពោះវិចិកិច្ឆាមិនមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា វិចិកិច្ឆាមិនមាននៅក្នុងខ្លួនរបស់អាត្មាអញ ។ ម្យ៉ាងទៀត

វិចិកិច្ឆាដែលមិនទាន់កើត ហើយកើតឡើងបានដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង វិចិកិច្ឆាដែលកើតឡើងហើយ អាចលះបង់បានដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង វិចិកិច្ឆាដែលលះបង់បានហើយ មិនអាចកើតតទៅទៀតបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

អធិប្បាយ សេចក្ដីសង្ស័យស្នាក់ស្ទើរមិនដាច់ស្រេច មិនចុះសម្រុងមូលទៅខាងណា ៗ បាន ហៅថា វិចិកិច្ឆា ។ ហេតុដែលនាំវិចិកិច្ឆាឲ្យកើតឡើងគឺ ដោយធ្វើទុកក្នុងចិត្តដោយគ្មានឧបាយប្រាជ្ញាក្នុងពួកធម៌ដែលជាទីតាំងនៃសេចក្ដីសង្ស័យ ។ ដែលហៅថាពួកធម៌ជាទីតាំងនៃសេចក្ដីសង្ស័យនោះ បានដល់វិចិកិច្ឆាហ្នឹងឯង ព្រោះហេតុនោះបានជាព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការមិនធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញាក្នុងពួកធម៌ដែលជាទីតាំងនៃសេចក្ដីសង្ស័យនេះឯង ជាអាហារនាំវិចិកិច្ឆាដែលមិនទាន់កើតឲ្យកើតឡើង ដែលកើតឡើងហើយ ក៏រឹងរឹតតែកើតចំរើនជាភិយ្យោភាពឡើងទៀត ។ ចំណែកខាងការលះបង់នូវវិចិកិច្ឆានោះ ដោយធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញាក្នុងពួកកុសលធម៌ជាដើម ព្រោះហេតុនោះព្រះមានព្រះភាគទ្រង់ត្រាស់ថា ពួកធម៌ជាកុសល នឹងធម៌ជាអកុសលក៏មាន ពួកធម៌ដែលប្រកបដោយទោស នឹងធម៌មិនមានទោសក៏មាន ពួកធម៌ដែលគួរសេព នឹងធម៌ដែលមិនគួរសេពក៏មាន

ពួកធម៌ថោកទាប នឹងធម៌ឧត្តមក៏មាន ពួកធម៌មានចំណែកប្រៀបដោយពណ៌ខ្មៅ នឹងពណ៌សក៏មាន ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញាក្នុងពួកធម៌ទាំងនេះឯង ជាអាហារនាំវិចិកិច្ឆាដែលមិនទាន់កើត មិនឲ្យកើតឡើងបាន ដែលកើតឡើងហើយ ក៏អាចលះបង់បាន ។

ម្យ៉ាងទៀត ធម៌ ៦ យ៉ាងប្រព្រឹត្តទៅក្នុងការលះបង់នូវវិចិកិច្ឆាបានដែរគឺ ១– ពាហុស្សុតតា ភាពជាអ្នករៀនសូត្រចេះដឹងច្រើន ២– បរិបុច្ឆកតា ភាពជាអ្នកច្រើនដោយការសាកសួរនូវហេតុគួរ នឹងមិនគួរ ៣– វិនយេ បកតញ្ញុតា ភាពជាអ្នកស្គាល់ការខុសត្រូវក្នុងវិនយបញ្ញត្តិ ៤– អធិមោក្ខពហុលតា ភាពជាអ្នកច្រើនដោយការជាប់ជឿស៊ប់ ៥– កល្យាណមិត្តតា ភាពជាអ្នកសេពគប់តែមិត្តល្អ ៦– សប្បាយកថា និយាយ ឬស្តាប់នូវពាក្យដែលនាំឲ្យមានសេចក្តីសប្បាយ ។ វិចិកិច្ឆាដែលលះបង់ដោយធម៌ទាំង ៦ យ៉ាងនេះបានហើយ ។ មិនអាចកើតតទៅទៀតបាននោះ ដោយសោតាបត្តិមគ្គ ។

តមក ភិក្ខុនោះ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្នុង គឺធម៌របស់ខ្លួនផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្រៅ គឺធម៌របស់អ្នកដទៃផង ឈ្មោះថាពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយទាំងខាងក្នុង ទាំងខាងក្រៅ, ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងធម៌ទាំងឡាយផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងធម៌ទាំង-

ឡាយផង ឈ្មោះថាពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយ ។ ម្យ៉ាងទៀត ស្មារតីរបស់ភិក្ខុនោះ ក៏តាំងឡើងប្រាកដថា ធម៌ទាំងនេះ គ្រាន់តែជាធម៌ទាំងឡាយប៉ុណ្ណោះឯង មិនមែនសត្វ មិនមែនបុគ្គល មិនមែនស្ត្រី មិនមែនបុរសទេ កំណត់ដើម្បីឲ្យចំរើនប្រាជ្ញា ឲ្យមានស្មារតីរឹងប៉ុនប៉ុណ្ណោះ ដោយអំណាចនៃការពិចារណាឃើញដូច្នេះ ចិត្តរបស់ភិក្ខុនោះ ក៏មិនជាប់ជំពាក់ មិនអាស្រ័យនៅដោយតណ្ហានឹងទិដ្ឋិផង ទាំងមិនមានសេចក្ដីប្រកៀកប្រកាន់នូវអ្វីនីមួយតិចតួចក្នុងលោកផង ។

សេចក្ដីដែលពោលមកនេះឯង ហៅថា ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺនីវរណៈ ៥ ។

នីវរណបព្វៈ ចប់ ។

## ខន្ធបព្វៈ

### សង្កាត់នៃការពិចារណានូវធម៌គឺឧបាទានក្ខន្ធ

ភិក្ខុ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺឧបាទានក្ខន្ធ ៥ ។ ភិក្ខុ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺឧបាទានក្ខន្ធ ៥ នោះ តើដូចម្ដេច ? ភិក្ខុ ពិចារណាឃើញតាមសេចក្ដីពិតថា រូបមានប៉ុណ្ណោះ ធម៌ជាដែនកើតឡើងនៃរូបមានប៉ុណ្ណោះ ធម៌ជាដែនរលត់ទៅនៃរូបមានប៉ុណ្ណោះ, វេទនាមានប៉ុណ្ណោះ ធម៌ជាដែនកើតឡើងនៃវេទនាមានប៉ុណ្ណោះ

ធម៌ជាដែនរលត់ទៅនៃវេទនាមានប៉ុណ្ណេះ, សញ្ញាមានប៉ុណ្ណេះ ធម៌ជាដែនកើតឡើងនៃសញ្ញាមានប៉ុណ្ណេះ ធម៌ជាដែនរលត់ទៅនៃសញ្ញាមានប៉ុណ្ណេះ, សង្ខារទាំងឡាយមានប៉ុណ្ណេះ ធម៌ជាដែនកើតឡើងនៃសង្ខារទាំងឡាយមានប៉ុណ្ណេះ ធម៌ជាដែនរលត់ទៅនៃសង្ខារទាំងឡាយមានប៉ុណ្ណេះ, វិញ្ញាណមានប៉ុណ្ណេះ ធម៌ជាដែនកើតឡើងនៃវិញ្ញាណមានប៉ុណ្ណេះ ធម៌ជាដែនរលត់ទៅនៃវិញ្ញាណមានប៉ុណ្ណេះ ។

អធិប្បាយ រូបមាន ២៨ គឺ ភូតរូប ៤ មានបឋវីធាតុជាដើម ឧបាទាយរូប ២៤ មានបសាទរូប ៥ ជាដើម ធម៌ជាដែនដែលប្រជុំគ្នាឲ្យកើតរូបមាន ៤ គឺ អវិជ្ជា ១ តណ្ហា ១ កម្ម ១ អាហារ ១ ធម៌ជាដែនដែលនាំឲ្យរលត់រូប ព្រោះរលត់នូវធម៌ ៤ គឺ អវិជ្ជា ១ តណ្ហា ១ កម្ម ១ អាហារ ១, វេទនាមាន ៦ មានចក្ខុសម្ផស្សជាវេទនាជាដើម ធម៌ជាដែនដែលប្រជុំគ្នាឲ្យកើតវេទនាមាន ៤ គឺ អវិជ្ជា ១ តណ្ហា ១ កម្ម ១ ផស្សៈ ១, ធម៌ជាដែនដែលនាំឲ្យរលត់វេទនាព្រោះរលត់នូវធម៌ ៤ គឺ អវិជ្ជា ១ តណ្ហា ១ កម្ម ១ ផស្សៈ ១, សញ្ញាមាន ៦ មានចក្ខុសម្ផស្សជាសញ្ញាជាដើម ធម៌ជាដែនដែលប្រជុំគ្នាឲ្យកើតសញ្ញាមាន ៤ គឺ អវិជ្ជា ១ តណ្ហា ១ កម្ម ១ ផស្សៈ ១, ធម៌ជាដែនដែលនាំឲ្យរលត់សញ្ញាព្រោះរលត់នូវធម៌ ៤ គឺ អវិជ្ជា ១ តណ្ហា ១ កម្ម ១ ផស្សៈ ១, សង្ខារបានដល់ចេតនាដែលប្រព្រឹត្តទៅក្នុងទ្វារ ៦ មានចក្ខុសម្ផស្សជាចេតនាជាដើម ធម៌ជាដែនដែល

ប្រជុំគ្នាឲ្យកើតសង្ខារមាន ៤ គឺ អវិជ្ជា ១ តណ្ហា ១ កម្ម ១ ផស្សៈ ១, ធម៌ជាដែនដែលនាំឲ្យរលត់សង្ខារ ព្រោះរលត់នូវធម៌ ៤ គឺ អវិជ្ជា ១ តណ្ហា ១ កម្ម ១ ផស្សៈ ១, វិញ្ញាណប្បានដល់ចិត្ត ៨៩ ឬ ១២១ ដួង ធម៌ជាដែនដែលប្រជុំគ្នាឲ្យកើតវិញ្ញាណមាន ៤ គឺ អវិជ្ជា ១ តណ្ហា ១ កម្ម ១ នាមរូប ១, ធម៌ជាដែនដែលនាំឲ្យរលត់វិញ្ញាណ ព្រោះរលត់នូវធម៌ ៤ គឺ អវិជ្ជា ១ តណ្ហា ១ កម្ម ១ នាមរូប ១ ។

ភិក្ខុ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្នុង គឺធម៌របស់ខ្លួន ទាំងពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្រៅ គឺធម៌របស់អ្នកដទៃ ។បេ។ ដោយអំណាចនៃការពិចារណាឃើញដូច្នេះ ចិត្តរបស់ភិក្ខុនោះ ក៏មិនជាប់ជំពាក់ មិនអាស្រ័យនៅដោយតណ្ហានិងទិដ្ឋិផង ទាំងមិនមានសេចក្តីប្រកៀកប្រកាន់នូវអ្វីនីមួយតិចតួចក្នុងលោកផង ។

សេចក្តីដែលពោលមកនេះ ហៅថា ភិក្ខុ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺឧបាទានក្ខន្ធ៥ ។

ខន្ធបព្វៈ ចប់ ។

## អាយតនបព្វៈ

សង្កាត់នៃការពិចារណានូវធម៌គឺអាយតនៈ

ភិក្ខុ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺអាយតនៈ ៦ ទាំងខាងក្នុងទាំងខាងក្រៅ ។ ភិក្ខុ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ

គឺអាយតនៈ ៦ ទាំងខាងក្នុងទាំងខាងក្រៅនោះ តើដូចម្ដេច ? ភិក្ខុ ដឹង ច្បាស់នូវចក្ខុផង ដឹងច្បាស់នូវរូបារម្មណ៍ទាំងឡាយផង មួយទៀត សំ-យោជនៈណា ដែលអាស្រ័យនូវចក្ខុនឹងរូបារម្មណ៍ទាំងពីរនោះហើយកើតឡើង ក៏ដឹងច្បាស់នូវសំយោជនៈនោះផង សំយោជនៈដែលមិនទាន់កើតឡើងហើយកើតឡើងបានដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង សំយោជនៈដែលកើតឡើងហើយ អាចលះបង់បានដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង សំយោជនៈដែលលះបង់បានហើយ ៗ មិនអាចកើតតទៅទៀតបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង

ដឹងច្បាស់នូវសោតៈផង ដឹងច្បាស់នូវសទ្ទារម្មណ៍ទាំងឡាយផង...ៗ

ដឹងច្បាស់នូវឃានៈផង ដឹងច្បាស់នូវគន្ធារម្មណ៍ទាំងឡាយផង...ៗ

ដឹងច្បាស់នូវជិវ្ហាផង ដឹងច្បាស់នូវរសារម្មណ៍ទាំងឡាយផង....ៗ

ដឹងច្បាស់នូវកាយផង ដឹងច្បាស់នូវផោដ្ឋព្វារម្មណ៍ទាំងឡាយផង..ៗ

ភិក្ខុ ដឹងច្បាស់នូវមនោផង ដឹងច្បាស់នូវធម្មារម្មណ៍ទាំងឡាយផង មួយទៀត សំយោជនៈណាដែលអាស្រ័យនូវមនោ នឹងធម្មារម្មណ៍ទាំងពីរនោះហើយកើតឡើង ក៏ដឹងច្បាស់នូវសំយោជនៈនោះផង សំយោជនៈដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង សំយោជនៈដែលកើតឡើងហើយ អាចលះបង់បានដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង សំយោជនៈដែលលះបង់បាន

ហើយ ៗ មិនអាចកើតតទៅទៀតបាន ដោយហេតុណា កំដឹងច្បាស់នូវហេតុនោះផង ៗ

អធិប្បាយ អាយតនៈខាងក្នុង ៦ គឺ ចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយ មនោ ៗ អាយតនៈខាងក្រៅ ៦ គឺ រូបៈ សទ្ទៈ គន្ធៈ រសៈ ផោដ្ឋព្វៈ ធម្មៈ ៗ អាយតនៈទាំងនេះជាគូអាស្រ័យគ្នានឹងគ្នា ដូចចក្ខុជាគូនឹងរូប, សោតៈជាគូនឹងសទ្ទៈ, ឃានៈជាគូនឹងគន្ធៈ, ជិវ្ហាជាគូនឹងរសៈ, កាយជាគូនឹងផោដ្ឋព្វៈ, មនោជាគូនឹងធម្មៈ ៗ អាយតនៈខាងក្នុងនឹងអាយតនៈខាងក្រៅនេះឯង ដែលអាស្រ័យគ្នានឹងគ្នា ជាមូលហេតុនាំឲ្យកើតកិលេស គឺសំយោជនៈ ៗ ប្រែថា កិលេសជាតជាគ្រឿងប្រកបសត្វទុក ឬ ចងក្រៀកសត្វឲ្យជាប់នៅក្នុងភពមាន ១០ យ៉ាងគឺ កាមរាគៈ ១ បដិឃៈ ១ មានៈ ១ ទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ ភវរាគៈ ១ ឥស្សា ១ មច្ឆរិយៈ ១ អវិជ្ជា ១ ៗ សំយោជនៈដែលកើតឡើង អាស្រ័យនូវអាយតនៈខាងក្នុង នឹងអាយតនៈខាងក្រៅ តើដូចម្ដេច ? ត្រង់ដែលបុគ្គលបានឃើញឥដ្ឋារម្មណ៍ដែលមកកាន់គន្លងនៃចក្ខុទ្វារ មានសេចក្ដីរីករាយ ដោយអំណាចនៃកាមហើយ ឈ្មោះថាកាមរាគសំយោជនៈកើតឡើង, ត្រង់ដែលបុគ្គលមានសេចក្ដីខឹងអាក់អន់តូចចិត្តចំពោះអនិដ្ឋារម្មណ៍ ឈ្មោះថាបដិឃសំយោជនៈកើតឡើង, ត្រង់ដែលបុគ្គលមានសេចក្ដីសំគាល់ថា អ្នកដទៃវៀរតែអាត្មាអញចេញ ហើយមិនអាចយល់នូវអារម្មណ៍នោះបានទេ ឈ្មោះថា មានសំយោជនៈ

កើតឡើង, ត្រង់ដែលបុគ្គល មានសេចក្ដីយល់ប្រកាន់ថា រូបារម្មណ៍នោះឯងជារបស់ទៀងទាត់ឈ្មោះថា ទិដ្ឋិសំយោជនៈកើតឡើង, ត្រង់ដែលបុគ្គលមានសេចក្ដីសង្ស័យថា រូបារម្មណ៍នោះឯងជាសត្វ ឬ ហ្ន៎? ជារបស់សត្វ ឬ ហ្ន៎? ឈ្មោះថាវិចិកិច្ឆាសំយោជនៈកើតឡើង, ត្រង់ដែលបុគ្គលមានសេចក្ដីប្រាថ្នាសម្បត្តិក្នុងភពថា អើហ្ន៎! របស់នេះយើងបានល្អហើយ ឈ្មោះថាភវរាគសំយោជនៈកើតឡើង, ត្រង់ដែលបុគ្គលសមាទានកាន់យកនូវសីល និងវត្តដោយគិតថា សេចក្ដីបរិសុទ្ធិរបស់អាត្មាអញ ដោយសីលនិងវត្តនេះ ឬ តាំងចិត្តសមាទាននូវសីល និងវត្តបែបនេះតទៅទៀត ឈ្មោះថា សីលព្វតបរាមាសសំយោជនៈកើតឡើង, ត្រង់ដែលបុគ្គលមានសេចក្ដីប្រណែនថា ធ្វើម្ដេចហ្ន៎! អ្នកដទៃ កុំគប្បីបាននូវរូបារម្មណ៍នោះ ឈ្មោះថា ឥស្សាសំយោជនៈកើតឡើង, ត្រង់ដែលបុគ្គលមានសេចក្ដីកំណាញ់ក្នុងរូបារម្មណ៍ដែលខ្លួនបានហើយ មិនចង់ឲ្យឃ្លាតចេញបានទៅអ្នកដទៃ ឈ្មោះថា មច្ឆរិយសំយោជនៈកើតឡើង, អវិជ្ជាសំយោជនៈរបស់បុគ្គលកើតឡើង ព្រោះការមិនដឹងដោយអំណាចនៃសេចក្ដីល្ងង់ដែលកើតរួមជាមួយនឹងសំយោជនៈទាំងអស់ដូចបានពោលមកហើយ ។ ន័យដែលបានពោលមកហើយនេះ គប្បីជ្រាបក្នុងសំយោជនៈដែលកើតឡើងអាស្រ័យនូវអាយតនៈជាលំដាប់តទៅមានសោត.នឹងសទ្ទារម្មណ៍ជាដើមផងចុះ ។

ការលះបង់សំយោជនៈទាំង ១០ នោះដោយតទង្គប្បហាន នឹងវិក្ខម្ភ•

ទប្បហាន ។ សំយោជនៈ ៥ គឺ ទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ ឥស្សា ១ មច្ឆរិយៈ ១ ដែលបុគ្គលលះបង់បានហើយមិនកើតតទៅទៀត ដោយសោតាបត្តិមគ្គ ។ សំយោជនៈ ២ គឺ កាមរាគៈ ១ បដិឃៈ ១ ដ៏គ្រោតគ្រាតដែលបុគ្គលលះបង់បានហើយមិនកើតតទៅទៀត ដោយសកទាគាមិមគ្គ ដែលល្អិតដោយអនាគាមិមគ្គ ។ សំយោជនៈ ៣ គឺ មានៈ ១ ភវរាគៈ ១ អវិជ្ជា ១ ដែលបុគ្គលលះបង់បានហើយ មិនកើតតទៅទៀត ដោយអរហត្តមគ្គ ។

តមក ភិក្ខុនោះ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្នុង គឺធម៌របស់ខ្លួន ទាំងពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្រៅ គឺធម៌របស់អ្នកដទៃ ។ បេ ។ ដោយអំណាចនៃការពិចារណាឃើញដូច្នេះ ចិត្តរបស់ភិក្ខុនោះ មិនជាប់ជំពាក់ មិនអាស្រ័យនៅដោយតណ្ហានិងទិដ្ឋិផង ទាំងមិនមានសេចក្ដីប្រកៀកប្រកាន់នូវអ្វីនីមួយតិចតួចក្នុងលោកផង ។

សេចក្ដីដែលពោលមកនេះ ហៅថា ភិក្ខុ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺអាយតនៈ ៦ ទាំងខាងក្នុង ទាំងខាងក្រៅ ។

អាយតនបព្វៈ ចប់ ។

## ពោជ្ឈង្គបព្វៈ

សង្កាត់នៃការពិចារណានូវធម៌ គឺពោជ្ឈង្គ

(អង្គនៃប្រាជ្ញាជាគ្រឿងដឹងច្បាស់ ឬត្រាស់ដឹងនូវមគ្គផលនិព្វាន ហៅថា ពោជ្ឈង្គ) ។

ភិក្ខុ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺពោជ្ឈង្គ ៧ ។ ភិក្ខុ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺពោជ្ឈង្គ ៧ នោះ តើដូចម្តេច ? ភិក្ខុ ពិចារណាឃើញ ទោះសតិសម្ពោជ្ឈង្គមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គមាននៅក្នុងខ្លួនរបស់អាត្មាអញ, ទោះសតិ-សម្ពោជ្ឈង្គមិនមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គមិនមាននៅក្នុងខ្លួនរបស់អាត្មាអញ, ម្យ៉ាងទៀត សតិសម្ពោជ្ឈង្គដែលមិនទាន់កើត ក៏កើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង សតិ-សម្ពោជ្ឈង្គដែលកើតឡើងហើយ ក៏ពេញបរិបូណ៌ដោយការចំរើន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

ទោះធម្មវិចយសម្ពោជ្ឈង្គ មាននៅក្នុងខ្លួន..... ។

ទោះវីរិយសម្ពោជ្ឈង្គ មាននៅក្នុងខ្លួន..... ។

ទោះបីតិសម្ពោជ្ឈង្គ មាននៅក្នុងខ្លួន..... ។

ទោះបស្សទ្ធិសម្ពោជ្ឈង្គ មាននៅក្នុងខ្លួន..... ។

ទោះសមាធិសម្ពោជ្ឈង្គ មាននៅក្នុងខ្លួន..... ។

ភិក្ខុ ពិចារណាឃើញ ទោះឧបេក្ខាសម្ពោជ្ឈង្គ មាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គមាននៅក្នុងខ្លួនរបស់អាត្មាអញ, ទោះឧបេក្ខាសម្ពោជ្ឈង្គមិនមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គមិនមាននៅក្នុងខ្លួនរបស់អាត្មាអញ ។ ម្យ៉ាងទៀត ឧបេក្ខាសម្ពោជ្ឈង្គ

ដែលមិនទាន់កើតក៏កើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ឧបេក្ខាសម្ពោជ្ឈង្គដែលកើតឡើងហើយ ក៏ពេញបរិបូណ៌ដោយការចំរើន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ អធិប្បាយក្នុងពោជ្ឈង្គទីមួយ ៗ ដូចតទៅនេះ ៖

## សតិសម្ពោជ្ឈង្គ

អង្គរបស់បុគ្គលអ្នកត្រាស់ដឹង ឬអង្គរបស់ប្រាជ្ញាជាគ្រឿងត្រាស់ដឹង ហៅថា ពោជ្ឈង្គ ។ អង្គរបស់ប្រាជ្ញាជាគ្រឿងត្រាស់ដឹងដ៏ល្អគឺសតិ ហៅថា សតិសម្ពោជ្ឈង្គ ។ នេះ ជាអង្គនៃប្រាជ្ញាដែលនឹងញុំាងបុគ្គលអ្នកប្រតិបត្តិតាម ឲ្យបានត្រាស់ដឹងនូវអរិយមគ្គ-អរិយផលដោយពិត ព្រោះហេតុនោះបានជាព្រះសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើពួកធម៌ជាទីតាំងនៃសតិសម្ពោជ្ឈង្គមាននៅ ការធ្វើទុកក្នុងចិត្តឲ្យច្រើនដោយឧបាយប្រាជ្ញាប្រព្រឹត្តទៅក្នុងពួកធម៌ជាទីតាំងនៃសតិសម្ពោជ្ឈង្គនោះ ជាអាហារញុំាងសតិសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើង ញុំាងសតិសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យរឹងរឹតតែកើតចំរើនពេញបរិបូណ៌ជាភិយ្យោភាពឡើងទៀត ។ ម្យ៉ាងទៀត ធម៌ ៤ យ៉ាង ប្រព្រឹត្តទៅដើម្បីញុំាងសតិសម្ពោជ្ឈង្គឲ្យកើតឡើងគឺ ១– សតិសម្បជញ្ញៈ សេចក្តីរលឹកនឹកឃើញនឹងសេចក្តីដឹងខ្លួន; ២– មុដ្ឋស្សតិបុគ្គលបរិវជ្ជនតា វៀរនូវបុគ្គលដែលភ្លេចស្មារតី; ៣– ឧបដ្ឋិតស្សតិបុគ្គលសេវនតា

សេពគប់នូវបុគ្គលដែលមានស្មារតីដ៏កល់មាំ; ៤– តទធិមុត្តតា ចិត្តឱនចុះស៊ប់ក្នុងសតិសម្ពោជ្ឈង្គនោះ ។ សតិសម្ពោជ្ឈង្គដែលកើតឡើងដោយហេតុគឺធម៌ទាំង ៤ យ៉ាងនេះហើយ រមែងចំរើនពេញបរិបូណ៌ដោយអរហត្តមគ្គ (ពោជ្ឈង្គទាំង ៦ ខាងចុងទៀតក៏ដូចគ្នានេះដែរ) ។

## ធម្មវិចយសម្ពោជ្ឈង្គ

អង្គរបស់ប្រាជ្ញាជាគ្រឿងដឹងដ៏ល្អគឺធម្មវិចយៈ; ការជ្រើសរើសនូវ-ធម៌ឬការពិចារណានូវធម៌ ហៅថា ធម្មវិចយៈ ឯធម្មវិចយសម្ពោជ្ឈង្គនេះជាអង្គនៃប្រាជ្ញាដែលនឹងញុំាងបុគ្គលអ្នកប្រតិបត្តិតាម ឲ្យបានត្រាស់ដឹងនូវអរិយមគ្គ-អរិយផលដោយពិត ព្រោះហេតុនោះបានជាព្រះភគវ័តបរម-សាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម៌ជាកុសលនឹងធម៌ជាអកុ-សលក៏មាន ធម៌ដែលប្រកបដោយទោសនឹងធម៌មិនមានទោសក៏មាន ធម៌ដែលគួរសេពនឹងធម៌ដែលមិនគួរសេពក៏មាន ធម៌ថោកទាបនឹងធម៌ឧត្តមក៏មាន ធម៌មានចំណែកប្រៀបដោយពណ៌ខ្មៅនឹងពណ៌សក៏មាន ការធ្វើទុកក្នុងចិត្តឲ្យច្រើនដោយឧបាយប្រាជ្ញាប្រព្រឹត្តទៅក្នុងធម៌ទាំងនោះ ជាអាហារញុំាងធម្មវិចយសម្ពោជ្ឈង្គដែលមិនទាន់កើតឲ្យកើតឡើង ញុំាងធម្មវិចយសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យរឹងរឹតតែកើតចំរើនពេញបរិ-បូណ៌ជាភិយ្យោភាពឡើងទៀត ។ ម្យ៉ាងទៀត ធម៌ ៧ យ៉ាងប្រព្រឹត្តទៅដើម្បីញុំាងធម្មវិចយសម្ពោជ្ឈង្គឲ្យកើតឡើងគឺ ១– បរិបុច្ឆកតា ភាព

ជាអ្នកឧស្សាហ៍សាកសួរនូវធម៌មានខន្ធធាតុនិងអាយតនៈជាដើម; ២– វត្ថុវិសទកិរិយា ការធ្វើវត្ថុទាំងខាងក្នុងទាំងខាងក្រៅឲ្យស្អាត; ៣– ឥន្ទ្រិយសមត្តប្បដិបាទនា ការពូតផ្គុំឥន្ទ្រិយឲ្យមានកម្លាំងស្មើគ្នា; ៤– ទុប្បញ្ញបុគ្គលបរិវជ្ជនា ការវៀរចាកនូវបុគ្គលដែលគ្មានប្រាជ្ញា; ៥– បញ្ញវន្តបុគ្គលសេវនា ការសេពគប់នូវបុគ្គលដែលមានប្រាជ្ញា; ៦– គម្ភីរញ្ញាណចរិយបច្ចវេក្ខណា ការពិចារណាដោយញាណចរិយាដ៏ជ្រាលជ្រៅ; ៧– តទធិមុត្តតា ភាពជាអ្នកមានចិត្តឱនចុះស៊ប់ក្នុងធម្មវិចយសម្ពោជ្ឈង្គនោះ ។

## វីរិយសម្ពោជ្ឈង្គ

អង្គរបស់ប្រាជ្ញាជាគ្រឿងត្រាស់ដឹងដ៏ល្អគឺវិរិយៈ; ដំណើរប្រព្រឹត្តិទៅដោយសេចក្តីអង់អាចមិនរួញរាគឺ សេចក្តីព្យាយាមដ៏មុឺងម៉ាត់ ហៅថាវិរិយៈ ឯវិរិយសម្ពោជ្ឈង្គនេះ ជាអង្គនៃប្រាជ្ញាដែលនឹងញុំាងបុគ្គលអ្នកប្រតិបត្តិតាម ឲ្យបានត្រាស់ដឹងនូវអរិយមគ្គ-អរិយផលដោយពិត ព្រោះហេតុនោះបានជាព្រះសព្វញ្ញុពុទ្ធទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សេចក្តីព្យាយាមមាន ៣ យ៉ាងគឺ អារភធាតុ ព្យាយាមដែលតាំងឡើងជាដំបូង ១ និក្កមធាតុ ព្យាយាមយ៉ាងកណ្តាល ដើម្បីចេញចាកកោសជ្ជៈ ១ បរក្កមធាតុ ព្យាយាមយ៉ាងក្រៃលែងដើម្បីឈានកន្លងឲ្យរួចផុតចាកកោសជ្ជៈ ១ ។ ការធ្វើទុកក្នុងចិត្តឲ្យច្រើនដោយឧបាយ

ប្រាជ្ញប្រព្រឹត្តទៅក្នុងព្យាយាមទាំង ៣ យ៉ាងនោះ ជាអាហារដើម្បីញ៉ាំងវិរិយសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើង ញ៉ាំងវិរិយសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យរឹងរឹតតែកើតចំរើនពេញបរិបូណ៌ជាភិយ្យោភាពឡើងទៀត ។ ម្យ៉ាងទៀតធម៌ ១១ យ៉ាងប្រព្រឹត្តទៅដើម្បីញ៉ាំងវិរិយ-សម្ពោជ្ឈង្គឲ្យកើតឡើងគឺ ១– អបាយភយប្បច្ចវេក្ខណតា ភាពជាអ្នកពិចារណាឃើញនូវភ័យក្នុងអបាយ; ២– អានិសំសទស្សា-វិតា ភាពជាអ្នកឃើញនូវអានិសង្សនៃព្យាយាម; ៣– គមនវីថិបច្ចវេក្ខណតា ភាពជាអ្នកពិចារណាឃើញតាមវិថីជាដំណើរនៃអរិយបុគ្គលទាំងឡាយមានព្រះពុទ្ធជាដើមតែងដើរហើយ; ៤– បិណ្ឌបាតាប-ចាយនតា ភាពជាអ្នកមានសេចក្ដីគោរពក្នុងបិណ្ឌបាត; ៥– ទាយ-ជ្ជមហត្តប្បច្ចវេក្ខណតា ភាពជាអ្នកពិចារណាឃើញនូវភាវៈជាធំរបស់មត៌ក គឺបិណ្ឌបាតជាមត៌កដែលព្រះបរមសាស្ដាទ្រង់ប្រទានទុកឲ្យ; ៦– សត្ថុមហត្តប្បច្ចវេក្ខណតា ភាពជាអ្នកពិចារណាឃើញនូវភាវៈជាធំរបស់ព្រះបរមសាស្ដា; ៧– ជាតិមហត្តប្បច្ចវេក្ខណតា ភាពជាអ្នកពិចារណាឃើញនូវភាវៈជាធំរបស់ជាតិ; ៨– សព្រហ្មចារិ-មហត្តប្បច្ចវេក្ខណតា ភាពជាអ្នកពិចារណាឃើញនូវភាវៈជាធំរបស់សព្រហ្មចារី; ៩– កុសីតបុគ្គលបរិវជ្ជនតា ភាពជាអ្នកវៀរនូវបុគ្គលខ្ជិលច្រអូស; ១០– អារទ្ធវិរិយបុគ្គលសេវនតា ភាពជា

អ្នកសេពគប់នូវបុគ្គលអ្នកមានព្យាយាមប្រារព្ធ; ១១- តទធិមុត្តតា ភាពជាអ្នកមានចិត្តឱនចុះស៊ប់ក្នុងវីរិយសម្ពោជ្ឈង្គនោះ ។

## បីតិសម្ពោជ្ឈង្គ

អង្គរបស់ប្រាជ្ញាជាគ្រឿងត្រាស់ដឹងដ៏ល្អគឺបីតិ; ធម្មជាតិញុំាងកាយនឹងចិត្តឲ្យពេញឆ្អែតណែនដោយអំណរ ឬសេចក្ដីត្រេកអរដ៏ខ្លាំងហាក់ដូចជាអណ្ដែតកាយឡើងហៅថា បីតិ ឯបីតិសម្ពោជ្ឈង្គនេះ ជាអង្គនៃប្រាជ្ញាដែលញុំាងបុគ្គលអ្នកប្រតិបត្តិតាម ឲ្យបានត្រាស់ដឹងនូវអរិយមគ្គ - អរិយ-ផលដោយពិត ព្រោះហេតុនោះ ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើពួកធម៌ជាទីតាំងនៃបីតិសម្ពោជ្ឈង្គមាននៅ ការធ្វើទុកក្នុងចិត្តឲ្យច្រើនដោយឧបាយប្រាជ្ញា ប្រព្រឹត្តទៅក្នុងពួកធម៌ជាទីតាំងនៃបីតិ. សម្ពោជ្ឈង្គនោះ ជាអាហារដើម្បីញុំាងបីតិសម្ពោជ្ឈង្គដែលមិនទាន់កើតឲ្យកើតឡើង បីតិសម្ពោជ្ឈង្គដែលកើតឡើងហើយក៏រឹងរឹតតែកើតចំរើនពេញបរិបូណ៌ជាកិយ្យោភាពឡើងទៀត ។ មួយវិញទៀត ធម៌ ១១ យ៉ាងប្រព្រឹត្តទៅដើម្បីញុំាងបីតិសម្ពោជ្ឈង្គឲ្យកើតឡើងគឺ ១- ពុទ្ធានុស្សតិ ២- ធម្មានុស្សតិ ៣- សង្ឃានុស្សតិ ៤- សីលានុស្សតិ ៥- ចាគានុស្សតិ ៦- ទេវតានុស្សតិ ៧- ឧបសមានុស្សតិ ៨- លូខបុគ្គលបរិវជ្ជនតា ភាពជាអ្នកវៀរនូវបុគ្គល ដែលសៅហ្មងគ្រោក ៩- សិនិទ្ធបុគ្គលសេវនតា ភាពជាអ្នកសេពគប់នូវបុគ្គល

មានចិត្តទន់ភ្លន់ពេលសោរ ១០– បសាទនីយសុត្តន្តប្បច្ចវេក្ខណ-តា ភាពជាអ្នកពិចារណានូវសូត្រដែលគួរនាំមកនូវសេចក្តីជ្រះថ្លា ១១– តទធិមុត្តតា ភាពជាអ្នកមានចិត្តឱនចុះស៊ប់ក្នុងបីតិសម្ពោជ្ឈង្គនោះ ។

## បស្សទ្ធិសម្ពោជ្ឈង្គ

អង្គរបស់ប្រាជ្ញជាគ្រឿងត្រាស់ដឹងដ៏ល្អគឺបស្សទ្ធិ, សេចក្តីស្ងប់ គឺសេចក្តីស្ងប់កាយ នឹងសេចក្តីស្ងប់ចិត្ត ហៅថា បស្សទ្ធិ ឯបស្សទ្ធិសម្ពោជ្ឈង្គនេះ ជាអង្គនៃប្រាជ្ញដែលញុំាងបុគ្គលអ្នកប្រតិបត្តិតាម ឲ្យបានត្រាស់ដឹងនូវអរិយមគ្គ - អរិយផលដោយពិត ព្រោះហេតុនោះ បានជាព្រះបរម-សាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការធ្វើទុកក្នុងចិត្តឲ្យច្រើនដោយឧបាយប្រាជ្ញប្រព្រឹត្តទៅក្នុងកាយបស្សទ្ធិ នឹងចិត្តបស្សទ្ធិនោះឯង ជាអាហារដើម្បីញុំាងបស្សទ្ធិសម្ពោជ្ឈង្គដែលមិនទាន់កើតឲ្យកើតឡើង ញុំាងបស្សទ្ធិសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យរឹងរឹតតែកើតចំរើនពេញបរិបូណ៌ជាតិយេ្យភាពឡើងទៀត ។ មយ៉ាងទៀត ធម៌ ៧ យ៉ាងប្រព្រឹត្តទៅដើម្បីញុំាងបស្សទ្ធិសម្ពោជ្ឈង្គឲ្យកើតឡើងគឺ ១– បណីតភោជន-សេវនតា ភាពជាអ្នកសេពនូវភោជនដ៏ឧត្តម, ២– ឧតុសុខសេ-វនតា ភាពជាអ្នកសេពនូវរដូវដែលនាំឲ្យសប្បាយក្នុងឥរិយាបថទាំង ៤, ៣– ឥរិយាបថសុខសេវនតា ភាពជាអ្នកសេពនូវឥរិយាបថជាសុខ, ៤– មជ្ឈត្តប្បយោគតា ភាពជាអ្នកប្រកបព្យាយាមយ៉ាងកណ្តាល,

៥- សារទ្ធកាយបុគ្គលបរិវជ្ជនតា ភាពជាអ្នកវៀរនូវបុគ្គលដែលមានកាយសោប់សេល់, ៦- បស្សទ្ធកាយបុគ្គលសេវនតា ភាពជាអ្នកសេពគប់នូវបុគ្គលដែលមានកាយស្ងប; ៧- តទធិមុត្តតា ភាពជាអ្នកមានចិត្តឱនចុះស៊ប់ក្នុងបស្សទ្ធិសម្ពោជ្ឈង្គនោះ ។

## សមាធិសម្ពោជ្ឈង្គ

អង្គរបស់ប្រាជ្ញាជាគ្រឿងត្រាស់ដឹងដ៏ល្អគឺសមាធិ, ធម៌ដែលធ្វើចិត្តឲ្យស្ងប់ គឺធ្វើចិត្តឲ្យទឹងធឹងបិតនៅក្នុងអារម្មណ៍ជាកុសលតែមួយ ហៅថា សមាធិ ឯសមាធិសម្ពោជ្ឈង្គនេះជាអង្គនៃប្រាជ្ញាដែលនឹងញុំាងបុគ្គលអ្នកប្រតិបត្តិតាមឲ្យបានត្រាស់ដឹងនូវអរិយមគ្គ-អរិយផលដោយពិត ព្រោះហេតុនោះបានជាព្រះតថាគតទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការធ្វើទុកក្នុងចិត្តឲ្យច្រើនដោយឧបាយប្រាជ្ញាប្រព្រឹត្តទៅក្នុង សមថនិមិត្ត (ការធ្វើចិត្តឲ្យស្ងប់ជានិមិត្ត) និងអព្យគ្គនិមិត្ត (ការធ្វើចិត្តមិនឲ្យរាយមាយជានិមិត្ត) ហ្នឹងឯងជាអាហារដើម្បីញុំាងសមាធិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឲ្យកើតឡើងញុំាងសមាធិសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យរឹងរឹតតែកើតចំរើនពេញបរិបូណ៌ជាកិយ្យោភាពឡើងទៀត ។ មយ៉ាងទៀត ធម៌ ១១ យ៉ាងប្រព្រឹត្តទៅដើម្បីញុំាងសមាធិសម្ពោជ្ឈង្គឲ្យកើតឡើងគឺ ១- វត្ថុវិសទកិរិយា ការធ្វើវត្ថុទាំងខាងក្នុងទាំងខាងក្រៅឲ្យស្អាត; ២- ឥន្ទ្រិយសមត្តប្បដិបាទនតា ភាពជាអ្នកពូតផ្គុំឥន្ទ្រិយឲ្យមានកម្លាំងស្មើគ្នា,

៣– និមិត្តកុសលតា ភាពជាអ្នកឈ្លាសក្នុងនិមិត្ត, ៤– សមយេ ចិត្តស្ស បគ្គណ្ហណតា ភាពជាអ្នកផ្គងចិត្តឡើងក្នុងសម័យដែលគួរ, ៥– សមយេ ចិត្តស្ស និគ្គណ្ហណតា ភាពជាអ្នកសង្កត់ចិត្តទុកក្នុងសម័យដែលគួរ, ៦– សមយេ ចិត្តស្ស សម្បហំសនតា ភាពជាអ្នកកម្សាចិត្តក្នុងសម័យដែលគួរ, ៧– សមយេ ចិត្តស្ស អជ្ឈុបេក្ខនតា ភាពជាអ្នកទប់តម្រង់ចិត្តក្នុងសម័យដែលគួរ, ៨– អសមាហិតបុគ្គលបរិវជ្ជនតា ភាពជាអ្នកវៀរនូវបុគ្គលដែលមានចិត្តមិនដំកល់មាំ, ៩– សមាហិតបុគ្គលសេវនតា ភាពជាអ្នកសេពគប់នូវបុគ្គលដែលមានចិត្តដំកល់មាំ, ១០– ឈានវិមោក្ខបច្ចវេក្ខណតា ភាពជាអ្នកពិចារណានូវឈានវិមោក្ខ, ១១– តទធិមុត្តតា ភាពជាអ្នកមានចិត្តឱនចុះស៊ប់ក្នុងសមាធិសម្ពោជ្ឈង្គនោះ ។

## ឧបេក្ខាសម្ពោជ្ឈង្គ

អង្គរបស់ប្រាជ្ញាជាគ្រឿងត្រាស់ដឹងដ៏ល្អគឺ ឧបេក្ខា, ធម្មជាតិព្រងើយកន្តើយ តាំងនៅជាកណ្តាល ។ មិនអើពើក្នុងឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍ ហៅថា ឧបេក្ខា ឯឧបេក្ខាសម្ពោជ្ឈង្គនេះ ជាអង្គនៃប្រាជ្ញាដែលនឹងញុំាងបុគ្គលអ្នកប្រតិបត្តិតាមឲ្យត្រាស់ដឹងនូវអរិយមគ្គ-អរិយផលដោយពិត ព្រោះហេតុនោះបានជា ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើពួកធម៌ដែលជាទីតាំងនៃឧបេក្ខាសម្ពោជ្ឈង្គមាននៅ ការធ្វើទុក

កុងចិត្តឲ្យច្រើនដោយឧបាយប្រាជ្ញប្រព្រឹត្តទៅក្នុងពួកធម៌ទាំងនោះ ជាអាហារញ៉ាំងឧបេក្ខាសម្ពោជ្ឈង្គ ដែលមិនទាន់កើតឲ្យកើតឡើង ញ៉ាំងឧបេក្ខាសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យរឹងរឹតតែកើតបំរើនពេញបរិបូណ៌ជាកិយ្យោភាពឡើងទៀត ។ ម្យ៉ាងទៀត ធម៌ ៥ យ៉ាងប្រព្រឹត្តទៅដើម្បីញ៉ាំងឧបេក្ខាសម្ពោជ្ឈង្គឲ្យកើតឡើងគឺ ១– សត្តមជ្ឈត្តតា ភាពនៃចិត្តជាកណ្ដាលក្នុងសត្វ ២– សង្ខារមជ្ឈត្តតា ភាពនៃចិត្តជាកណ្ដាលក្នុងសង្ខារ, ៣– សត្តសង្ខារកេលាយនបុគ្គលបរិវជ្ជនតា វៀរនូវបុគ្គលដែលមានសេចក្ដីរាប់អានក្នុងសត្វនិងសង្ខារ, ៤– សត្តសង្ខារមជ្ឈត្តបុគ្គលសេវនតា សេពគប់នូវបុគ្គលដែលមានចិត្តជាកណ្ដាល ក្នុងសត្វនិងសង្ខារ, ៥– តទធិមុត្តតា មានចិត្តនុនបុះសិប់ក្នុងឧបេក្ខាសម្ពោជ្ឈង្គនោះ ។

តមក ភិក្ខុនោះ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្នុងគឺធម៌របស់ខ្លួន ទាំងពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្រៅគឺធម៌របស់អ្នកដទៃ ។ល។ ដោយអំណាចនៃការពិចារណាឃើញដូច្នេះ ចិត្តរបស់ភិក្ខុនោះ មិនជាប់ជំពាក់ មិនអាស្រ័យនៅដោយតណ្ហានិងទិដ្ឋិផង ទាំងមិនមានសេចក្ដីប្រកៀកប្រកាន់នូវអ្វីនីមួយតិចតួចក្នុងលោកផង ។

សេចក្ដីដែលពោលមកនេះ ហៅថា ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយគឺពោជ្ឈង្គ ៧ ។

ពោជ្ឈង្គបព្វៈ ចប់ ។

# សច្ចបព្វៈ

## សង្កាត់នៃការពិចារណានូវធម៌គឺអរិយសច្ច

ភិក្ខុ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺអរិយសច្ច ៤ ។ ភិក្ខុ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺអរិយសច្ច ៤ នោះ តើដូចម្តេច ? ភិក្ខុ ដឹងច្បាស់តាមពិតថា នេះទុក្ខ, ដឹងច្បាស់តាមពិតថា នេះធម៌ជាដែនកើតឡើងនៃទុក្ខ, ដឹងច្បាស់តាមពិតថា នេះធម៌សម្រាប់រំលត់ទុក្ខ, ដឹងច្បាសតាមពិតថា នេះបដិបទាជាដំណើរទៅកាន់ធម៌សម្រាប់រំលត់ទុក្ខទាំង ៤ នេះឯង ហៅថា អរិយសច្ច ។

# ទុក្ខសច្ច

## ទុក្ខជាការពិត

ដូចម្តេច ហៅថា ទុក្ខអរិយសច្ច ? ជាតិ ចាត់ថាជាទុក្ខ, ជរា ចាត់ថាជាទុក្ខ, មរណៈ ចាត់ថាជាទុក្ខ, សោក ចាត់ថាជាទុក្ខ, បរិទេវៈ (សេចក្តីខ្សឹកខ្សួល) ចាត់ថាជាទុក្ខ, ទុក្ខៈ (សេចក្តីលំបាកកាយនឹងចិត្ត) ចាត់ថាជាទុក្ខ, ទោមនស្ស (សេចក្តីអាក់អន់ចិត្ត) ចាត់ថាជាទុក្ខ, ឧបាយាសៈ (សេចក្តីតានតឹង ឬ ខ្វោចផ្សាចិត្ត) ចាត់ថាជាទុក្ខ, អប្បិយេហិ សម្បយោគ (ការជួបប្រសព្វជាមួយសត្វនឹងសង្ខារទាំងឡាយដែលមិនជាទីស្រឡាញ់) ចាត់ថាជាទុក្ខ, បិយេហិ វិប្បយោគ (ការព្រាត់ប្រាសចាកសត្វនឹងសង្ខារទាំងឡាយដែលជាទីស្រឡាញ់) ចាត់ថាជាទុក្ខ, យម្បិច្ឆំ ន

លកតិ តម្បិទុក្ខ (ប្រាថ្នានូវហេតុណា មិនបានដូចប្រាថ្នា ការមិនបាន នោះ) ចាត់ថាជាទុក្ខ, សង្ខិត្តេន បញ្ចុបាទានក្ខន្ធទុក្ខ (ដោយបំប្រួញមក គឺឧបាទានក្ខន្ធទាំង ៥) ចាត់ថាជាទុក្ខ, ទុក្ខទាំងអស់នេះឯង ហៅថា ទុក្ខអរិយសច្ច ។

ដូចម្តេច ហៅថា ជាតិ ? ការកើត ការកើតព្រម ការចុះកាន់គភ៌ ការប្រព្រឹត្តិទៅមិនដាច់ ការកើតប្រាកដនៃខន្ធទាំងឡាយ ការបានចំពោះ នូវអាយតនៈទាំងឡាយនៃពួកសត្វនោះ ៗ នេះឯង តថាគតហៅថា ជាតិ (កំណើត) ។

ដូចម្តេច ហៅថា ជរា ? ការគ្រាំគ្រា ការទ្រុឌទ្រោមនៃរាងកាយ ធ្មេញបាក់ សក់ស្កូវ សាច់ស្បែកជ្រួញជ្រីវយុរយារ ការថយចុះនៃ អាយុ ការទ្រោមជុំវិញនៃឥន្ទ្រិយទាំងឡាយនៃពួកសត្វនោះ ៗ នេះឯង ហៅថា ជរា (សេចក្តីចាស់) ។

ដូចម្តេច ហៅថា មរណៈ ? ការច្យុតិ ការឃ្លាតទៅនៃវិញ្ញាណ ការបែកធ្លាយបាត់បង់ទៅនៃរាងកាយ ការធ្វើនូវមរណកាល ការបែក ធ្លាយនៃខន្ធទាំងឡាយ ការដាក់ចុះនូវអត្តភាពលើផែនដីដូចជាអង្កត់ឧស ការដាច់បង់នៃជីវិតិន្ទ្រិយនៃពួកសត្វនោះ ៗ នេះឯង ហៅថា មរណៈ (សេចក្តីស្លាប់) ។

ដូចម្តេច ហៅថា សោក ? សេចក្តីសោកស្តាយ សេចក្តីស្រងេះ

ស្រងោប សេចក្ដីរឹងស្ងួតចិត្ត សេចក្ដីក្រៀមក្រំចិត្តនៃពួកសត្វដែលប្រកបដោយសេចក្ដីវិនាសណាមួយ មានសេចក្ដីវិនាសនៃញាតិជាដើម ឬហេតុនៃទុក្ខណាមួយ មានការសម្លាប់ ឬចាប់ចងជាដើម ពាល់ត្រូវហើយ នេះឯង ហៅថា សោក (សេចក្ដីស្ដាយអាល័យ) ។

ដូចម្ដេច ហៅថា បរិទេវៈ? ការយំទួញរក ការយំទួញរៀបរាប់ បូរបាច់ពីនេះពីនោះនៃពួកសត្វ ដែលប្រកបដោយសេចក្ដីវិនាសណាមួយ មានសេចក្ដីវិនាសនៃញាតិជាដើម ឬ ហេតុនៃទុក្ខណាមួយ មានការសម្លាប់ ឬ ចាប់ចងជាដើមពាល់ត្រូវហើយ នេះឯង ហៅថា បរិទេវៈ (សេចក្ដីខ្សឹកខ្សួល) ។

ដូចម្ដេច ហៅថា ទុក្ខ ? សេចក្ដីលំបាកប្រព្រឹត្តទៅក្នុងកាយ សេចក្ដីមិនត្រេកអរប្រព្រឹត្តទៅក្នុងកាយ ការទទួលនូវអារម្មណ៍មិនជាទីត្រេកអរ ដែលកើតអំពីកាយសម្ផស្សនៃសត្វទាំងឡាយនោះ ៗ នេះឯង ហៅថា ទុក្ខ (សេចក្ដីលំបាកកាយនឹងចិត្ត) ។

ដូចម្ដេច ហៅថា ទោមនស្ស ? សេចក្ដីអាក់អន់ប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីមិនត្រេកអរប្រព្រឹត្តទៅក្នុងចិត្ត ការទទួលនូវអារម្មណ៍មិនជាទីត្រេកអរដែលកើតអំពីចិត្តសម្ផស្សនៃសត្វទាំងឡាយនោះ ៗ នេះឯង ហៅថា ទោមនស្ស (សេចក្ដីអាក់អន់ចិត្ត) ។

ដូចម្ដេច ហៅថា ឧបាយាសៈ (សេចក្ដីខ្វាចផ្សាចិត្ត)? សេចក្ដី

ចង្អៀតចង្អល់ណែនក្នុងចិត្ត សេចក្ដីលំបាកខ្លាំងក្នុងចិត្ត សេចក្ដីតានតឹងចិត្តនៃពួកសត្វដែលប្រកបដោយសេចក្ដីវិនាសណាមួយ មានសេចក្ដីវិនាសព្រាត់ប្រាសនៃញាតិជាដើម ឬហេតុនៃទុក្ខណាមួយ មានការសម្លាប់ និងការចាប់ចងឃុំខាំងជាដើម កើតឡើងប៉ះពាល់គ្របសង្កត់ នេះឯង ហៅថា ឧបាយាសៈ (សេចក្ដីខ្វាចផ្សាក្នុងចិត្ត) ។

ដូចម្ដេច ហៅថា អប្បិយេហិ សម្បយោគទុក្ខ (ការជួបប្រសព្វជាមួយសត្វ និងសង្ខារទាំងឡាយដែលមិនជាទីស្រឡាញ់ជាទុក្ខ)? រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ទាំងឡាយណា មាននៅក្នុងលោកនេះ ដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត ពុំនោះសោត ជនទាំងឡាយណា ដែលមានសេចក្ដីប្រាថ្នានូវកម្មមិនចំរើន ប្រាថ្នានូវកម្មមិនជាប្រយោជន៍ ប្រាថ្នានូវកម្មមិនជាទីសប្បាយ ប្រាថ្នានូវកម្មដែលនាំមិនឲ្យមានសេចក្ដីក្សេមក្សាន្តចាកយោគៈ ការដើររួមគ្នា ការមកជួបប្រទះគ្នា ការនៅប្រប៉ូកប្របល់គ្នា ជាមួយអារម្មណ៍ទាំងឡាយនោះ ៗ ជាមួយជនទាំងឡាយនោះ ៗ នេះឯង ហៅថា អប្បិយេហិ សម្បយោគទុក្ខ (ការជួបប្រសព្វជាមួយសត្វ និងសង្ខារទាំងឡាយដែលមិនជាទីស្រឡាញ់ ជាទុក្ខ) ។

ដូចម្ដេច ហៅថា បិយេហិ វិប្បយោគទុក្ខ (ការព្រាត់ប្រាសចាកសត្វ និងសង្ខារទាំងឡាយដែលជាទីស្រឡាញ់ ជាទុក្ខ)? រូបារម្មណ៍ សទ្ទា-

រម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ទាំងឡាយណា មាននៅក្នុងលោកនេះ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ពុំនោះសោត ជនទាំងឡាយណា ដែលមានសេចក្តីប្រាថ្នានូវកម្មដ៏ចំរើន ប្រាថ្នានូវកម្មជាប្រយោជន៍ ប្រាថ្នានូវកម្មជាទីសប្បាយ ប្រាថ្នានូវកម្មដែលនាំឲ្យមានសេចក្តីក្សេមក្សាន្តចាកយោគៈ ទោះជាមាតាបិតាក្តី ជាបងប្អូនប្រុស ប្អូនបងប្អូនស្រីក្តី ជាមិត្ត ឬអាមាត្យក្តី ជាញាតិសាលោហិតក្តី ការមិនបានដើររួមគ្នា ការមិនបានមកជួបប្រទះគ្នា ការមិនបាននៅប្រឡូកប្រឡំគ្នាជាមួយអារម្មណ៍ទាំងឡាយនោះ ៗ ជាមួយជនទាំងឡាយនោះ ៗ នេះឯង ហៅថា បិយេហិ វិប្បយោគទុក្ខ (ការព្រាត់ប្រាសចាកសត្វនិងសង្ខារទាំងឡាយដែលជាទីស្រឡាញ់ ជាទុក្ខ) ។

ដូចម្តេច ហៅថា យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខ (ប្រាថ្នានូវហេតុណាមិនបានដូចប្រាថ្នា ការមិនបាននោះ ជាទុក្ខ)? សេចក្តីប្រាថ្នាកើតឡើងដល់សត្វទាំងឡាយ ដែលមានជាតិ ជរា ព្យាធិ និងមរណៈជាធម្មតា មានសេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយលំបាកចិត្ត សេចក្តីអាក់អន់ចិត្ត និងសេចក្តីខ្លោចផ្សាចិត្តជាធម្មតា ហើយប្រាថ្នាយ៉ាងនេះថា អើហ្ន៎! សូមឲ្យយើងទាំងឡាយ កុំគប្បីជាអ្នកមានទុក្ខមានជាតិ ជាដើមជាធម្មតាឡើយ ពុំនោះសោត ប្រាថ្នាថាសូមឲ្យទុក្ខទាំងឡាយមានជាតិជាដើមនោះ កុំគប្បីមកប៉ះពាល់ដល់យើងទាំងឡាយឡើយ ។ ហេតុ

នោះ សត្វទាំងឡាយក៏មិនគប្បីបានសម្រេចតាមសេចក្ដីប្រាថ្នារបស់ខ្លួនដោយពិត នេះឯង ឈ្មោះថា ប្រាថ្នានូវហេតុណា មិនបានដូចប្រាថ្នា ការមិនបាននោះ ចាត់ថាជាទុក្ខ ។ ម្យ៉ាងទៀត បុគ្គលប្រាថ្នានូវទ្រព្យសម្បត្តិណា ជាសវិញ្ញាណកទ្រព្យក្ដី ជាអវិញ្ញាណកទ្រព្យក្ដី ហើយមិនបាននូវទ្រព្យសម្បត្តិនោះតាមបំណងរបស់ខ្លួន នេះឯង ក៏ឈ្មោះថាប្រាថ្នានូវហេតុណា មិនបានដូចប្រាថ្នា ការមិនបានោះ ចាត់ថាជាទុក្ខដែរ ។

ដូចម្ដេច ហៅថា ដោយបំព្រួញមកគឺ ឧបាទានក្ខន្ធទាំង ៥ ចាត់ថាជាទុក្ខ ? ឧបាទានក្ខន្ធមាន ៥ គឺ រូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ។ ឧបា-ទានក្ខន្ធទាំង ៥ នេះ ជាខន្ធនៅប្រកបដោយអាសវៈនិងឧបាទាន ឬថាខន្ធមានឧបាទានជាអារម្មណ៍ ព្រោះថា ទុក្ខទាំងឡាយមានជាតិទុក្ខជាដើម ដែលកើតឡើងបៀតបៀននូវសត្វទាំងឡាយក្នុងភពទាំងពួង រមែងកើតឡើងអាស្រ័យនូវឧបាទានក្ខន្ធនេះឯងជាបច្ច័យ កាលបើឧបាទានក្ខន្ធរលត់អស់ហើយ ទុក្ខទាំងឡាយមានជាតិទុក្ខជាដើម ក៏រលត់ទៅជាមួយផងដែរ ហេតុតាំងនេះឯង ទើបហៅដោយបំប្រួញថា ឧបាទានក្ខន្ធទាំង ៥ ចាត់ថាជាទុក្ខ ។

ទុក្ខទាំងអស់នេះ ហៅថា ទុក្ខអរិយសច្ច ។

ទុក្ខសច្ច ចប់ ។

# សមុទយសច្ច

## ហេតុជាដែនកើតឡើងនៃទុក្ខជាការពិត

ដូចម្ដេច ហៅថា ទុក្ខសមុទយអរិយសច្ច? តណ្ហាណា ដែលតាក់តែង ធ្វើនូវភពថ្មីជាប្រក្រតី កើតលេតជាមួយនឹងនន្ទិរាគៈ(សេចក្ដីត្រេកត្រអាល) ត្រេកអរចំពោះក្នុងភពនោះៗ ឬក្នុងអារម្មណ៍នោះៗ តណ្ហានោះមាន ៣ យ៉ាងគឺ កាមតណ្ហា សេចក្ដីប្រាថ្នាក្នុងកាមគុណ ១ ភវតណ្ហា សេចក្ដីប្រាថ្នាក្នុងរូបភពនិងអរូបភព ដែលប្រកបដោយសស្សតទិដ្ឋ ១ វិភវតណ្ហា សេចក្ដីប្រាថ្នាឲ្យសូន្យចាកភព ប្រកបដោយឧច្ឆេទទិដ្ឋ ១ ។

តណ្ហារបស់បុគ្គលដែលលាយដោយរាគៈ (តម្រេក) ប្រព្រឹត្តទៅក្នុងកាមគុណ ៥ គឺ រូប សំឡេង ក្លិន រស សម្ផស្ស ឬថាកាមគុណទាំង៥ នេះ ជាអារម្មណ៍នាំឲ្យតណ្ហាកើតឡើង ហៅថា កាមតណ្ហា ។ តណ្ហារបស់យោគាវចរអ្នកបានឈានដែលលាយដោយរាគៈ ប្រព្រឹត្តទៅក្នុងរូប-ភពនិងអរូបភព ប្រកបដោយសស្សតទិដ្ឋិ គឺមានសេចក្ដីយល់ឃើញថា អារម្មណ៍នោះឯង ទៀងទាត់ឋិតថេរ មិនប្រែប្រួល ពុំនោះសោត សេចក្ដីត្រេកអររបស់យោគាវចរ ដែលឈ្លក់ជាប់នៅក្នុងឈាន ដោយសេចក្ដីយល់ឃើញថា ឈាននោះឯង មានសុខទៀងទាត់មិនប្រែប្រួល ហៅថា ភវតណ្ហា ។ តណ្ហារបស់បុគ្គលដែលលាយដោយរាគៈ ប្រព្រឹត្តទៅជាមួយឧច្ឆេទទិដ្ឋិ គឺមានសេចក្ដីយល់ឃើញថា អារម្មណ៍នោះឯង សូន្យឈឹង

ឥតមានសេសសល់ គឺយល់ថាស្លាប់ហើយសូន្យទៅតែម្តង ឥតមានកើតទៀតឡើយ ហៅថា វិភវតណ្ហា ។ បណ្តាតណ្ហាទាំង ៣ ដូចបានពោលមកហើយនោះ ក្នុងតណ្ហានីមួយ ៗ មាន ៣៦ គឺ កាមតណ្ហា ៣៦ ភវ. តណ្ហា ៣៦ វិភវតណ្ហា ៣៦ គឺយកអាយតនៈខាងក្នុង ៦ មានចក្ខាយតនៈជាដើមមកគុណនឹងតណ្ហាទាំង ៣ ត្រូវជាតណ្ហា ១៨ ឈ្មោះថា អជ្ឈត្តិកតណ្ហា, យកអាយតនៈខាងក្រៅ ៦ មានរូបាយតនៈជាដើម មកគុណនឹងតណ្ហាទាំង ៣ ត្រូវជាតណ្ហា ១៨ ឈ្មោះថា ពាហិទ្ធាតណ្ហា, អជ្ឈត្តិក-តណ្ហា ១៨ នឹងពាហិទ្ធាតណ្ហា ១៨ រួមជាតណ្ហា ៣៦; បាត់ទៅខាងអតីត ៣៦ អនាគត ៣៦ បច្ចុប្បន្ន ៣៦ ត្រូវជាតណ្ហា ១០៨ (ហៅថា អដ្ឋុត្ត-រសតតណ្ហា) ។

តណ្ហានោះ កាលដែលកើតឡើង តើកើតឡើងក្នុងទីណា ? កាលដែលជាប់នៅតើជាប់នៅក្នុងទីណា ? អារម្មណ៍ណា ក្នុងលោកដែលមានសភាពគួរស្រឡាញ់ គួរត្រេកអរ តណ្ហានោះ កាលដែលកើតឡើងរមែងកើតឡើងក្នុងអារម្មណ៍នោះ កាលដែលជាប់នៅ រមែងជាប់នៅក្នុងអារម្មណ៍នោះ ។ អារម្មណ៍អ្វីខ្លះក្នុងលោក ដែលមានសភាពគួរស្រឡាញ់គួរត្រេកអរ ? ។

## អាយតនៈខាងក្នុង ៦

ចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយ នឹងមនោ ក្នុងលោកជាអារម្មណ៍

ដែលមានសភាពគួរស្រឡាញ់ គួរត្រេកអរ តណ្ហាកាលដែលកើតឡើង រមែងកើតឡើងក្នុងអារម្មណ៍គឺចក្ខុជាដើមនោះ កាលដែលជាប់នៅ រមែងជាប់នៅក្នុងអារម្មណ៍គឺចក្ខុជាដើមនោះដែរ ។

អធិប្បាយ– មនុស្សសត្វទូទៅ តែងមានសេចក្ដីស្រឡាញ់រាងកាយរបស់ខ្លួនជាធម្មតា គ្មានអ្នកណាមួយបដិសេធថាស្អប់ឬមិនស្រឡាញ់រាងកាយរបស់ខ្លួនឡើយ និយាយថ្មីចំពោះរាងកាយដែលបរិបូណ៌ដោយអាការៈពេញលេញល្អ សូម្បីរាងកាយមានវិកលខ្វះខាតមិនល្អយ៉ាងណាក៏ដោយ គង់តែជាប់ចិត្តបញ្ចោសអង្អែលថ្នាក់ថ្នមបង់សុខ បង់រស់នៅជាធម្មតា ដូចយ៉ាងអាយតនៈខាងក្នុងទាំង ៦ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ មនោ កាលណាបើបុគ្គលយកកញ្ចក់មកឆ្លុះមើលរូបកាយរបស់ខ្លួនក្នុងថ្ងៃនៃកញ្ចក់ ឃើញភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ របស់ខ្លួន កាលនោះក៏កើតសេចក្ដីស្រឡាញ់ពេញចិត្ត បំរើនចិត្ត ត្រេកអរក្នុងចិត្ត រមែងសំគាល់ថា ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ របស់អាត្មាអញសមរម្យល្អគ្រប់កន្លែងទាំងអស់ ទាំងសំគាល់ឃើញថាមនោគឺចិត្តរបស់អាត្មាអញសោតទៀត ក៏ជាចិត្តថ្លៃថ្នាល្អ មិនមែនដូចជាចិត្តអ្នកដទៃទេ កាលបើសេចក្ដីស្រឡាញ់ពេញចិត្តរបស់ខ្លួនកើតឡើងយ៉ាងនេះហើយ ឈ្មោះថា តណ្ហាកើតឡើងអាស្រ័យនូវអាយតនៈខាងក្នុង ។

# អាយតនៈខាងក្រៅ ៦

រូបៈ សទ្ទៈ គន្ធៈ រសៈ ផោដ្ឋព្វៈ នឹង ធម្មៈ ក្នុងលោកដែលមាន សភាពគួរស្រឡាញ់ គួរគ្រេកអរ តណ្ហាកាលដែលកើតឡើងរមែងកើត ឡើងក្នុងអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើមនោះ កាលដែល ជាប់នៅ ក៏រមែងជាប់នៅក្នុងអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើម នោះដែរ ។

អធិប្បាយ– អាយតនៈខាងក្រៅទាំង ៦ គឺ រូប សំឡេង ក្លិន រស សម្ផស្ស ធម៌ កាលណាបើបុគ្គល បានជួបប្រទះឃើញរូបអ្វីមួយ ទោះ មានវិញ្ញាណក្តី ឥតវិញ្ញាណក្តី ដែលជារូបល្អ ក៏កើតសេចក្តីស្រឡាញ់ ពេញចិត្ត ហើយមានចំណង់ចង់បានរូបនោះ, បានស្តាប់ឮសំឡេងអ្វី នីមួយដែលពីរោះ ក៏កើតសេចក្តីរីករាយក្នុងចិត្ត ហើយចង់ស្តាប់សំឡេង នោះ, បានហិតឬធុំក្លិនអ្វីនីមួយដែលក្រអូប ក៏កើតសេចក្តីរីករាយក្នុងចិត្ត ហើយប្រាថ្នាចង់បានវត្ថុនោះ, បានលិឍភ្លក់ផ្លញក់ផ្លាប់នូវវត្ថុអ្វីនីមួយ ដែលឆ្ងាញ់ពិសា ក៏កើតសេចក្តីត្រេកអរក្នុងចិត្ត ហើយប្រាថ្នាចង់បាន រសនៃវត្ថុនោះ, បានប៉ះពាល់វត្ថុអ្វីនីមួយដោយកាយដែលមានសម្ផស្សល្អិត ទន់មានសំពត់អាវជាដើម ក៏កើតសេចក្តីស្រឡាញ់ពេញចិត្ត ហើយមាន ចំណង់ចង់បាននូវវត្ថុទាំងនោះ, បានរិះគិតនូវអារម្មណ៍ គឺធម៌ណានីមួយ ជាទីគាប់ចិត្ត ក៏កើតសេចក្តីរីករាយប្រាថ្នានូវអារម្មណ៍នោះ កាលបើសេចក្តី

ស្រឡាញ់ សេចក្ដីប្រាថ្នា របស់ខ្លួនកើតឡើងយ៉ាងនេះហើយ ឈ្មោះថា តណ្ហាកើតឡើងអាស្រ័យនូវអាយតនៈខាងក្រៅ ។

## វិញ្ញាណ ៦

ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយ-វិញ្ញាណ និងមនោវិញ្ញាណ ក្នុងលោកដែលមានសភាពគួរស្រឡាញ់ គួរត្រេកអរ ។ តណ្ហា កាលដែលកើតឡើង ក៏រមែងកើតឡើងក្នុងវិញ្ញាណទាំងឡាយមានចក្ខុវិញ្ញាណជាដើមនោះ កាលដែលជាប់នៅក៏រមែងជាប់នៅក្នុងវិញ្ញាណទាំងឡាយ មានចក្ខុវិញ្ញាណជាដើមនោះដែរ ។

អធិប្បាយ– វិញ្ញាណ ប្រែថា ធម្មជាតដឹងច្បាស់, វិញ្ញាណដែលកើតឡើងបាន លុះតែអាយតនៈខាងក្នុង និងអាយតនៈខាងក្រៅអាស្រ័យគ្នាទើបកើតឡើង សូមជ្រាបដូចតទៅនេះ ព្រោះអាស្រ័យនូវចក្ខុនិងរូប ទើបចក្ខុវិញ្ញាណកើតឡើងអាចឲ្យដឹងថា រូបរបស់នេះ រូបរបស់នោះ ល្អឬអាក្រក់ទៅបាន បើរូបនោះល្អជាទីគាប់ចិត្ត ក៏កើតសេចក្ដីប្រាថ្នាចំពោះរូបនោះ, ព្រោះអាស្រ័យនូវត្រចៀកនិងសំឡេង ទើបសោតវិញ្ញាណកើតឡើង អាចឲ្យដឹងថាជាសំឡេងនេះ សំឡេងនោះ ពីរោះឬមិនពីរោះ បើសំឡេងនោះពីរោះក៏កើតសេចក្ដីត្រេកអរប្រាថ្នាចំពោះសំឡេងនោះ, ព្រោះអាស្រ័យនូវច្រមុះនិងក្លិន ទើបឃានវិញ្ញាណកើតឡើង អាចឲ្យដឹងថាជាក្លិនវត្ថុនេះវត្ថុនោះ បើក្លិនវត្ថុនោះក្រអូបជាទីគាប់ចិត្ត ក៏កើតសេចក្ដីប្រាថ្នាក្នុងក្លិននោះ,

ព្រោះអាស្រ័យនូវអណ្ដាតនឹងរស ទើបជិវ្ហាវិញ្ញាណកើតឡើង អាចឲ្យដឹងថាវត្ថុនេះមានរសសាប ប្រៃ ជូរ ចត់ជាដើម ក៏កើតសេចក្ដីប្រាថ្នាក្នុងរសនៃវត្ថុដែលខ្លួនត្រូវការនោះ, ព្រោះអាស្រ័យនូវកាយនឹងផ្សព្វ ទើបកាយវិញ្ញាណកើតឡើង អាចឲ្យដឹងថា របស់នេះមានសម្ផស្សទន់ស្រួល ឬរឹងគ្រោតគ្រាត បើរបស់ណាមួយដែលមានសម្ផស្សទន់ស្រួលល្អជាទីគាប់ចិត្ត ក៏កើតសេចក្ដីប្រាថ្នាក្នុងសម្ផស្សនោះ, ព្រោះអាស្រ័យនូវចិត្តនឹងធម៌ ទើបមនោវិញ្ញាណកើតឡើង អាចឲ្យដឹងថាអារម្មណ៍នេះល្អ អារម្មណ៍នោះមិនល្អ បើអារម្មណ៍ណាដែលចិត្តរិះគិតឃើញថាល្អថាស្រួល ក៏កើតសេចក្ដីប្រាថ្នាចំពោះអារម្មណ៍នោះ ។ កាលបើសេចក្ដីស្រឡាញ់ សេចក្ដីប្រាថ្នារបស់ខ្លួនកើតឡើងយ៉ាងនេះហើយ ឈ្មោះថា តណ្ហាកើតឡើងក្នុងវិញ្ញាណទាំងឡាយ មានចក្ខុវិញ្ញាណជាដើម ដែលអាស្រ័យនូវអាយតនៈខាងក្នុងនឹងអាយតនៈខាងក្រៅ ។

## សម្ផស្ស ៦

ចក្ខុសម្ផស្ស សោតសម្ផស្ស ឃានសម្ផស្ស ជិវ្ហាសម្ផស្ស កាយសម្ផស្ស មនោសម្ផស្ស ក្នុងលោកដែលមានសភាពគួរស្រឡាញ់ គួរត្រេកអរ ។ តណ្ហាកាលដែលកើតឡើង ក៏រមែងកើតឡើងក្នុងសម្ផស្សទាំងឡាយ មានចក្ខុសម្ផស្សជាដើមនោះ កាលដែលជាប់នៅ ក៏រមែងជាប់នៅក្នុងសម្ផស្សទាំងឡាយមានចក្ខុសម្ផស្សជាដើមនោះដែរ ។

អធិប្បាយ– សម្ផស្ស ប្រែថា ការពាល់ត្រូវ ឬការប៉ះពាល់ គឺអាយតនៈខាងក្នុង ប៉ះពាល់នូវអាយតនៈខាងក្រៅ ឬអាយតនៈខាងក្រៅប៉ះពាល់នូវអាយតនៈខាងក្នុង អាស្រ័យគ្នានឹងគ្នាយ៉ាងនេះ ហៅថា សម្ផស្ស ។ ព្រោះអាស្រ័យចក្ខុនឹងរូប ទើបចក្ខុសម្ផស្សកើតឡើង, ព្រោះអាស្រ័យសោតៈនឹងសទ្ទៈ ទើបសោតសម្ផស្សកើតឡើង, ព្រោះអាស្រ័យឃានៈនឹងគន្ធៈ ទើបឃានសម្ផស្សកើតឡើង, ព្រោះអាស្រ័យជិវ្ហានឹងរស ទើបជិវ្ហាសម្ផស្សកើតឡើង, ព្រោះអាស្រ័យកាយនឹងផ្សព្វ ទើបកាយសម្ផស្សកើតឡើង, ព្រោះអាស្រ័យមនោនឹងធម៌ ទើបមនោសម្ផស្សកើតឡើង ។ ព្រោះហេតុនោះ តណ្ហា កាលដែលកើតឡើង រមែងកើតឡើងអាស្រ័យនូវសម្ផស្សទាំងឡាយ មានចក្ខុសម្ផស្សជាដើមនោះឯង ។

## វេទនា ៦

វេទនាដែលកើតអំពីចក្ខុសម្ផស្សក្តី វេទនាដែលកើតអំពីសោតសម្ផស្សក្តី វេទនាដែលកើតអំពីឃានសម្ផស្សក្តី វេទនាដែលកើតអំពីជិវ្ហាសម្ផស្សក្តី វេទនាដែលកើតអំពីកាយសម្ផស្សក្តី វេទនាដែលកើតអំពីមនោសម្ផស្សក្តី ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ គួរត្រេកអរ ។ តណ្ហាកាលដែលកើតឡើងរមែងកើតឡើងក្នុងវេទនាទាំងឡាយ មានវេទនាដែលកើតអំពីចក្ខុសម្ផស្សជាដើមនោះ កាលដែលជាប់នៅ រមែងជាប់នៅក្នុងវេទនាទាំងឡាយ មានវេទនាដែលកើតអំពីចក្ខុសម្ផស្សជាដើមនោះដែរ ។

អធិប្បាយ– វេទនាមានលក្ខណៈដឹងនូវអារម្មណ៍ ឬទទួលនូវអារម្មណ៍ផ្សេង ៗ វេទនានេះចែកចេញទៅតាមអារម្មណ៍នោះមាន ៥ យ៉ាងគឺ ក្នុងខណៈដែលមានសុខកើតឡើង ទទួលអារម្មណ៍ជាសុខនោះ បានឈ្មោះថា សុខវេទនា ១ ក្នុងខណៈដែលមានការឈឺចាប់ ឬមានភ័យព្រួយលំបាកកើតឡើងអំពីហេតុណាមួយ ហើយទទួលអារម្មណ៍ជាទុក្ខនោះ បានឈ្មោះថា ទុក្ខវេទនា ១ ក្នុងខណៈដែលមានសេចក្ដីរីករាយចិត្តកើតឡើងអំពីហេតុណាមួយ ទទួលអារម្មណ៍ជាសោមនស្សនោះ បានឈ្មោះថា សោមនស្ស-វេទនា ១ ក្នុងខណៈដែលមានសេចក្ដីអាក់អន់តូចចិត្តកើតឡើងអំពីហេតុណាមួយ ទទួលអារម្មណ៍ជាទោមនស្សនោះ បានឈ្មោះថា ទោមនស្ស-វេទនា ១ ក្នុងខណៈដែលចិត្តព្រងើយកណ្ដើយ តាំងនៅជាកណ្ដាល ទទួលអារម្មណ៍មិនជាទុក្ខ មិនជាសុខនោះ ហៅថា ឧបេក្ខាវេទនា ១ ។ បណ្ដាវេទនាទាំង ៥ យ៉ាងនោះ ក្នុងវេទនានីមួយ ៗ ចែកចេញទៅតាមទ្វារទាំង៦ គឺសុខវេទនាមាន ៦ មានចក្ខុសម្ផស្សជាសុខវេទនាជាដើម, ទុក្ខវេទនាមាន ៦ មានចក្ខុសម្ផស្សជាទុក្ខវេទនាជាដើម, សោមនស្សវេទនាមាន ៦ មានចក្ខុសម្ផស្សជាសោមនស្សវេទនាជាដើម, ទោមនស្សវេទនាមាន ៦ មានចក្ខុសម្ផស្សជាទោមនស្សវេទនាជាដើម, ឧបេក្ខាវេទនាមាន ៦ មានចក្ខុសម្ផស្សជាឧបេក្ខាវេទនាជាដើម; ព្រោះហេតុនោះ តណ្ហា ដែលកើតឡើង ព្រោះអាស្រ័យនូវវេទនាដែលកើតអំពីសម្ផស្ស គឺការប៉ះពាល់នៃ

អាយតនៈខាងក្នុង នឹងអាយតនៈខាងក្រៅ ដូចបានពោលមកហើយនោះ ឯង ៗ

## សញ្ញា ៦

រូបសញ្ញា សេចក្ដីសំគាល់នូវរូបារម្មណ៍ ១ សទ្ទសញ្ញា សេចក្ដីសំគាល់នូវសទ្ទារម្មណ៍ ១ គន្ធសញ្ញា សេចក្ដីសំគាល់នូវគន្ធារម្មណ៍ ១ រសសញ្ញា សេចក្ដីសំគាល់នូវរសារម្មណ៍ ១ ផោដ្ឋព្វសញ្ញា សេចក្ដីសំគាល់នូវផោដ្ឋព្វារម្មណ៍ ១ ធម្មសញ្ញា សេចក្ដីសំគាល់នូវធម្មារម្មណ៍ ១ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ គួរត្រេកអរ តណ្ហា កាលដែលកើតឡើង រមែងកើតក្នុងសេចក្ដីសំគាល់នូវអារម្មណ៍ទាំងឡាយ មានសេចក្ដីសំគាល់នូវរូបារម្មណ៍ជាដើមនោះ កាលដែលជាប់នៅ រមែងជាប់នៅក្នុងសេចក្ដីសំគាល់នូវអារម្មណ៍ទាំងឡាយ មានសេចក្ដីសំគាល់នូវរូបារម្មណ៍ជាដើមនោះដែរ ៗ ព្រោះហេតុនោះ តណ្ហា ដែលកើតឡើងអាស្រ័យសេចក្ដីសំគាល់នូវអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើម ដែលចូលមកតាមទ្វារទាំងឡាយ មានចក្ខុទ្វារជាដើម ៗ

## សញ្ចេតនា ៦

រូបសញ្ចេតនា ចំណុចចិត្តក្នុងរូបារម្មណ៍ ១ សទ្ទសញ្ចេតនា ចំណុចចិត្តក្នុងសទ្ទារម្មណ៍ ១ គន្ធសញ្ចេតនា ចំណុចចិត្តក្នុងគន្ធារម្មណ៍ ១ រសសញ្ចេតនា ចំណុចចិត្តក្នុងរសារម្មណ៍១ ផោដ្ឋព្វ-

សព្ទតណ្ហា ចំណុចចិត្តក្នុងផោដ្ឋព្វារម្មណ៍ ១ ធម្មតណ្ហាជា ចំណុចចិត្តក្នុងធម្មារម្មណ៍ ១ ក្នុងលោក ដែលជាធម្មជាតិគួរស្រឡាញ់ គួរត្រេកអរ តណ្ហា កាលដែលកើតឡើង រមែងកើតឡើងក្នុងចំណុចចិត្ត ក្នុងអារម្មណ៍ទាំងឡាយមានរូបារម្មណ៍ជាដើមនោះ កាលដែលជាប់នៅ រមែងជាប់នៅក្នុងចំណុចចិត្ត ក្នុងអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើមនោះដែរ ។

## តណ្ហា ៦

រូបតណ្ហា ចំណង់ក្នុងរូបារម្មណ៍ ១ សទ្ទតណ្ហា ចំណង់ក្នុងសទ្ទារម្មណ៍ ១ គន្ធតណ្ហា ចំណង់ក្នុងគន្ធារម្មណ៍ ១ រសតណ្ហា ចំណង់ក្នុងរសារម្មណ៍ ១ ផោដ្ឋព្វតណ្ហា ចំណង់ក្នុងផោដ្ឋព្វារម្មណ៍ ១ ធម្មតណ្ហា ចំណង់ក្នុងធម្មារម្មណ៍ ១ ក្នុងលោក ដែលជាធម្មជាតិគួរស្រឡាញ់ គួរត្រេកអរ តណ្ហា កាលដែលកើតឡើង រមែងកើតឡើងក្នុងចំណង់ក្នុងអារម្មណ៍ទាំងឡាយមានរូបារម្មណ៍ជាដើមនោះ កាលដែលជាប់នៅ រមែងជាប់នៅក្នុងចំណង់ក្នុងអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើមនោះដែរ ។

## វិតក្កៈ ៦

រូបវិតក្កៈ សេចក្តីត្រិះរិះនូវរូបារម្មណ៍ ១ សទ្ទវិតក្កៈ សេចក្តីត្រិះរិះនូវសទ្ទារម្មណ៍ ១ គន្ធវិតក្កៈ សេចក្តីត្រិះរិះនូវគន្ធារម្មណ៍ ១

រសវិតក្កៈ សេចក្តីត្រិះរិះនូវរសារម្មណ៍ ១ ផោដ្ឋព្វវិតក្កៈ សេចក្តីត្រិះរិះនូវផោដ្ឋព្វារម្មណ៍ ១ ធម្មវិតក្កៈ សេចក្តីត្រិះរិះនូវធម្មារម្មណ៍ ១ ក្នុងលោក ដែលជាសភាវៈគួរស្រឡាញ់ គួរត្រេកអរ តណ្ហា កាលដែលកើតឡើង រមែងកើតឡើងក្នុងសេចក្តីត្រិះរិះនូវអារម្មណ៍ទាំងឡាយ មានសេចក្តីត្រិះរិះនូវរូបារម្មណ៍ជាដើមនោះ កាលដែលដាប់ទៅ រមែងដាប់ទៅក្នុងសេចក្តីត្រិះរិះនូវអារម្មណ៍ទាំងឡាយ មានសេចក្តីត្រិះរិះនូវរូបារម្មណ៍ជាដើមនោះដែរ ។

## វិចារៈ ៦

រូបវិចារៈ ការពិចារណានូវរូបារម្មណ៍ ១ សទ្ទវិចារៈ ការពិចារណានូវសទ្ទារម្មណ៍ ១ គន្ធវិចារៈ ការពិចារណានូវគន្ធារម្មណ៍ ១ រសវិចារៈ ការពិចារណានូវរសារម្មណ៍ ១ ផោដ្ឋព្វវិចារៈ ការពិចារណានូវផោដ្ឋព្វារម្មណ៍ ១ ធម្មវិចារៈ ការពិចារណានូវធម្មារម្មណ៍ ១ ក្នុងលោក ដែលជាសភាវៈគួរស្រឡាញ់ គួរត្រេកអរ ។ តណ្ហា កាលកើតឡើង រមែងកើតឡើងក្នុងការពិចារណានូវអារម្មណ៍ទាំងឡាយ មានការពិចារណានូវរូបារម្មណ៍ជាដើមនោះ កាលដែលដាប់ទៅ រមែងដាប់ទៅក្នុងការពិចារណានូវអារម្មណ៍ទាំងឡាយ មានការពិចារណានូវរូបារម្មណ៍ជាដើមនោះដែរ ។

សេចក្តីដូចបានពោលមកទាំងប៉ុន្មាននេះឯង ហៅថា ទុក្ខសមុទយ-

អរិយសច្ច ។

សមុទយសច្ច ចប់ ។

# និរោធសច្ច

ធម៌ជាគ្រឿងរលត់ទៅនៃទុក្ខជាការពិត

ដូចម្តេច ហៅថា ទុក្ខនិរោធអរិយសច្ច ? ការរលត់នៃតណ្ហានោះ ដោយមិនមានសេសសល់ ការលះបង់ ការរលាស់ចោល ការជម្រុះចោល និងការមិនមានសេចក្តីអាល័យចំពោះតណ្ហានោះឯង ហៅថា ទុក្ខនិរោធអរិយសច្ច ។

ពាក្យថា ការរលត់នៃតណ្ហាដោយមិនមានសេសសល់ក្តី ការលះបង់ក្តី ការរលាស់ចោលក្តី ការជម្រុះចោលក្តី ការមិនមានសេចក្តីអាល័យក្តី ចំពោះតណ្ហានោះ ការអស់នៃរាគៈក្តី ការអស់នៃទោសៈក្តី ការអស់នៃមោហៈក្តី ការអស់នៃតណ្ហាក្តី មានប៉ុណ្ណេះជាដើម ពាក្យទាំងអស់នេះជាឈ្មោះរបស់និព្វាន ឬជាពាក្យសម្រាប់ផ្លាស់ប្តូរហៅឈ្មោះនិព្វាន តាមន័យនេះឃើញថានិព្វានមានច្រើនយ៉ាងណាស់ ប៉ុន្តែដែលពិតនោះ និព្វានមានតែមួយ ឯនិព្វានដែលមានឈ្មោះច្រើនយ៉ាងដូច្នោះ ដោយអំណាចនិព្វានជាប្រតិបក្សនឹងសង្ខតធម៌ទាំងពួង ឬជាប្រព្រឹត្តទៅតាមឈ្មោះនៃសង្ខតធម៌ទាំងពួងប៉ុណ្ណោះឯង ។ និព្វានមានតែមួយដូចគ្នានឹងចិត្តដែរ តាមពិតចិត្តនោះមានតែមួយ ប៉ុន្តែដែលមានឈ្មោះប្រមាណជាទៅ ៨៩ ដួង ឬ ១២១

ដូននោះ  គឺឲ្យឈ្មោះទៅតាមអារម្មណ៍របស់ចិត្ត ឬឲ្យឈ្មោះទៅតាមវិថីរបស់ចិត្ត ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ផ្សេង ៗ ប៉ុណ្ណោះ ។

តណ្ហាដែលកើតឡើងព្រោះអាស្រ័យនូវអារម្មណ៍ជាបច្ច័យ តណ្ហាដែលអស់ទៅ សូន្យទៅ រលត់ទៅមិនមានសេសសល់ ព្រោះអាស្រ័យនូវនិព្វាន បុគ្គលបានដល់និព្វានដរាបណា តណ្ហាឈ្មោះថាអស់រលត់សូន្យទៅដរាបនោះដែរ ព្រោះហេតុនោះបុគ្គលគួរពិចារណាថា តើប្រតិបត្តិយ៉ាងណាដែលនាំឲ្យតណ្ហានោះរលត់ទៅបាន គប្បីជ្រាបតាមន័យនៃព្រះពុទ្ធភាសិតដូចតទៅនេះ ៖

ចុះតណ្ហានោះ កាលដែលបុគ្គលលះបង់ តើលះបង់ក្នុងទីណា ? កាលដែលរលត់ទៅ តើរលត់ទៅក្នុងទីណា ? អារម្មណ៍ណាក្នុងលោកដែលមានសភាពគួរស្រឡាញ់ គួរត្រេកអរ តណ្ហានោះ កាលដែលបុគ្គលលះបង់ រមែងលះបង់ក្នុងអារម្មណ៍នោះ កាលដែលរលត់ទៅ រមែងរលត់ទៅក្នុងអារម្មណ៍នោះដែរ ។ អារម្មណ៍អ្វីខ្លះក្នុងលោក ដែលមានសភាពគួរស្រឡាញ់ គួរត្រេកអរ?

## អាយតនៈខាងក្នុង ៦

ចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយ និងមនោ ក្នុងលោក ដែលជាអារម្មណ៍គួរស្រឡាញ់ គួរត្រេកអរ តណ្ហា កាលដែលបុគ្គលលះបង់ រមែងលះបង់ក្នុងអារម្មណ៍មានចក្ខុជាដើមនោះ កាលដែលរលត់ទៅ រមែង

រលត់ទៅក្នុងអារម្មណ៍មានចក្ខុជាដើមនោះដែរ ។

## អាយតនៈខាងក្រៅ ៦

រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ និងធម្មារម្មណ៍ ក្នុងលោក ដែលជាអារម្មណ៍គួរស្រឡាញ់ គួរត្រេកអរ តណ្ហា កាលដែលបុគ្គលលះបង់ រមែងលះបង់ក្នុងអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើមនោះ កាលដែលរលត់ទៅ រមែងរលត់ទៅក្នុងអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើមនោះដែរ ។

## វិញ្ញាណ ៦

ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយៈ-វិញ្ញាណ និងមនោវិញ្ញាណ ក្នុងលោក ដែលជាធម្មជាតគួរស្រឡាញ់ គួរត្រេកអរ តណ្ហា កាលដែលបុគ្គលលះបង់ រមែងលះបង់ក្នុងវិញ្ញាណទាំងឡាយ មានចក្ខុវិញ្ញាណជាដើមនោះ កាលដែលរលត់ទៅ រមែងរលត់ទៅក្នុងវិញ្ញាណទាំងឡាយ មានចក្ខុវិញ្ញាណជាដើមនោះដែរ ។

## សម្ផស្ស ៦

ចក្ខុសម្ផស្ស សោតសម្ផស្ស ឃានសម្ផស្ស ជិវ្ហាសម្ផស្ស កាយ-សម្ផស្ស និងមនោសម្ផស្ស ក្នុងលោក ដែលជាសភាវៈគួរស្រឡាញ់ គួរត្រេកអរ តណ្ហា កាលដែលបុគ្គលលះបង់ រមែងលះបង់ក្នុងសម្ផស្សទាំងឡាយ មានចក្ខុសម្ផស្សជាដើមនោះ កាលដែលរលត់ទៅ រមែងរលត់

ទៅក្នុងសម្ផស្សទាំងឡាយ មានចក្ខុសម្ផស្សជាដើមនោះដែរ ។

## វេទនា ៦

វេទនាដែលកើតអំពីចក្ខុសម្ផស្ស វេទនាដែលកើតអំពីសោតសម្ផស្ស វេទនាដែលកើតអំពីឃានសម្ផស្ស វេទនាដែលកើតអំពីជិវ្ហាសម្ផស្ស វេទនាដែលកើតអំពីកាយសម្ផស្ស វេទនាដែលកើតអំពីមនោសម្ផស្ស ក្នុងលោកដែលជាធម្មជាតិគួរស្រឡាញ់ គួរត្រេកអរ តណ្ហា កាលដែលបុគ្គលលះបង់ រមែងលះបង់ក្នុងវេទនាដែលកើតអំពីសម្ផស្សទាំងឡាយ មានវេទនាដែលកើតអំពីចក្ខុសម្ផស្សជាដើមនោះ កាលដែលរលត់ទៅ រមែងរលត់ទៅក្នុងវេទនាដែលកើតអំពីសម្ផស្សទាំងឡាយ មានវេទនាដែលកើតអំពីចក្ខុសម្ផស្សជាដើមនោះដែរ ។

## សញ្ញា ៦

សេចក្ដីសំគាល់នូវរូបារម្មណ៍ សេចក្ដីសំគាល់នូវសទ្ទារម្មណ៍ សេចក្ដីសំគាល់នូវគន្ធារម្មណ៍ សេចក្ដីសំគាល់នូវរសារម្មណ៍ សេចក្ដីសំគាល់នូវផោដ្ឋព្វារម្មណ៍ និងសេចក្ដីសំគាល់នូវធម្មារម្មណ៍ ក្នុងលោក ដែលជាធម្មជាតិគួរស្រឡាញ់ គួរត្រេកអរ តណ្ហា កាលដែលបុគ្គលលះបង់ រមែងលះបង់ក្នុងសេចក្ដីសំគាល់នូវអារម្មណ៍ទាំងឡាយ មានសេចក្ដីសំគាល់នូវរូបារម្មណ៍ជាដើមនោះ កាលដែលរលត់ទៅ រមែងរលត់ទៅក្នុងសេចក្ដីសំគាល់នូវអារម្មណ៍ទាំងឡាយ មានសេចក្ដីសំគាល់នូវរូបារម្មណ៍ជាដើម

នោះដែរ ។

# សញ្ចេតនា ៦

ចំណុចចិត្តក្នុងរូបារម្មណ៍ ចំណុចចិត្តក្នុងសទ្ទារម្មណ៍ ចំណុចចិត្តក្នុងគន្ធារម្មណ៍ ចំណុចចិត្តក្នុងរសារម្មណ៍ ចំណុចចិត្តក្នុងផោដ្ឋព្វារម្មណ៍ និងចំណុចចិត្តក្នុងធម្មារម្មណ៍ ក្នុងលោក ដែលជាធម្មជាតិគួរស្រឡាញ់ គួរត្រេកអរ តណ្ហា កាលដែលបុគ្គលលះបង់ រមែងលះបង់ក្នុងចំណុចចិត្តក្នុងអារម្មណ៍ទាំងឡាយ មានចំណុចចិត្តក្នុងរូបារម្មណ៍ជាដើមនោះ កាលដែលរលត់ទៅ ក៏រមែងរលត់ទៅក្នុងចំណុចចិត្តក្នុងអារម្មណ៍ទាំងឡាយ មានចំណុចចិត្តក្នុងរូបារម្មណ៍ជាដើមនោះដែរ ។

# តណ្ហា ៦

ចំណង់ក្នុងរូបារម្មណ៍ ចំណង់ក្នុងសទ្ទារម្មណ៍ ចំណង់ក្នុងគន្ធារម្មណ៍ ចំណង់ក្នុងរសារម្មណ៍ ចំណង់ក្នុងផោដ្ឋព្វារម្មណ៍ និងចំណង់ក្នុងធម្មារម្មណ៍ ក្នុងលោក ដែលជាធម្មជាតិគួរស្រឡាញ់ គួរត្រេកអរ តណ្ហា កាលដែលបុគ្គលលះបង់ រមែងលះបង់ក្នុងចំណង់ក្នុងអារម្មណ៍ទាំងឡាយ មានចំណង់ក្នុងរូបារម្មណ៍ជាដើមនោះ កាលដែលរលត់ទៅ រមែងរលត់ទៅក្នុងចំណង់ក្នុងអារម្មណ៍ទាំងឡាយ មានចំណង់ក្នុងរូបារម្មណ៍ជាដើមនោះដែរ ។

## វិតក្កៈ ៦

សេចក្ដីត្រិះរិះនូវរូបារម្មណ៍ សេចក្ដីត្រិះរិះនូវសទ្ទារម្មណ៍ សេចក្ដីត្រិះរិះនូវគន្ធារម្មណ៍ សេចក្ដីត្រិះរិះនូវរសារម្មណ៍ សេចក្ដីត្រិះរិះនូវផោដ្ឋព្វារម្មណ៍ នឹងសេចក្ដីត្រិះរិះនូវធម្មារម្មណ៍ ក្នុងលោក ដែលជាសភាវៈគួរស្រឡាញ់ គួរត្រេកអរ តណ្ហា កាលដែលបុគ្គលលះបង់ រមែងលះបង់ក្នុងសេចក្ដីត្រិះរិះនូវអារម្មណ៍ទាំងឡាយ មានសេចក្ដីត្រិះរិះនូវរូបារម្មណ៍ជាដើមនោះ កាលដែលរលត់ទៅ រមែងរលត់ទៅក្នុងសេចក្ដីត្រិះរិះនូវអារម្មណ៍ទាំងឡាយ មានសេចក្ដីត្រិះរិះនូវរូបារម្មណ៍ជាដើមនោះដែរ ។

## វិចារៈ ៦

ការពិចារណានូវរូបារម្មណ៍ ការពិចារណានូវសទ្ទារម្មណ៍ ការពិចារណានូវគន្ធារម្មណ៍ ការពិចារណានូវរសារម្មណ៍ ការពិចារណានូវផោដ្ឋព្វារម្មណ៍ នឹងការពិចារណានូវធម្មារម្មណ៍ ក្នុងលោក ដែលជាសភាវៈគួរស្រឡាញ់ គួរត្រេកអរ តណ្ហា កាលដែលបុគ្គលលះបង់ រមែងលះបង់ក្នុងការពិចារណានូវអារម្មណ៍ទាំងឡាយ មានការពិចារណានូវរូបារម្មណ៍ជាដើមនោះ កាលដែលរលត់ទៅ រមែងរលត់ទៅក្នុងការពិចារណានូវអារម្មណ៍ទាំងឡាយ មានការពិចារណានូវរូបារម្មណ៍ជាដើមនោះដែរ ។

សេចក្ដីដូចបានពោលមកទាំងប៉ុន្មាននេះឯង ហៅថា ទុក្ខនិរោធ-

អរិយសច្ច ។

និរោធសច្ច ចប់ ។

# មគ្គសច្ច

ហេតុជាផ្លូវប្រតិបត្តិដល់នូវកិរិយារលត់នៃទុក្ខជាការពិត

ដូចម្តេច ហៅថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ? អរិយមគ្គដែលប្រកបដោយអង្គ ៨ ប្រការ ជាបដិបទាដល់នូវការរលត់ទុក្ខ ហៅថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។ អរិយមគ្គដែលប្រកបដោយអង្គ ៨ ប្រការនោះតើដូចម្តេចខ្លះ ? គឺ សម្មាទិដ្ឋិ (សេចក្តីយល់ឃើញត្រូវ) ១ សម្មាសង្កប្បៈ (សេចក្តីត្រិះរិះត្រូវ) ១ សម្មាវាចា (ការនិយាយពាក្យត្រូវ) ១ សម្មាកម្មន្តៈ (ការងារត្រូវ) ១ សម្មាអាជីវៈ (ការចិញ្ចឹមជីវិតត្រូវ) ១ សម្មា-វាយាមៈ (សេចក្តីព្យាយាមត្រូវ) ១ សម្មាសតិ (សេចក្តីនឹករលឹកត្រូវ) ១ សម្មាសមាធិ (ការដំកល់ចិត្តឲ្យនឹងធឹងត្រូវ) ១ ។

ដូចម្តេច ហៅថា សម្មាទិដ្ឋិ (សេចក្តីយល់ឃើញត្រូវ) ? ប្រាជ្ញាយល់ឃើញច្បាស់ក្នុងកងទុក្ខទាំង ១២ មានជាតិទុក្ខជាដើមក្តី ប្រាជ្ញាយល់ឃើញច្បាស់ក្នុងធម៌ជាហេតុដែលជាទីប្រជុំនាំឲ្យកើតទុក្ខ គឺតណ្ហាក្តី ប្រាជ្ញាយល់ឃើញច្បាស់ក្នុងធម៌គឺនិព្វាន ដែលជាទីរលត់នៃទុក្ខក្តី ប្រាជ្ញាយល់ឃើញច្បាស់ក្នុងបដិបទា (សេចក្តីប្រតិបត្តិ) ជាដំណើរទៅកាន់ទីរលត់នៃទុក្ខក្តី ប្រាជ្ញាយល់ឃើញយ៉ាងនេះឯង ហៅថា សម្មាទិដ្ឋិ (សេចក្តី

យល់ឃើញត្រូវ) ។

ដូចម្ដេច ហៅថា សម្មាសង្កប្បៈ(សេចក្ដីត្រិះរិះត្រូវ) ? សេចក្ដីត្រិះរិះដើម្បីចេញចាកកាមក្ដី សេចក្ដីត្រិះរិះដើម្បីមិនព្យាបាទគេក្ដី សេចក្ដីត្រិះរិះដើម្បីមិនបៀតបៀនគេក្ដី សេចក្ដីត្រិះរិះយ៉ាងនេះឯង ហៅថា សម្មាសង្កប្បៈ (សេចក្ដីត្រិះរិះត្រូវ) ។

ដូចម្ដេច ហៅថា សម្មាវាចា (ការនិយាយពាក្យត្រូវ)? ចេតនាវៀរចាកការនិយាយពាក្យមិនពិតក្ដី ចេតនាវៀរចាកសំដីញុះញង់ក្ដី ចេតនាវៀរចាកសំដីទ្រគោះបោះបោកក្ដី ចេតនាវៀរចាកការនិយាយពាក្យពេយពាយឥតប្រយោជន៍ក្ដី ការវៀរចាកពាក្យទាំងនេះឯង ហៅថា សម្មាវាចា (ការនិយាយពាក្យត្រូវ) ។

ដូចម្ដេច ហៅថា សម្មាកម្មន្តៈ (ការងារត្រូវ)? ចេតនាវៀរចាកការញាំងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លងក្ដី ចេតនាវៀរចាកការកាន់យកនូវទ្រព្យដែលគេមិនបានឲ្យក្ដី ចេតនាវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយក្ដី ការវៀរចាកអំពើទាំងនេះឯង ហៅថា សម្មាកម្មន្តៈ (ការងារត្រូវ) ។

ដូចម្ដេច ហៅថា សម្មាអាជីវៈ (ការចិញ្ចឹមជីវិតត្រូវ)? អរិយសាវកលះបង់នូវមិច្ឆាអាជីវៈ (ការចិញ្ចឹមជីវិតខុស) ហើយសម្រេចនូវការចិញ្ចឹមជីវិតត្រូវ ។

ផ្នែកខាងបព្វជិត មានការវៀរចាកបាបធម៌ ៤ និងអនេសនៈ ២១ ជា

ដើម ផ្នែកខាងគ្រហស្ថ មានការវៀរចាកជំនួញខុស ៥ យ៉ាងជាដើម ការវៀរចាកអំពើចិញ្ចឹមជីវិតខុសទាំងនេះឯង ហៅថា សម្មាអាជីវៈ (ការចិញ្ចឹមជីវិតត្រូវ) ។

ដូចម្តេច ហៅថា សម្មាវាយាមៈ (សេចក្តីព្យាយាមត្រូវ)? ភិក្ខុ ញុំាងឆន្ទៈឲ្យកើតប្រឹងប្រែងប្រារព្ធនូវព្យាយាម ផ្គងចិត្តទុកឲ្យមាំ ដើម្បីញុំាងធម៌ទាំងឡាយ ជាអកុសលដ៏លាមកដែលមិនទាន់កើត កុំឲ្យកើតឡើងបាន ។ ភិក្ខុ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែងប្រារព្ធនូវព្យាយាម ផ្គងចិត្តទុកឲ្យមាំ ដើម្បីលះបង់នូវធម៌ទាំងឡាយ ជាអកុសលដ៏លាមកដែលកើតឡើងហើយ ។ ភិក្ខុ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែងប្រារព្ធនូវព្យាយាម ផ្គងចិត្តទុកឲ្យមាំ ដើម្បីញុំាងធម៌ទាំងឡាយជាកុសល ដែលមិនទាន់កើតឲ្យកើតឡើង ។ ភិក្ខុ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែងប្រារព្ធនូវព្យាយាម ផ្គងចិត្តទុកឲ្យមាំ ដើម្បីញុំាងធម៌ទាំងឡាយជាកុសលដែលកើតឡើងហើយ ឲ្យបានឋិតថេរ កុំឲ្យក្សុបក្សាំងបាត់ទៅវិញ ឲ្យបានចំរើនធំទូលាយ ពេញបរិបូណ៌ក្រៃលែងឡើង ។ ការតាំងសេចក្តីព្យាយាមដូច្នេះឯង ហៅថា សម្មាវាយាមះ (សេចក្តីព្យាយាមត្រូវ) ។

ដូចម្តេច ហៅថា សម្មាសតិ (សេចក្តីរឭកត្រូវ)? ភិក្ខុ មានសេចក្តីព្យាយាមដុតបំផ្លាញនូវពួកកិលេសក្នុងភពទាំង ៣ ប្រកបដោយសម្បជញ្ញៈ (សេចក្តីដឹងខ្លួន) ទាំងប្រកបដោយសតិជាគ្រឿងកំណត់ផង

ពិចារណាឃើញនូវកាយក្នុងកាយ ហើយបន្ទោបង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោក ។ ភិក្ខុ មានសេចក្ដីព្យាយាមដុតបំផ្លាញនូវពួកកិលេសក្នុងភពទាំង ៣ ប្រកបដោយសម្បជញ្ញៈ ទាំងប្រកបដោយសតិជាគ្រឿងកំណត់ផង ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ ហើយបន្ទោបង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោក ។ ភិក្ខុ មានសេចក្ដីព្យាយាមដុតបំផ្លាញនូវពួកកិលេសក្នុងភពទាំង ៣ ប្រកបដោយសម្បជញ្ញៈ ទាំងប្រកបដោយសតិជាគ្រឿងកំណត់ផង ពិចារណាឃើញនូវចិត្តក្នុងចិត្ត ហើយបន្ទោបង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោក ។ ភិក្ខុ មានសេចក្ដីព្យាយាមដុតបំផ្លាញនូវពួកកិលេសក្នុងភពទាំង ៣ ប្រកបដោយសម្បជញ្ញៈ ទាំងប្រកបដោយសតិជាគ្រឿងកំណត់ផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ហើយបន្ទោបង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោក ។ ការតាំងស្មារតីពិចារណាឃើញដូច្នេះឯង ហៅថា សម្មាសតិ (សេចក្ដីនឹករលឹកត្រូវ) ។

ដូចម្ដេច ហៅថា សម្មាសមាធិ (ការដំកល់ចិត្តនឹងធឹងត្រូវ)? ភិក្ខុស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈានប្រកបដោយវិតក្កៈនិងវិចារៈ មានតែបីតិនិងសុខ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ លុះរម្ងាប់នូវវិតក្កៈនិងវិចារៈរួចហើយ ក៏ចូលកាន់ទុតិយជ្ឈានដែលមានសទ្ធា

ដ៏ថ្លាផូរផង់ តាំងនៅខាងក្នុង មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខៈដែលកើតអំពីសមាធិ ។ ភិក្ខុ នោះជាអ្នកព្រងើយកន្តើយ ព្រោះប្រាសចាកតម្រេកក្នុងបីតិ ទាំងស្ងប់ចាកវិតក្កៈនឹងវិចារៈផង មានសតិសម្បជញ្ញៈផង ទទួលនូវសេចក្តីសុខដោយនាមកាយផង អរិយបុគ្គលទាំងឡាយ តែងពោលសរសើរនូវបុគ្គលដែលបាននូវតតិយជ្ឈានណា ថាជាអ្នកព្រងើយកន្តើយ មានស្មារតី មានប្រក្រតីនៅជាសុខ ក៏ចូលកាន់តតិយជ្ឈាននោះ ។ ភិក្ខុ ចូលកាន់ចតុត្ថជ្ឈាន មានស្មារតីដ៏បរិសុទ្ធដែលកើតអំពីឧបេក្ខា ឥតទុក្ខឥតសុខ ព្រោះលះបង់នូវសុខផង ព្រោះលះបង់នូវទុក្ខផង ព្រោះអស្តង្គតរលត់សោមនស្សនឹងទោមនស្សទាំងឡាយអំពីមុនផង ក៏សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ នេះឯង ហៅថា សម្មាសមាធិ (ការដំកល់ចិត្តនឹងធឹងត្រូវ) ។

មគ្គសច្ច ចប់ ។

តមក ភិក្ខុនោះ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ជាខាងក្នុងគឺធម៌របស់ខ្លួនផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ជាខាងក្រៅគឺធម៌របស់អ្នកដទៃផង ឈ្មោះថា ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយទាំងខាងក្នុងទាំងខាងក្រៅ ភិក្ខុនោះ ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងធម៌ទាំងឡាយផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយផង ឈ្មោះថា ពិចារណាឃើញនូវធម៌ដែលប្រជុំ

កើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយ ។ មួយវិញទៀត ស្មារតីរបស់ភិក្ខុនោះ ក៏តាំងឡើងប្រាកដថា ធម៌ទាំងឡាយនេះ គ្រាន់តែជាធម៌ប៉ុណ្ណោះឯង មិនមែនសត្វ មិនមែនបុគ្គល មិនមែនស្ត្រី មិនមែនបុរសទេ ការពិចារណាឃើញដូច្នេះកំណត់ដើម្បីឲ្យចំរើនប្រាជ្ញា ឲ្យមានស្មារតីវឹងប៉ុនប៉ុណ្ណោះ ដោយអំណាចនៃការពិចារណាឃើញដូច្នេះ ចិត្តរបស់ភិក្ខុនោះ ក៏មិនជាប់ជំពាក់ មិនអាស្រ័យនៅដោយតណ្ហានឹងទិដ្ឋិផង ទាំងមិនមានសេចក្តីប្រកៀកប្រកាន់នូវអ្វីនីមួយតិចតួចក្នុងលោកផង ។

សេចក្តីដែលពោលមកនេះ ហៅថា ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយគឺ អរិយសច្ច ៤ ។

សច្ចបព្វៈ ចប់ ។

ធម្មានុបស្សនាសតិបដ្ឋាន ចប់ ។

# សតិបដ្ឋានភាវនានិសង្ស

## អានិសង្សនៃការចំរើននូវសតិបដ្ឋាន

ព្រះសម្មាសម្ពុទ្ធ លុះសម្តែងសតិបដ្ឋានទាំង ៤ ចប់ហើយ ក៏ទ្រង់សម្តែងអំពីអានិសង្សនៃការចំរើននូវសតិបដ្ឋានតទៅទៀត ដោយព្រះពុទ្ធ-ភាសិតថា ម្នាលភិក្ខុទាំងឡាយ បើបុគ្គលណាមួយ ទោះភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ចំរើននូវសតិបដ្ឋានទាំងឡាយ ៤ នេះ តាមលំ-ដាប់នៃវិធីចំរើនដែលតថាគតបានពោលមកហើយយ៉ាងនេះ (បានចំរើន)

អស់ ៧ឆ្នាំ, បណ្ដាផលទាំងឡាយពីរ គឺអនាគាមិផលនឹងអរហត្តផល ផលណាមួយ គង់នឹងបានសម្រេចដល់បុគ្គលនោះតាមប្រាថ្នាដោយពិត គឺនឹងបានសម្រេចនូវភាពជាអរហន្តក្នុងបច្ចុប្បន្ន ពុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់នៅ ក៏គង់នឹងបានសម្រេចនូវភាពជាអនាគាមិបុគ្គលពុំខាន ។

ម្នាលភិក្ខុទាំងឡាយ កុំបាច់ដល់ទៅអស់ ៧ ឆ្នាំឡើយ, បើបុគ្គលណាមួយ ទោះភិក្ខុក្ដី ភិក្ខុនីក្ដី ឧបាសកក្ដី ឧបាសិកាក្ដី ចំរើននូវសតិបដ្ឋានទាំងឡាយ ៤ នេះ តាមលំដាប់នៃវិធីចំរើន ដែលតថាគតបានពោលមកហើយយ៉ាងនេះ អស់ ៦ ឆ្នាំក្ដី អស់ ៥ ឆ្នាំក្ដី អស់ ៤ ឆ្នាំក្ដី អស់ ៣ ឆ្នាំក្ដី អស់ ២ ឆ្នាំក្ដី អស់ ១ ឆ្នាំក្ដី, បណ្ដាផលទាំងឡាយពីរ ផលណាមួយ គង់នឹងបានសម្រេចដល់បុគ្គលនោះតាមប្រាថ្នាដោយពិត គឺនឹងបានសម្រេចនូវភាពជាអរហន្តក្នុងបច្ចុប្បន្ន ពុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់នៅ ក៏គង់នឹងបានសម្រេចនូវភាពជាអនាគាមិបុគ្គលពុំខាន ។

ម្នាលភិក្ខុទាំងឡាយ កុំបាច់ដល់ទៅអស់ ១ ឆ្នាំឡើយ, បើបុគ្គលណាមួយ ទោះភិក្ខុក្ដី ភិក្ខុនីក្ដី ឧបាសកក្ដី ឧបាសិកាក្ដី ចំរើននូវសតិបដ្ឋានទាំងឡាយ ៤ នេះ តាមលំដាប់នៃវិធីចំរើន ដែលតថាគតបានពោលមកហើយយ៉ាងនេះ, អស់ ៧ ខែ, បណ្ដាផលទាំងឡាយពីរ ផលណាមួយ គង់នឹងបានសម្រេចដល់បុគ្គលនោះតាមប្រាថ្នាដោយពិត គឺនឹងបានសម្រេចនូវភាពជាអរហន្តក្នុងបច្ចុប្បន្ន ពុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់

ទៅ ក៏គង់នឹងបានសម្រេចនូវភាពជាអនាគាមិបុគ្គលពុំខាន ។

ម្នាលភិក្ខុទាំងឡាយ កុំបាច់ដល់ទៅអស់ ៧ ខែឡើយ. បើបុគ្គលណាមួយ ទោះភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ចំរើននូវសតិបដ្ឋានទាំងឡាយ ៤ នេះ តាមលំដាប់នៃវិធីចំរើន ដែលតថាគតបានពោលមកហើយយ៉ាងនេះ អស់ ៦ ខែក្តី អស់ ៥ ខែក្តី អស់ ៤ ខែក្តី អស់ ៣ ខែក្តី អស់ ២ ខែក្តី អស់ ១ ខែក្តី អស់កន្លះខែក្តី, បណ្តាផលទាំងឡាយពីរ ផលណាមួយ គង់នឹងបានសម្រេចដល់បុគ្គលនោះតាមប្រាថ្នាដោយពិត គឺនឹងបានសម្រេចនូវភាពជាអរហន្តក្នុងបច្ចុប្បន្ន ពុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់នៅ ក៏គង់នឹងបានសម្រេចនូវភាពជាអនាគាមិបុគ្គលពុំខាន ។

ម្នាលភិក្ខុទាំងឡាយ កុំបាច់ដល់ទៅអស់កន្លះខែ, បើបុគ្គលណាមួយ ទោះភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ចំរើននូវសតិបដ្ឋានទាំងឡាយ ៤ នេះ តាមលំដាប់នៃវិធីចំរើនដែលតថាគតបានពោលមកហើយយ៉ាងនេះ, អស់៧ថ្ងៃ, បណ្តាផលទាំងឡាយពីរ ផលណាមួយ គង់នឹងបានសម្រេចដល់បុគ្គលនោះ តាមប្រាថ្នាដោយពិត គឺនឹងបានសម្រេចនូវភាពជាអរហន្តក្នុងបច្ចុប្បន្ន ពុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់នៅ ក៏គង់នឹងបានសម្រេចនូវភាពជាអនាគាមិបុគ្គលពុំខានឡើយ ។

លុះព្រះតថាគតបរមសាស្តា ទ្រង់សម្តែងនូវអានិសង្សនៃការចំរើននូវសតិបដ្ឋានទាំង ៤ នេះចប់ហើយ ក៏ទ្រង់សម្តែងបញ្ជាក់ថែមទៀតតាមន័យ

ខាងដើមថា ម្នាលភិក្ខុទាំងឡាយ ផ្លូវគឺសតិបដ្ឋានទាំងឡាយ ៤ នេះ ជាផ្លូវមូលតែមួយ ប្រព្រឹត្តទៅដើម្បីបាននិសង្ស ៥ ប្រការគឺ ដើម្បីសេចក្ដីបរិសុទ្ធិស្អាតរបស់សត្វទាំងឡាយ ១ ដើម្បីកន្លងបង់នូវសេចក្ដីសោកនឹងសេចក្ដីខ្សឹកខ្សួលរំជួលចិត្តទាំងឡាយ ១ ដើម្បីអស្ដង្គតរលត់ទុក្ខនឹងទោមនស្សទាំងឡាយ ១ ដើម្បីដល់នូវអរិយមគ្គជាធម៌ស្រោចស្រង់សត្វ ១ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវនិព្វាន ១ ។

ពាក្យណាដែលតថាគតបានពោលហើយថា សាសនារបស់តថាគតជាគុណសម្រាប់ស្រោចស្រង់សត្វឲ្យរួចផុតចាកទុក្ខ ពាក្យនោះ តថាគតបានពោលហើយ ព្រោះអាស្រ័យនូវផ្លូវដ៏ប្រសើរគឺ សតិបដ្ឋានទាំង ៤ នេះឯង ។ ព្រះភគវតែ ទ្រង់សម្ដែងនូវសតិបដ្ឋានសូត្រនេះចប់ហើយ ភិក្ខុទាំងអស់អង្គនោះ ក៏មានចិត្តត្រេកអរចំពោះភាសិតនៃព្រះអង្គ ។

សតិបដ្ឋានសូត្រ ចប់ ។

# សន្លឹកប្រាប់មាតិកាធម៌

ឈ្មោះមាតិកាធម៌ ទំព័រ


សេចក្ដីបរិយាយក្នុងខាងដើមនៃសតិបដ្ឋាន ........ ១

ពាក្យថា សតិបដ្ឋាន ........ ៥

ពាក្យថា មគ្គ ........ ៦

សតិបដ្ឋាន ៤ នោះគឺអ្វីខ្លះ ? ........ ១០

កាយានុបស្សនាសតិបដ្ឋាន ........ ១០

វេទនានុបស្សនាសតិបដ្ឋាន ........ ១១

ចិត្តានុបស្សនាសតិបដ្ឋាន ........ ១២

ធម្មានុបស្សនាសតិបដ្ឋាន ........ ១៣

កាយានុបស្សនាសតិបដ្ឋាន ........ ១៤

អានាបានបព្វៈ ........ ១៤

ឥរិយាបថបព្វៈ ........ ១៧

សម្បជញ្ញបព្វៈ ........ ១៨

បដិកូលបព្វៈ ........ ១៩

ធាតុបព្វៈ ........ ២១

នវសីវថិកាបព្វៈ ........ ២២

វេទនានុបស្សនាសតិបដ្ឋាន ........ ២៤

# សន្ទឹកប្រាប់មាតិកាធម៌

ឈ្មោះមាតិកាធម៌ ទំព័រ

ចិត្តានុបស្សនាសតិបដ្ឋាន .................... ៣៦
ធម្មានុបស្សនាសតិបដ្ឋាន .................... ៣៦
នីវរណបព្វៈ .................... ៣៦
ខន្ធបព្វៈ .................... ៤៦
អាយតនបព្វៈ .................... ៤៨
ពោជ្ឈង្គបព្វៈ .................... ៥២
សច្ចបព្វៈ .................... ៦៣
ទុក្ខសច្ច .................... ៦៣
សមុទយសច្ច .................... ៦៩
អាយតនៈខាងក្នុង ៦ .................... ៧០
អាយតនៈខាងក្រៅ ៦ .................... ៧២
វិញ្ញាណ ៦ .................... ៧៣
សម្ផស្ស ៦ .................... ៧៤
វេទនា ៦ .................... ៧៥
សញ្ញា ៦ .................... ៧៧
សញ្ចេតនា ៦ .................... ៧៧

# សន្លឹកប្រាប់មាតិកាធម៌

## ឈ្មោះមាតិកាធម៌ ទំព័រ


តណ្ហា ៦ .......................................... ៧៨

វិតក្កៈ ៦ .......................................... ៧៨

វិចារៈ ៦ .......................................... ៧៩

និរោធសច្ច .......................................... ៨០

អាយតនៈខាងក្នុង ៦ .......................................... ៨១

អាយតនៈខាងក្រៅ ៦ .......................................... ៨២

វិញ្ញាណ ៦ .......................................... ៨២

សម្ផស្ស ៦ .......................................... ៨២

វេទនា ៦ .......................................... ៨៣

សញ្ញា ៦ .......................................... ៨៣

សញ្ចេតនា ៦ .......................................... ៨៤

តណ្ហា ៦ .......................................... ៨៤

វិតក្កៈ ៦ .......................................... ៨៥

វិចារៈ ៦ .......................................... ៨៥

មគ្គសច្ច .......................................... ៨៦

សតិបដ្ឋានការនានិសង្ស .......................................... ៩១